វិទ្យាស្ថាន
បណ្តុះបណ្តាល និង ស្រាវជ្រាវ
ដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ)

# សង្ខេប
# របាយការណ៍អភិវឌ្ឍន៍
# ប្រចាំឆ្នាំ២០០៦-០៧





វិទ្យាស្ថាន
បណ្តុះបណ្តាល និង ស្រាវជ្រាវ
ដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ)

# សង្ខេប
# របាយការណ៍អភិវឌ្ឍន៍
# ប្រចាំឆ្នាំ២០០៦-២០០៧

*Annual Development Review*
*2006 - 2007*

ភ្នំពេញ ខែកុម្ភៈ ឆ្នាំ២០០៧

*ក្នុងលក្ខណៈជា វិទ្យាស្ថានឯករាជ្យមួយរបស់កម្ពុជាខាងការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍ វបសអ មានបេសកកម្មចូលរួមចំណែកដល់ការអភិវឌ្ឍន៍ប្រទេសកម្ពុជាប្រកបដោយចីរភាព និងការលើកកំពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា តាមរយៈការស្រាវជ្រាវមានគុណភាពខ្ពស់ពីគោលនយោបាយអភិវឌ្ឍន៍ ការផ្សព្វផ្សាយ ចំណេះដឹង និងការកសាងសមត្ថភាព ។*

*វបសអ ប្រឹងប្រែងបំពេញបេសកកម្មនេះ ដោយធ្វើការងារជាដៃគូជាមួយស្ថាប័នសាធារណៈ និងសង្គមស៊ីវិលកម្ពុជាស្ថាប័នអភិវឌ្ឍន៍ក្នុងតំបន់និងពិភពលោកនិងដោយគោរពដល់សមត្ថភាពរបស់ប្រជាពលរដ្ឋនិងស្ថាប័នកម្ពុជា ចំណេះដឹង និងបទពិសោធន៍ក្នុងស្រុក ព្រមទាំងប្រវត្តិសាស្ត្រ និងវប្បធម៌របស់ប្រទេសកម្ពុជា ។*

© ២០០៧ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង - គ្មានផ្នែកណាមួយនៃឯកសារនេះ ត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗ ដូចជា អេឡិចត្រូនិក យន្តកម្ម ថតចម្លង... ។ល។ ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពីវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ ។

សង្ខេបរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០០៦-២០០៧
*Annual Development Review 2006-07*
ភ្នំពេញ ខែកុម្ភៈ ឆ្នាំ២០០៧

*ហ៊ីង វុត្ថា, ភីម រុនស៊ីណារិទ្ធិ, ប៊ុន ដូរីណា, ផាន់ ដាលីស, ទូត សុខផល្លី, សុខ ស៊ីណា, ប្រ៉ែត បាឡាដ, ធន់ វឌ្ឍនា, កាស្តេ-ហាសិន, គ្រីសស្មៀន-ស្លុត, តុប-នេត, សូ សុវណ្ណារិទ្ធិ, លឹម សុវណ្ណារា, នូ កែវ សុទ្ធា, ប៉ក់ គីមជឿន និង ហ៊ាង វុទ្ធី*

ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ ។ ទស្សនៈទាំងនោះ មិនមែនជាទស្សនៈរបស់វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាទេ ។

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
☞ អាសយដ្ឋាន ៥៦ ផ្លូវលេខ៣១៥ ខណ្ឌទួលគោក ភ្នំពេញ កម្ពុជា
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៣៨៤/៧០១, ៨៨៣-៦០៣, ៨៨១-៩១៦
🖷 (៨៥៥-២៣) ៨៨០ ៧៣៤
អ៊ីមែលៈ cdri@camnet.com.kh website: http://www.cdri.org.kh

កែសម្រួល និងរចនាដោយៈ យូ សិទ្ធីរិទ្ធ, អ៊ុំ ចាន់ថា, ភីម ថាន់ និង គីម ចិត្រា
បោះពុម្ពនៅប្រទេសកម្ពុជា ដោយរោងពុម្ពជប៉ុន
បកប្រែដោយៈ ច័ន្ទ សុផល និង លិ វុឌ្ឍី

# មាតិកា


បុព្វកថា.....០៧

បញ្ជីអក្សរកាត់ .....០៨

១. សេចក្តីផ្តើម: និន្នាការអភិវឌ្ឍន៍ចំបងៗ .....០៩

២. ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា.....១៥

៣. ការវិនិយោគផ្ទាល់បរទេស និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា.....១៩

៤. ចំណូលពីធនធានធម្មជាតិអាចជាគុណប្រយោជន៍ផង និងជាគុណវិបត្តិផងក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច.....២៣

៥. ផលិតកម្មសត្វនិងសេវាកម្មបសុព្យាបាលនៅកម្ពុជា.....២៧

៦. សម្បត្តិធម្មជាតិរួម និងភាពក្រីក្រ: ការវិភាគលើចំណងទាក់ទងរវាងភាពក្រីក្រជនបទ និងការប្រើប្រាស់ធនធានធម្មជាតិ .....៣១

៧. ពលកម្មចំណាកស្រុកក្នុងជីវភាពជនបទ: បញ្ហាប្រឈម និងកាលានុវត្តិភាព.....៣៧

៨. គណនេយ្យភាពជាអ្វី? និងមានស្ថានភាពយ៉ាងដូចម្តេចនៅកម្ពុជា?.....៤១

បញ្ជីឯកសារពិភាក្សារបស់ វបសអ.....៤៨

# បុព្វកថា

ឯកសារនេះជាសេចក្តីសង្ខេបនៃរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំទី២ របស់ វិទ្យាស្ថានបណ្តុះបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ-CDRI) ដែលធ្វើការសិក្សាពីបញ្ហាអភិវឌ្ឍន៍ដ៏សំខាន់ៗរបស់ប្រទេសកម្ពុជា និងដែលបោះពុម្ពផ្សាយជាភាសាអង់គ្លេស ។ របាយការណ៍សំរាប់ឆ្នាំនេះ ផ្តោតលើភាពក្រីក្រនៅជនបទ ព្រមទាំងយុទ្ធសាស្ត្រនិងគោលនយោបាយកាត់បន្ថយភាពក្រីក្រ ដោយបង្ហាញពីលទ្ធផលរកឃើញនៃការស្រាវជ្រាវចំបងៗនាពេលថ្មីៗរបស់ វបសអ ពោលគឺការសិក្សាពីការចាកចេញផុតពីភាពក្រីក្រ និងការវាយតំលៃពីភាពក្រីក្រដោយមានការចូលរួមនៅបឹងទន្លេសាប ។ ឯកសារសង្ខេបជាភាសាខ្មែរ បានបោះពុម្ព ផ្សាយព្រមគ្នានឹងឯកសារជាភាសាអង់គ្លេស ដើម្បីអាចបំរើបានច្រើនថែមទៀតដល់មជ្ឈដ្ឋានអ្នកអាន ។ ក្នុងការជ្រើសរើសប្រធានបទសំរាប់របាយការណ៍នេះ វបសអ បានព្យាយាមផ្តោតលើទិដ្ឋភាពសំខាន់ៗនៃការអភិវឌ្ឍន៍នៅប្រទេសកម្ពុជា ព្រមទាំងផ្តល់ព័ត៌មាន ការវិភាគ និងការយល់ដឹងថ្មីៗទៀតទៅដល់អ្នកកសាងគោលនយោបាយ អ្នកផ្តល់ជំនួយ សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ។ អត្ថបទនីមួយៗ និងកំរងអត្ថបទទាំងមូល អាចក្លាយជាវិភាគទានមួយដ៏មានប្រយោជន៍សំរាប់ការពិភាក្សា និងការជជែកវែកញែកពីបញ្ហាអភិវឌ្ឍន៍នាពេលបច្ចុប្បន្ន ដោយមានចំណុចផ្តោតសំខាន់មួយគឺភាពចាំបាច់នៃការកាត់បន្ថយភាពក្រីក្រដែលមានកំណត់គោលដៅជាក់លាក់ ។

ឯកសារនេះ បង្ហាញជារួមនៅក្នុងសេចក្តីផ្តើមនូវ លទ្ធផលម៉ាក្រូសេដ្ឋកិច្ចនាពេលថ្មីៗ ដោយបានពិនិត្យជាពិសេសពីយុទ្ធសាស្ត្រសំរាប់ជំរុញការលូតលាស់ដែលមានសមត្ថភាពកាត់បន្ថយភាពក្រីក្រកំរិតខ្ពស់ ។ របាយការណ៍ក៏បង្ហាញផងដែរពីចំណងទាក់ទងដ៏ទន់ខ្សោយរវាងការលូតលាស់នឹងការកាត់បន្ថយភាពក្រីក្រ វិសមភាពផ្សេងៗមួយចំនួន ទិដ្ឋភាពសំខាន់ៗនៃសេដ្ឋកិច្ចកម្ពុជា ហើយនិងបរិបទអភិវឌ្ឍន៍ធំទូលាយ ដែលរួមមានទាំងការគ្រប់គ្រងធនធានធម្មជាតិ អភិបាលកិច្ច និងបញ្ហាយេនឌ័រផង ។

របាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំរបស់វបសអលេខនេះបានផ្សព្វផ្សាយនៅទិវាបើកសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០០៧ ដែលជាការងាររួមជាដៃគូថ្មីមួយរវាង វបសអ និងធនាគារអេអិនហ្សែតរ៉ូយ៉ាល់ ។ ប្រធានបទនៃសន្និសីទឆ្នាំនេះគឺ *ចក្ខុវិស័យកម្ពុជាឆ្នាំ២០០៧: កាលានុវត្តិភាព ដើម្បីកំណើន ការអភិវឌ្ឍន៍ និងវិបុលភាពរួម* ។ នៅឆ្នាំនីមួយៗ សន្និសីទចក្ខុវិស័យ នឹងអញ្ជើញមកជួបជុំគ្នានូវអ្នកដឹកនាំនៅក្នុងរដ្ឋាភិបាល វិស័យឯកជន ស្ថាប័នស្រាវជ្រាវ អង្គការសង្គមស៊ីវិល និងសហគមន៍អភិវឌ្ឍន៍អន្តរជាតិ ដើម្បីពិនិត្យពិចារណាពីអនាគតរបស់ប្រទេសកម្ពុជា ។

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា សង្ឃឹមថា សន្និសីទចក្ខុវិស័យប្រចាំឆ្នាំ ព្រមទាំងរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ និងរបាយការណ៍សង្ខេបជាភាសាខ្មែរ នឹងចូលរួមចំណែកបានច្រើនដល់ការផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវការស្រាវជ្រាវមានគុណភាពខ្ពស់ខាងគោលនយោបាយ ស្តីពីបញ្ហាសំខាន់ៗសំរាប់អនាគតប្រទេសកម្ពុជា ព្រមទាំងជួយផ្តល់ព័ត៌មានដល់ការកសាងគោលនយោបាយអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍អន្តរជាតិនានា ព្រមទាំងអ្នកពាក់ព័ន្ធផ្សេងៗទៀត ។

*ឡារី ស្ត្រេន្ទ*
*នាយកប្រតិបត្តិនៃ វបសអ*
*ខែកុម្ភៈ ឆ្នាំ២០០៧-០២-១៣*

# បញ្ជីអក្សរកាត់

| | |
|---|---|
| ផសស | ផលិតផលក្នុងស្រុកសរុប (Gross Domestic Products) |
| ភសសស | ភ្នាក់ងារសុខភាពសត្វសហគមន៍ (Community-based Animal Health Workers) |
| វបសអ/CDRI | វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (Cambodia Development Resource Institute) |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី (Asian Development Bank) |
| CMDGs | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (Cambodian Millennium Development Goals) |
| CPR | សម្បត្តិធម្មជាតិរួម (Common Property Resources) |
| FDI | វិនិយោគផ្ទាល់ពីបរទេស (Foreign Direct Investment) |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ (International Monetary Fund) |
| HFCE | ចំណាយប្រើប្រាស់ចុងក្រោយតាមគ្រួសារ (Household Final Consumption Expenditure) |
| MOPS | ការសិក្សាពីការចាកផុតពីភាពក្រីក្រ (Moving out of Poverty Study) |
| NRE | ធនធានធម្មជាតិ និងបរិស្ថាន (Natural Resources and Environment) |
| NIS | វិទ្យាស្ថានជាតិស្ថិតិ (National Institute of Statistics) |
| NSDP | ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ (National Strategic Development Plan) |
| PPA | ការវាយតំលៃភាពក្រីក្រដោយមានការចូលរួម (Participatory Poverty Assessment) |
| WB | ធនាគារពិភពលោក (World Bank) |

# ១. សេចក្តីផ្តើមៈ និន្នាការអភិវឌ្ឍន៍ចំបងៗ

ដោយ ប្រ៉េត បាឡាដ

## ១.១. ម៉ាក្រូសេដ្ឋកិច្ចមានដំណើរការល្អ

ដំណើរការម៉ាក្រូសេដ្ឋកិច្ចជាទូទៅនៃសេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០០៥ កន្លងមកនេះ បានបង្ហាញពីភាពខ្លាំងជាងការរំពឹងទុក ដែលជាព័ត៌មានលើកទឹកចិត្តចំពោះអ្នកធ្វើផែនការក្នុងរដ្ឋាភិបាល អ្នកផ្តល់ជំនួយ និងអ្នកពាក់ព័ន្ធនានា ។ ផលិតផលក្នុងស្រុកសរុប ( ផសស) ១៣,៤% ដែលទទួលបាននៅឆ្នាំ២០០៥ គឺជាការរីកចំរើនមួយដ៏ធំ បើធៀបទៅនឹង ១០,០% នៅឆ្នាំ២០០៤ ហើយនិង ៨,១% នៅចន្លោះឆ្នាំ២០០០ ដល់ ២០០៤ ។ ផសស កសិកម្ម បានកើនដល់ ១៦,៦% នៅទន្ទឹមគ្នានឹង ផសស ឧស្សាហកម្ម និងសេវាកម្ម បានកើនឡើងចំនួន ១២,១% ដូចគ្នា ។ តួលេខទាំងអស់ខាងលើនេះបានកើនឡើង ហួសពីការស្មានរបស់គ្រឹះស្ថាននានាជាច្រើននៅកម្ពុជាដែលបានគិតទុកថា ការកើនឡើងនៃសេដ្ឋកិច្ចអាចមានដោយយឺតៗនោះ ។ ឧទាហរណ៍ ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានទស្សន៍ទាយថា សេដ្ឋកិច្ចកម្ពុជាអាចកើនក្នុងចន្លោះ ២,៣ ទៅ ២,៦% តែប៉ុណ្ណោះ ។ វិទ្យាស្ថាន CDRI បានទស្សន៍ទាយដោយសុទិដ្ឋិនិយមជាងគេគឺ ៦,០% ។

តួលេខកំណើន ផសស នៅឆ្នាំ២០០៥ របស់រដ្ឋាភិបាល ឆ្លុះបញ្ចាំងឱ្យឃើញពីការកែតំរូវឡើងវិញនូវតួលេខប៉ាន់ស្មានក្នុងគណនេយ្យជាតិ ក្នុងនោះមានទាំងការកែលំអ និងការពង្រីកដែនគ្របដណ្តប់ ព្រមទាំងការកែលំអក្នុងវិធីសាស្ត្រប្រមូលទិន្នន័យ ។ ឧទាហរណ៍ ដែនគ្របដណ្តប់ត្រូវបានកែលំអឡើងសំរាប់ផ្នែកដឹកជញ្ជូនទំនិញ និងថែទាំសុខភាពឯកជន ហើយត្រូវបានពង្រីកបន្ថែមដោយដាក់បញ្ចូលផងដែរនូវផ្នែកជីកយករ៉ែមាស រុករកប្រេងកាត ផ្គត់ផ្គង់ឧស្ម័ន និងមីក្រូហិរញ្ញវត្ថុ ។ ការកែលំអវិធីសាស្ត្រប្រមូលទិន្នន័យរួមមាន ការប៉ាន់ស្មានឱ្យបានកាន់តែត្រឹមត្រូវឡើងនូវចំណាយប្រើប្រាស់ចុងក្រោយតាមគ្រួសារ (HFCE) និងចំណាយលើសំភារៈបរិក្ខារជាប់លាប់ ហើយវិជ្ជាស្ថានជាតិស្ថិតិ (NIS) បានធ្វើការផ្លាស់ប្តូរមួយចំនួនទាក់ទិននឹងប្រភពទិន្នន័យ ។ ទន្ទឹមគ្នានេះ កំណើន ផសស កសិកម្ម អាចជាលទ្ធផលនៃកត្តារួមផ្សំជាច្រើនដូចជា ធាតុអាកាសអំណោយផល ការកែលំអប្រព័ន្ធធារាសាស្ត្រ ការបង្កើនផ្ទៃដីដាំដុះ ការផ្លាស់ប្តូរបច្ចេកទេសដាំដុះ និងសេវាកម្មផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ។

ជំពូក ២ នៅក្នុងស្នាដៃនេះ ផ្តល់នូវការវិភាគដ៏ល្អិតល្អន់អំពី គណនេយ្យជាតិ អត្រាលូតលាស់ជាតិនិងតាមវិស័យនីមួយៗ ថវិកា និងតុល្យភាពនៃពាណិជ្ជកម្មនិងជញ្ជីងទូទាត់ រូបិយវត្ថុ អត្រាការប្រាក់ អត្រាប្តូរប្រាក់និងអតិផរណា ព្រមទាំងការពិនិត្យឡើងវិញនូវស្ថានភាពមានការងារធ្វើ និងស្ថានភាពពលករងាយគ្រោះ ។ ជំពូកនេះបញ្ចប់ដោយមានការវាយតម្លៃលើការទស្សន៍ទាយសេដ្ឋកិច្ចក្នុងរយៈពេលខ្លីខាងមុខនេះ ។

## ១.២. កំណើនសេដ្ឋកិច្ចខ្ពស់ ប៉ុន្តែមានកំណើនអសមធម៌?

រយៈពេលមួយឆ្នាំពិបាកឱ្យគេធ្វើការសន្និដ្ឋានទំនោរសេដ្ឋកិច្ចជាផ្លូវការណាស់ ពិសេសវិស័យកសិកម្ម ដែលអ្នកធ្វើផែនការ និងអ្នកផ្តល់ជំនួយនានាមិនទាន់អាចផ្អែកលើទំនោរនេះបានឡើយ ។ ដូចគ្នានេះផងដែរ ចំពោះដំណឹងល្អអំពីសេដ្ឋកិច្ចនៅកំរិតម៉ាក្រូ អាចជារបាំងដល់សូចនាករនានា ព្រោះថាកំណើនសេដ្ឋកិច្ចទាំងនេះហាក់ដូចជានៅមានកំរិតតូចចង្អៀត និងមានមូលដ្ឋានផុយស្រួយនៅឡើយ ។ ក្នុងនោះគឺរបាយមិនស្មើគ្នានៃការចែកចាយផលចំណេញដែល

ទទួលបានពីកំណើននេះ ។ ដោយធ្វើការប្រៀបធៀបទិន្នន័យនានា បានមកពីការអង្កេតសង្គមកិច្ច-សេដ្ឋកិច្ចនៅឆ្នាំ១៩៩៣ និងឆ្នាំ២០០៤ ធនាគារពិភពលោក បានធ្វើការវាយតម្លៃមួយនាឆ្នាំ២០០៦ ហើយរកឃើញថាភាពក្រីក្រនៅកម្ពុជាបានថយចុះ ១% ក្នុងមួយឆ្នាំ នាទសវត្សរ៍កន្លងមកនេះ ។ ប៉ុន្តែការថយចុះនៃភាពក្រីក្រនេះមានភាពប្រសើរឡើងតែនៅតាមតំបន់ទីក្រុង ដូចជា ភាពក្រីក្រថយចុះ ៦០% នៅទីក្រុងភ្នំពេញ ៤៤% នៅទីក្រុងសំខាន់ៗ តែគេឃើញមានភាពក្រីក្រតែ ២២% បានថយចុះនៅតំបន់ជនបទ ដែលនៅទីនោះមានប្រជាពលរដ្ឋក្រីក្ររស់នៅប្រមាណ ៩០% នៃប្រជាពលរដ្ឋក្រីក្រសរុបទូទាំងប្រទេស ។

ស្ថានភាពថយចុះនៃភាពក្រីក្រមិនដូចគ្នានេះបាន និងកំពុងបង្កឱ្យមានការកើនឡើងនូវភាពមិនស្មើគ្នា (អសមធម៌) ដូចដែលបានធ្វើការវាស់ស្ទង់ដោយមេគុណជីនី[១] (Gini coefficient) ពី ០,៣៦ ទៅ ០,៤០ ក្នុងរយៈពេលដូចគ្នា ។ អសមធម៌នេះជាកង្វល់មួយគួរឱ្យបារម្ភណ៍ណាស់ ពិសេសរវាងអ្នកទីក្រុង និងអ្នកជនបទ ។ នៅចន្លោះឆ្នាំ១៩៩៤ និង ២០០៤ មេគុណជីនីថយចុះពី ០,៣៩ ទៅ ០,៣៧ ចំពោះទីក្រុងភ្នំពេញ តែនៅតំបន់ទីក្រុងដទៃទៀតមេគុណនេះនៅរក្សាដដែលគឺ ០,៤៤ ។ ផ្ទុយទៅវិញ នៅតំបន់ជនបទ មេគុណនេះបានកើនពី ០,២៧ ដល់ ០,៣៣ (WB, 2006) ។ ការស្រាវជ្រាវខាងលើ ក៏បានបង្ហាញផងដែរថា ស្តង់ដារជីវភាពរបស់អ្នកក្រីក្របំផុត ២០% នៃអ្នកទាំងនោះបានកើនតែ ៨% រីឯស្តង់ដារជីវភាពរបស់អ្នកលើគេ ២០% បានកើនឡើង ដល់ ៤៥% នៅក្នុងអំឡុងទសវត្សរ៍កន្លងមកនេះ ។ តួលេខនេះចង្អុលបង្ហាញថា ផលដែលទទួលបានពីការកើនឡើងនៃកំណើនសេដ្ឋកិច្ចមិនត្រូវបានចែកចាយដោយស្មើភាពទេ រវាងអ្នកទីក្រុងនិងអ្នកជនបទ ហើយនិងរវាងអ្នកមាននិងអ្នកក្រ (រវាងក្រុមអ្នកទទួលផលផ្សេងគ្នា) ។

## ១.៣. ភាពចាំបាច់សំរាប់ពង្រីកចំណងទាក់ទងគ្នា

ហេតុមួយដែលនាំឱ្យមានភាពមិនស្របគ្នានៃការទទួលផលចំណេញពីកំណើនសេដ្ឋកិច្ច គឺភាពទន់ខ្សោយនៃចំណងទាក់ទងគ្នានៅខាងដើមខ្សែ និងខាងចុងខ្សែ រវាងវិស័យដែលមានកំណើនសំខាន់ៗ និងវិស័យដទៃទៀតនៃសេដ្ឋកិច្ច ។ ថ្វីបើមានកំនើនយ៉ាងលឿនក្នុងប៉ុន្មានឆ្នាំថ្មីៗនេះក្តី ក៏សេដ្ឋកិច្ចកម្ពុជាមិនអាចបង្កើតការងារថ្មីៗគ្រប់គ្រាន់ ដើម្បីស្រូបយកកំលាំងពលកម្ម ដែលកំពុងកើនឡើងយ៉ាងលឿនផងដែរនោះទេ ។ ផលិតភាពកសិកម្មនៅមានកំរិតទាបជាទីបំផុត ដែលមិនអាចផ្តល់ការងារធ្វើគ្រប់គ្រាន់ដល់អ្នកជនបទ ហើយនេះជំរុញឱ្យពលរដ្ឋកម្ពុជាក្មេងៗចាកចោលភូមិឃុំរបស់ពួកគេទៅរកការងារធ្វើនៅតាមតំបន់ទីក្រុង ឬឆ្លងដែនទៅប្រទេសដទៃទៀត ។ ដោយសារសេដ្ឋកិច្ចនៅតែបន្តផ្អែកលើវិស័យរងពីរគឺតម្បាញនិងទេសចរណ៍ក្នុងកំរិតតូចចង្អៀតបែបនេះ ហើយដែលមានលក្ខណៈងាយស្រួយតាមស្ថានការបរទេសនោះ ពលករថ្មីៗត្រូវបង្ខំចិត្តប្រជែងគ្នាដើម្បីស្វែងរកឱកាសការងារដ៏មានកំណត់ជាទីបំផុតនេះ ។ជាលទ្ធផល គេឃើញមានយុវជនដ៏ច្រើនពិសេសបុរសៗគ្មានការងារធ្វើ ។បញ្ហាដែលបន្សល់ដោយសារការគ្មានការងារធ្វើនេះគឺ ការកើនឡើងនៃការប្រើប្រាស់គ្រឿងញៀន ឬអំពើហឹង្សាក្នុងចំណោមយុវជនទាំងនោះ ។

ជំពូក ៣ ពិនិត្យមើលទំនាក់ទំនងរវាងវិនិយោគបរទេស (FDI) និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ហើយនិងចំណងទាក់ទងរបស់វាទៅនឹងកំណើនសេដ្ឋកិច្ច ។ ទោះបីវិនិយោគបរទេស (FDI) បាននិងកំពុងមានតួនាទីយ៉ាងសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងជាប្រភពការងារធ្វើដ៏ធំនៅកម្ពុជានាទសវត្សរ៍កន្លងមកក៏ដោយ ក៏

---

[១] មេគុណជីនី គឺជារង្វាស់វិសមភាពរបាយចំណូល ឬចំណាយ ដែលមានកំរិតពី ០ ដល់ ១ ។ ០ មានន័យថាមានសមភាពទាំងស្រុង ១ មានន័យថា មានវិសមភាពទាំងស្រុង ។

ឥទ្ធិពលរបស់វាទៅលើការកាត់បន្ថយភាពក្រីក្រហាក់នៅមានកំរិតនៅឡើយដោយសារហេតុមួយចំនួន ។ ការងារធ្វើស្ទើរទាំងអស់ប្រមូលផ្តុំគ្នានៅតាមតំបន់ទីក្រុង និងទាមទារទេពកោសល្យ និងការអប់រំខ្ពស់ ដែលអ្នកក្រីក្រមិនអាចឈានដល់ ។ វិនិយោគបរទេសផ្តោតជាសំខាន់ទៅលើវិស័យឧស្សាហកម្ម និងសេវាកម្មទេសចរណ៍ដែលមានទីតាំងនៅតាមតំបន់ទីក្រុង ចំណែកឯអ្នកក្រីក្រភាគច្រើនលើសលប់រស់នៅ និងបំរើការងារកសិកម្មតាមជនបទ ។ ជំពូកនេះពិភាក្សាអំពីវិធាននានាដើម្បីបង្កើនវិភាគទាននៃFDI ទៅក្នុងកម្មវិធីកាត់បន្ថយភាពក្រីក្ររបស់រដ្ឋាភិបាល ។

ជំពូក ៤ ពិនិត្យមើលដោយឡែកលើវិស័យប្រេងកាត និងឧស្ម័នធម្មជាតិ ដែលជាផ្នែកមួយទាក់ទាញជាសំខាន់ និងមានកំរិតខ្ពស់ដល់ការវិនិយោគបរទេស ។ ការរកឃើញប្រេង និងឧស្ម័នធម្មជាតិនៅពេលថ្មីៗ និងផែនការធ្វើអាជីវកម្ម ឆ្នាំ២០០៨-០៩ ខាងមុខនេះ ហាក់ដូចជាចំពេលល្អចំពោះតម្លៃខ្ពស់របស់ប្រេង និងចំពេលល្អចំពោះសេចក្តីត្រូវការថវិកាដ៏ប្រញាប់ជាទីបំផុតរបស់រដ្ឋាភិបាល សំរាប់បង្កើនទុនឱ្យដំណើរការការអភិវឌ្ឍន៍ដែលមានស្រាប់នៅពេលនេះ ។ ជំពូកនេះពិភាក្សាយុទ្ធសាស្ត្រនានា ដែលគេបានអនុវត្តនៅបណ្តាប្រទេសដទៃទៀតក្នុងគោលបំណងចៀសវាង "បណ្តាសា" (curse) ដែលអាចកើតមានពីប្រាក់ចំណូលដ៏លើសលប់ពីវិស័យរ៉ែ តែការប្រើប្រាស់សក្តានុពលប្រាក់ចំណូលដ៏លើសលប់នេះឱ្យបានសមស្របទៅក្នុងការអភិវឌ្ឍន៍សង្គមកិច្ច និងសេដ្ឋកិច្ច តាមគន្លងនានាដែល ផលចំណូលទាំងនេះអាចត្រូវបានគេបែងចែកដោយសមធម៌នៅក្នុងសង្គមទាំងមូល ។

## ១.៤. ការពង្រឹងវិស័យកសិកម្ម

មានការយល់រួមគ្នាមួយដ៏ធំធេងក្នុងចំណោមរដ្ឋាភិបាល អ្នកផ្តល់ជំនួយ សង្គមស៊ីវិល និងសហគមន៍ស្រាវជ្រាវ នៅកម្ពុជាថា ការចាំបាច់ជាបន្ទាន់មួយគឺការកាត់បន្ថយភាពក្រីក្រ តាមរយៈបង្កើនផលិតផលកសិកម្ម និងបង្កឱកាសឱ្យមានការងារធ្វើក្រៅពីកសិកម្មឱ្យបានច្រើនឡើងទៀតនៅតាមតំបន់ជនបទ ។ ការពង្រឹងវិស័យកសិកម្មគឺជាជ្រុងមួយនៃគោលនយោបាយយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាល និងដូចដែលមានចែងនៅក្នុងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ (NSDP) ។ យុទ្ធសាស្ត្រនេះមានបួនផ្នែកសំខាន់ៗគឺៈ កែលំអផលិតភាព និងធ្វើឱ្យមានភាពសំបូរបែបនៅក្នុងវិស័យកសិកម្ម កែលំអដីនិងការរំដោះដីធ្លីពីចំការមីន កែទំរង់វិស័យជលផល និងកែទំរង់វិស័យព្រៃឈើ[២] ។ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (CMDGs) ក៏បានបញ្ជាក់យ៉ាងច្បាស់លាស់ដែរអំពីការពង្រឹងវិស័យជនបទដើម្បីលុបបំបាត់ភាពក្រីក្រ និងទុរ្ភិក្ស[៣] ។

ការវាយតម្លៃការកាត់បន្ថយភាពក្រីក្រ របស់ធនាគារពិភពលោក ក៏អះអាងដែរថា ការពង្រឹងវិស័យកសិកម្មដែលជាក្បាលម៉ាស៊ីនទីបីនៃការលូតលាស់សេដ្ឋកិច្ច គឺជាការចាំបាច់ ដើម្បីឈានទៅសំរេចគោលបំណងកាត់បន្ថយភាពក្រីក្ររបស់រដ្ឋាភិបាល[៤] ។ វិទ្យាស្ថាន CDRI គាំទ្រយ៉ាងខ្លាំងក្លាចំពោះគោលការណ៍នេះ ដើម្បីការកាត់បន្ថយភាពក្រីក្រ ។ ការវាយតម្លៃការកាត់បន្ថយភាពក្រីក្រនោះ ក៏បានធ្វើការកត់សំគាល់ដែរថា ការបង្កើនផលិតភាពកសិកម្មអាចធ្វើទៅបានតាមរយៈការកែលំអការធានាសិទ្ធិកាន់កាប់ដីធ្លី និងហេដ្ឋារចនាសម្ព័ន្ធ ពិសេសនៅក្នុងតំបន់ប្រព័ន្ធធារាសាស្ត្រ និងការគ្រប់គ្រងទឹក ហើយទឹកនេះហើយដែលជាកត្តាចំបងជាងគេ និងត្រូវបានរដ្ឋាភិបាលទទួលស្គាល់មុនគេនៅក្នុងកំណើនសេដ្ឋកិច្ចនាឆ្នាំ២០០៥ ។ ថ្វីត្បិតតែការធានាសិទ្ធិកាន់កាប់ដីធ្លី និងហេដ្ឋារចនាសម្ព័ន្ធជា

---

[២] រាជរដ្ឋាភិបាលកម្ពុជា ( មករា ២០០៦) ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ២០០៦-២០១០

[៣] របាយការណ៍រីកចំរើនទី២នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាៈ បញ្ហាប្រឈម និងក្របខ័ណ្ឌសំរាប់ធ្វើសកម្មភាព កញ្ញា ២០០៣ ។

[៤] World Bank (2006); Halving Poverty by 2015, Cambodia Poverty Assessment.

ផ្នែកដែលគេត្រូវយកចិត្តទុកដាក់ជាប្រញាប់មុនគេក៏ដោយ ក៏ការស្រាវជ្រាវរបស់CDRI ផ្តល់មតិថានៅមានសេវាកម្មច្រើនទៀត ដែលត្រូវយកចិត្តទុកដាក់សំរាប់ក្បាលម៉ាស៊ីនទីបីនៃការលូតលាស់សេដ្ឋកិច្ច ។ សេវាកម្មទាំងនោះគឺ ការផ្តល់ឥណទានសមស្រប ការកែលំអសេវាកម្មផ្សព្វផ្សាយ និងមណ្ឌលសុខភាព ព្រមទាំងសេវាកម្មសង្គម ហើយដែលទាំងអស់នេះគឺទាមទារឱ្យមានគោលនយោបាយពីថ្នាក់ជាតិ និងការអនុវត្តន៏នៅថ្នាក់មូលដ្ឋាន ។

ជំពូក ៥ ពិនិត្យមើលអំពីវិស័យចិញ្ចឹមសត្វ ដែលវាជាផ្នែកមួយដ៏សំខាន់ចំពោះវិស័យកសិកម្មកម្ពុជា ប៉ុន្តែផ្នែកនេះត្រូវបានគេយកចិត្តទុកដាក់តិចតួចបំផុតអំពីការស្រាវជ្រាវការធ្វើគោលនយោបាយ ។ ជំពូកនេះផ្តល់ការពិនិត្យរួមមួយអំពីផលិតផលសត្វពាហនៈនៅកម្ពុជា ពិសេសយកចិត្តទុកដាក់លើបញ្ហាដែលទាក់ទងនឹងអន្តរកាលពីការចិញ្ចឹមសំរាប់បរិភោគជាលក្ខណៈគ្រួសារទៅជាផលិតផលពាណិជ្ជកម្មក្នុងស្រុកនិងក្នុងតំបន់ ។ការយកចិត្តទុកដាក់នៅក្នុងជំពូកនេះ គឺបញ្ហាការបង្កើតឱ្យមានគុណភាពបសុពេទ្យដោយចីរភាពនៅកម្ពុជា ដោយយោងជាពិសេសលើការស្រាវជ្រាវភ្នាក់ងារចិញ្ចឹមសត្វភូមិ (VLAs) នៅភាគពាយ័ព្យកម្ពុជា ។

## ១.៥. ការគ្រប់គ្រងធនធានធម្មជាតិ

ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ (NSDP) បានលើកឡើងថាការចាំបាច់នោះគឺ ការពង្រឹងការគ្រប់គ្រងធនធានធម្មជាតិតាមរយៈការកែទំរង់វិស័យជលផល និងព្រៃឈើ ។ ជំពូក ៦ ពិនិត្យទិន្នន័យដែលបានសិក្សាថ្មីៗមួយចំនួនសំរាប់រៀបចំអភិវឌ្ឍន៍ទស្សនៈសមស្របទៅនឹងស្ថានភាពជាក់ស្តែងអំពីចំណងទាក់ទងនៃភាពក្រីក្រជនបទ និងការប្រើប្រាស់ធនធានរួមនៅកម្ពុជា ។ការវិភាគរបស់វិទ្យាស្ថានCDRI លើទិន្នន័យអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច និងទិន្នន័យមានស្រាប់ដែលហៅថា ការចាកឱ្យផុតពីភាពក្រីក្រ (Moving Out of Poverty Study) របស់ខ្លួន បង្ហាញថាអត្រាភាពក្រីក្ររបស់គ្រួសារដែលពឹងអាស្រ័យលើធនធានរួមជលផល និងព្រៃឈើ មានកំរិតខ្ពស់ជាងគ្រួសារដែលមានប្រាក់ចំណូលពីប្រភពផ្សេងទៀត ។ លទ្ធផលដែលបានវិភាគទាំងនេះ បញ្ជាក់អំពីសារៈសំខាន់នៃធនធានរួមព្រៃឈើ និងជលផល ចំពោះគ្រួសារក្រីក្រទូទាំងប្រទេស ទាំងចំពោះជីវភាព និងទាំងចំពោះសំណាញ់សុវត្ថិភាពរបស់ពួកគេនាពេលដែលពួកគេមានវិបត្តិសេដ្ឋកិច្ចម្តងៗ ។ ភាពអាស្រ័យនឹងធនធានរួមនេះសំរាប់ផ្គត់ផ្គង់ជីវភាពកាន់តែមានកំរិតខ្លាំងក្លាថែមទៀតចំពោះគ្រួសារតាមភូមិ ប៉ុន្តែ អ្នកក្រីក្រនៅតែទទួលបានផល តិចជាងគ្រួសារអ្នកមានបើគិតពីទឹកប្រាក់សរុបដូចគ្នា ។ ក្នុងជំពូកនេះមានពិភាក្សាអំពីមូលហេតុនានាដែលនាំឱ្យគ្រួសារក្រីក្រប្រឈមមុខនឹងឧបសគ្គនានាជាច្រើន បើគេមានបំណងកែលំអសកម្មភាពប្រមូលផលរបស់ពួកគេ ។ ការសិក្សាវាយតំលៃភាពក្រីក្រដោយមានការចូលរួម PPA (Participatory Poverty Assessment) របស់ CDRI នៅតំបន់បឹងទន្លេសាប បង្ហាញយ៉ាងច្បាស់ថាគ្រួសារក្រីក្រ និងគ្រួសារទ័លក្រមានការពឹងអាស្រ័យលើធនធានធម្មជាតិ លើដី និងក្នុងទឹកកាន់តែច្រើនឡើងៗ សំរាប់ទ្រទ្រង់ជីវភាពដ៏ផុយស្រួយរបស់ពួកគេ ។ ការទាញយកផលពីធនធានធម្មជាតិដែលអ្នកក្រីក្រធ្លាប់បានប្រើប្រាស់ជាប្រពៃណីនោះ កាន់តែក្រទៅៗ និងជួបជំលោះជាញឹកញាប់ ដោយសារសេចក្តីត្រូវការទីផ្សារដែលពិសេសមានផលចំណេញទៅលើទីក្រុង ។

## ១.៦. ការកើនឡើងនៃអន្តោប្រវេសន៍

ការសិក្សារបស់CDRI នាពេលថ្មីៗបង្ហាញថា នៅចុងបញ្ចប់ អ្នកក្រីក្រនៅជនបទលក់ពលកម្មឱ្យអ្នកមានជាងក្នុងតំបន់ ឬអ្នកមានជាងមកពីក្រៅ ហើយបើគ្មានជំរើសបែបនេះនៅនឹងកន្លែងទេ ពួកគេនឹងចាកចោលស្រុកទេសរបស់ខ្លួន

ទៅតំបន់នានាទាំងនៅក្នុងស្រុក ឬនៅបរទេសដូចជាប្រទេសថៃឡង់ វៀតណាម និងម៉ាឡេស៊ី ដើម្បីស្វែងរកការងារធ្វើ ។ ជំពូក ៧ អង្កេតអំពីកត្តានានា ដែលហៅថា "កត្តារុញច្រាន" ដូចជាភាពខ្វះខាតផលិតផលកសិកម្ម ការថយចុះនៃធនធានធម្មជាតិ និងកត្តាអាកាសធាតុធ្ងន់ធ្ងរដទៃទៀត ដែលបង្ខំឱ្យមនុស្សទៅរកការងារធ្វើនៅតំបន់ទីក្រុង ឬនៅបរទេស ។ នៅកម្ពុជា ការធ្វើបំលាស់ទីគឺជាលទ្ធផលមួយនៃមុខងារភាពក្រីក្រដែលតម្រូវឱ្យមនុស្សផ្លាស់ទីលំនៅទៅកន្លែងផ្សេងដោយបង្ខំ តែមិនមែនដោយចេតនានោះទេ ។ នៅក្នុងន័យនេះ ចលនាកំលាំងពលកម្មអាចនិយាយបានថាជា ឧបករណ៍កាត់បន្ថយភាពក្រីក្រ ប៉ុន្តែឥទ្ធិពលរបស់វាអាចជាលក្ខណៈអន្តរកាល និងក្នុងរយៈពេលខ្លីប៉ុណ្ណោះ ដែលផ្ទុយពីការបង្ហាញនៅក្នុងឯកសារមួយចំនួន ។ ជំពូកនេះអះអាងថា នៅក្នុងន័យគោលនយោបាយ ចលនាកំលាំងពលកម្មមិនគួរទទួលយកថាជាការអភិវឌ្ឍន៍ជនបទនោះទេ ។ ការខំប្រឹងប្រែងដ៏ប្រញាប់ជាទីបំផុតនោះគឺ តំរូវការធ្វើការកែលំអជនបទ និងអភិវឌ្ឍន៍កសិកម្ម ដើម្បីបង្កើនផលិតផលកសិដ្ឋាន និងបង្កើតឱកាសការងារធ្វើក្រៅកសិដ្ឋានឱ្យបានកាន់តែច្រើនថែមទៀត ។

## ១.៧. អភិបាលកិច្ច

ការអនុវត្តន៍យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ដែលរួមមាន គោលនយោបាយកសិកម្ម ការបំរើសេវាកម្មសង្គម និងការគ្រប់គ្រងធនធានធម្មជាតិ សុទ្ធតែជាមុខងារដ៏សំខាន់ក្នុងការធ្វើអភិបាលកិច្ចរបស់អាជ្ញាធរមូលដ្ឋាន ។ ការសិក្សាថ្មីៗរបស់ CDRI បង្ហាញថា អភិបាលកិច្ចនៅថ្នាក់មូលដ្ឋានហាក់ដូចជានៅក្នុងសភាពលាយឡំគ្នា ។ ឧទាហរណ៍ការសិក្សា PPA នៅតំបន់បឹងទន្លេសាបឆ្លុះឱ្យឃើញថា ការលើកកំពស់សេវាកម្ម ដូចជាការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងវិស័យសុខភាពគឺជាការចាំបាច់ ។ នៅក្នុងភូមិខ្លះ មន្ត្រីផ្លូវការអាចមានលទ្ធភាពដោះស្រាយទំនាស់មួយចំនួន ដូចជា អំពើហឹង្សាក្នុងគ្រួសារជាដើម ។ ប៉ុន្តែ ក្នុងសកម្មភាពនេះដែរ គេឃើញមានសកម្មភាពពុករលួយក្នុងអភិបាលកិច្ចកើនឡើងយ៉ាងគឃ្លើន ដែលត្រូវតែមានការកែលំអជាបន្ទាន់ ។ ក្នុងសកម្មភាពពុករលួយនេះទៀតសោត គេឃើញមានជាប់ទាក់ទងនឹងគ្រួសារអ្នកមាន និងអ្នកធូរធារមធ្យម ដែលសកម្មភាពនេះមានឥទ្ធិពលដ៏គួរឈឺចាប់បំផុតចំពោះគ្រួសារក្រីក្រ និងគ្រួសារទ័លក្រ ។ លទ្ធផលនៃអំពើពុករលួយដែលភាគច្រើនកើតនៅក្នុងស្ថាប័នថ្នាក់មូលដ្ឋាននេះ បានរារាំងមិនឱ្យគ្រួសារក្រីក្រ និងទ័លក្រ មានលទ្ធភាពប្រើប្រាស់ធនធានធម្មជាតិ និងប្រើប្រាស់សេវាកម្មសាធារណៈ ព្រមទាំងទទួលការចោទប្រកាន់ការគៃបន្លំ អំពើប្រមាថផ្សេងៗទៀតក្នុងទំនាស់របស់ពួកគេ ។ ជារួម អំពើពុករលួយធ្វើឱ្យបាត់តុល្យភាពសិទ្ធិរវាងអ្នកមាន និងអ្នកក្រ ហើយរាល់សកម្មភាពសង្គមបានលំអៀងទៅផ្តល់ផលចំណេញដល់ក្រុមអ្នកមានអំណាច និងគ្រួសារអ្នកមាន ដែលជាការប្រឆាំង និងមាក់ងាយដល់សុខមាលភាពរបស់គ្រួសារក្រីក្រ និងគ្រួសារទ័លក្រ ។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាខាងទាំងអស់នេះ គេឃើញមានការលើកឡើងជាញឹកញាប់នូវទស្សនៈគណនេយ្យភាពក្នុងវិស័យសាធារណៈលើអភិបាលកិច្ចល្អ ការកាត់បន្ថយភាពក្រីក្រ វិមជ្ឈការ និងការអភិវឌ្ឍន៍ប្រជាធិបតេយ្យ នៅតាមរបាយការណ៍ផ្លូវការ និងសុន្ទរកថាជាច្រើន ។ ជំពូក ៨ អង្កេតមើលពីអត្ថន័យនៃពាក្យ "គណនេយ្យភាព" ដែលការប្រើពាក្យនេះហាក់ដូចជាមានការយល់ខុសៗគ្នាពីម្នាក់ទៅម្នាក់ ឬពីស្ថាប័នមួយទៅមួយទៀតក្នុងជួររដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ ហើយការដែលយល់មិនដូចគ្នានេះអាចនាំឱ្យមានការរំខានដល់វិធាននានានៃការកែទំរង់វិស័យសាធារណៈ ។ ជំពូកនេះ ពិនិត្យឡើងវិញនូវពាក្យគណនេយ្យភាព តាមរយៈការ សិក្សាឯកសារអន្តរជាតិនានាដោយចែកការយល់ឃើញជាពីរគឺៈ ទ្រឹស្តីគ្រប់គ្រងវិស័យសាធារណៈដែលលោកខាងលិចបានយក

គណនេយ្យភាពជាមូលដ្ឋានសំរាប់ការដឹកនាំ និងបន្ទាប់មកធ្វើការពិភាក្សាអំពីការយល់លើពាក្យគណនេយ្យភាពរបស់ជនជាតិកម្ពុជា ជាលក្ខណៈវប្បធម៌ ប្រវត្តិសាស្ត្រ រដ្ឋបាល នយោបាយរបស់ខ្លួន ហើយថាតើការយល់បែបនេះនឹងត្រូវគេសំរួចឱ្យមានការអនុវត្តន៍បែបណានៅក្នុង "បេតិកភណ្ឌថ្មី" នៃបរិបទកម្ពុជា ។ ជំពូកនេះផ្តល់ក្របខ័ណ្ឌមួយសំរាប់ការយល់ឃើញតាមគំនិតទាំងពីរខាងលើ ហើយថាតើការយល់ឃើញនៃគំនិតទាំងពីរនេះនឹងផ្សំគ្នាបែបណា ដើម្បីបង្កើតបានជាកូនកាត់មួយនៃពាក្យគណនេយ្យភាពនេះ ។

## ៣. និដ្ឋភាពយេនឌ័រនៅក្នុងភាពក្រីក្រ

លទ្ធផលមួយផ្នែកនៃការស្រាវជ្រាវដែលកំពុងដំណើរការរបស់ CDRI បានបង្ហាញឱ្យឃើញនៅក្នុងឯកសារនេះថាយេនឌ័រនៅតែបន្តជាកត្តាដ៏សំខាន់ក្នុងការកំណត់ការចូលរួមរបស់គ្រួសារ និងបុគ្គលទៅក្នុងសេវាកម្មសង្គម និងការគ្រប់គ្រងអចលនវត្ថុដ៏មានតម្លៃ ។ ឧទាហរណ៍មួយដែល CDRI ទទួលបានពីការអង្កេតអំពីការចុះបញ្ជីដីធ្លីតាមជនបទ និងទីក្រុងបង្ហាញថាស្ត្រីមេគ្រួសារភាគច្រើនមានដីតិចជាងបុរសមេគ្រួសារ ។ លើសពីនេះទៀត ស្ត្រីមេគ្រួសារទាំងនោះមានដីជាឡូត៍តូចៗ និងមិនសូវមានតម្លៃ ។ ស្ត្រីមេគ្រួសារទាំងនោះភាគច្រើនមិនសូវមានសមាជិកពេញកំលាំងការងារ ហើយទ្រព្យសម្បត្តិរបស់ពួកគេក៏មិនសូវមានតម្លៃដែរ ។ ហេតុនេះ ពួកគេងាយជួបនឹងបញ្ហាបន្ទាន់នានាដែលទាក់ទងនឹងវិបត្តិ និងបញ្ហាបន្ទាន់ៗ ។ ជាអាទិ៍ ស្ត្រីមេគ្រួសារច្រើនតែជួបបញ្ហាទុរ្ភិក្សជាងបុរសមេគ្រួសារ ដោយមិនគិតពីកម្មសិទ្ធិដីធ្លីធំ ឬតូចឡើយ ។ ភាពខុសគ្នានេះហើយដែលជាឧបស័គ្គនាំឱ្យស្ត្រីមិនអាចចូលរួមទទួលផលដោយស្មើភាពគ្នាពីកំណើនសេដ្ឋកិច្ចកម្ពុជា ។

ការស្រាវជ្រាវ PPA របស់ CDRI ក៏បង្ហាញផងដែរថា ស្ត្រីនៅក្នុងគ្រួសារក្រីក្រ និងគ្រួសារទ័លក្រនៅតែបន្តជួបប្រទះនឹងបញ្ហាសុខភាព ដែលរួមមានតាំងពីជម្ងឺងាយព្យាបាល ដែលបណ្តាលមកពីលក្ខខណ្ឌគ្មានអនាម័យក្នុងការរស់នៅ រហូតដល់ការព្យាបាលជម្ងឺមានតម្លៃខ្ពស់ៗពេក ហើយនិងអាកប្បកិរិយាស្ត្រីភេទមិនព្រមនិយាយឬយកបញ្ហាសុខភាពផ្ទាល់ខ្លួនមកពិភាក្សាដើម្បីរកជំនួយ ។ បញ្ហាសន្តិសុខផ្ទាល់ខ្លួនរបស់ស្ត្រី ក៏នៅតែបន្តចោទជាប្រចាំ ។ ឧទាហរណ៍ អំពើហិង្សានៅក្នុងគ្រួសារត្រូវបានគេកំណត់ថាជាកត្តារួមចំណែកធ្វើឱ្យមានភាពក្រីក្រកាន់តែច្រើនឡើងនៅក្នុងបណ្តាភូមិដែលបានស្រាវជ្រាវ ដោយសារការខូចខាតប្រាក់ចំណូល និងទ្រព្យសម្បត្តិ ធ្វើឱ្យបាត់លទ្ធភាព និងឱកាសរកប្រាក់ចំណូល ហើយនិងធ្វើឱ្យមានការលែងលះប្តីប្រពន្ធជាដើម ។ ស្ត្រីភេទភាគច្រើន ក៏ត្រូវបានគេរាយការណ៍មកដែរថា រងការចាប់រំលោភ និងចាប់បង្ខំ ដោយគ្មានការកែលំអ ឬសងជម្ងឺចិត្តណាមួយឱ្យដល់ជនរងគ្រោះឡើយ ។ ដោយសារការប្រថុយប្រថាននឹងភាពគ្មានសន្តិសុខបែបនេះហើយ ដែលឪពុកម្តាយភាគច្រើនសុខចិត្តឱ្យកូនស្រីខ្វះការសិក្សាអប់រំ ។

នៅកម្ពុជា បញ្ហាយេនឌ័រនៅក្នុងភាពក្រីក្រវាជាប់ទាក់ទិននឹងរាល់ផ្នែកសំខាន់ៗ ដូចជា ការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ដែលមានពិភាក្សានៅក្នុងឯកសារនេះ ជារួមមាន ការងារធ្វើ ការប្រើប្រាស់ និងការគ្រប់គ្រងធនធានធម្មជាតិ ការទទួលបានសេវាកម្មសង្គមសមស្រប និងអភិបាលកិច្ច ។ បញ្ហាដែលយេនឌ័រមានសក្តានុពលចំពោះការអភិវឌ្ឍន៍ និងអភិបាលកិច្ចទាំងនេះ ទាមទារឱ្យមានការពិភាក្សាច្រើនថែមទៀត ហើយនេះគឺជាផ្នែកមួយដ៏សំខាន់ដែល CDRI នឹងយកចិត្តទុកដាក់សំរាប់ការងារស្រាវជ្រាវជាលក្ខណៈគោលនយោបាយរបស់ខ្លួន ។

# ២. ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា

ដោយ ហ៊ីង វុត្ថា, ភីម រុនស៊ីណារិទ្ធិ, ប៊ុន ដូរីណា និងផាន់ ដាលីស

សេដ្ឋកិច្ចកម្ពុជាមានការរីកចំរើនខ្លាំងជាងការរំពឹងទុក ក្នុងឆ្នាំ២០០៥ ។ ផលិតផលក្នុងស្រុកសរុប (ផសស) ពិតកើនឡើង ១៣,៤% ក្នុងឆ្នាំ២០០៥ ប្រៀបធៀបនឹងកំនើន ១០,០% ក្នុងឆ្នាំ២០០៤ និងកំនើនមធ្យម ៨,២% ពីឆ្នាំ១៩៩៤-២០០៥ ។ កត្តាចំបងនៃការកលូតលាស់សេដ្ឋកិច្ចដ៏ឆាប់រហ័សនេះ គឺអាស្រ័យដោយកំនើនវិស័យកសិកម្មដែលមានសន្ទុះខ្លាំង ដោយសារអំណោយផលអាកាសធាតុជាមួយនឹងកំនើនវិស័យពីរទៀតគឺ វិស័យឧស្សាហកម្ម និងវិស័យសេវាកម្មដែលនៅរក្សាល្បឿនលឿនដដែល ។

## ១. កំណើនតាមវិស័យ

វិស័យកសិកម្មដែលមានចំនែក ៣១,៤%នៃ ផសស និងដែលបានផ្តល់ការងារ ៥៨% ដល់កំលាំងពលកម្មសរុប បានកើនឡើង ១៦,៦% ក្នុងឆ្នាំ២០០៥ ។ ផលិតផលដំណាំដែលលូតលាស់ខ្ពស់មានកំនើនស្មើ ២៨,០% ក្នុងឆ្នាំ២០០៥ ដោយសារមានទឹកភ្លៀងគ្រប់គ្រាន់ ធារាសាស្ត្រមានការកែលំអ និងការបង្កើនផ្ទៃដាំដុះ ។ ផលិតកម្មបសុសត្វ និងបក្សីកើនឡើង ៥,៨% ក្នុងឆ្នាំ២០០៥ ធៀបនឹងកំនើន ៤,៥% ក្នុងឆ្នាំ២០០៤ ។ ផលិតកម្មនេសាទ កើនឡើង ៥,៨% បន្ទាប់ពីថយចុះ ១,៧% ក្នុងឆ្នាំកន្លងទៅ ។ ក្នុងវិស័យកសិកម្មមានចំនុចដែលគួរឱ្យចាប់អារម្មណ៏មួយចំនួនដូចជាៈ ទី១ ទិន្នផលស្រូវស្មើ ២,៥តោនក្នុងមួយហិកតា ដែលនៅទាបជាងទិន្នផលប្រទេសជិតខាង ដែលមានលក្ខណៈកសិកម្ម និងអាកាសធាតុប្រហាក់ប្រហែលប្រទេសកម្ពុជា ។ រឿងនេះបញ្ជាក់ថា កម្ពុជានៅមានលទ្ធភាពដើម្បីបង្កើនផលស្រូវបានបន្ថែមទៀត ។ អាស្រ័យដោយប្រជាជនភាគច្រើនជាកសិករក្រីក្រ ការបង្កើនទិន្នផលស្រូវនឹងផ្តល់ផលវិជ្ជមានច្រើន ក្នុងការកាត់បន្ថយភាពក្រីក្រ ។ ទី២ ផលិតភាពបសុសត្វ និងបក្សីនៅមានកំរិតទាបបណ្តាលមកពីជំងឺឆ្លងផ្សេងៗ និងការប្រើប្រាស់បច្ចេកទេសដែលមានលក្ខណៈប្រពៃណី ។ កំរិតជីវភាពប្រជាជនមួយភាគធំអាចនឹងត្រូវបានប្រសើរជាងមុន ប្រសិនបើផលិតភាពបសុសត្វ និងបក្សីមានការកើនឡើង ហើយប្រព័ន្ធទីផ្សារត្រូវបានកែលំអ ។ ទី៣ ទោះបីទិន្នផលត្រី មានការកើនឡើងក្តី ក៏ប៉ុន្តែតំលៃបន្ថែមពិតនៃផលិតកម្មនេសាទមានការកើនឡើងទាបជាង ។ នេះបញ្ជាក់ថាបរិមាណត្រី ដែលមានគុណភាពខ្ពស់ និងតំលៃថ្លៃ មានការធ្លាក់ចុះក្នុងឆ្នាំ២០០៥ ។ ការកែលំអលើការគ្រប់គ្រងការនេសាទ និងការបំបាត់ការនេសាទខុសច្បាប់ មានសារៈសំខាន់ណាស់ដើម្បីធ្វើឱ្យមានចីរភាពនៃការនេសាទ និងការបង្កើនកំនើនសេដ្ឋកិច្ច ។

វិស័យឧស្សាហកម្មដែលមានចំនែក ២៨%នៃ ផសស និងដែលផ្តល់ការងារ ១៣,៥% ដល់កំលាំងពលកម្មសរុបកើនឡើង ១២,១% ក្នុងឆ្នាំ២០០៥ ប្រៀបធៀបនឹងកំនើន ១៦,៤% ក្នុងឆ្នាំ២០០៤ ។ ផលិតកម្មរ៉ែ កម្មន្តសាលភ្លើង ឧស្ម័ននិងទឹក និងសំណង់មានការកើនឡើង ២៤,៥% ៩,៧% ៤,៤% និង ២០,១% ក្នុងឆ្នាំ២០០៥ ។ នៅក្នុងវិស័យឧស្សាហកម្ម មានចំនុចមួយចំនួនដែលគួរឱ្យចាប់អារម្មណ៏រួមមានៈ ទី១ ទោះបីបច្ចុប្បន្ន ផលិតកម្មរ៉ែ មានចំនែកតិចតួចក្នុង ផសស សរុបក៏ដោយ គេមានការរំពឹងថា ផលិតកម្មរ៉ែនឹងផ្តល់វិភាគទានច្រើននាពេលអនាគត ។

ការស្រាវជ្រាវរុករករ៉ែក្នុងប្លុកទី១ នៃប្លុកទាំង៦ បានផ្តល់ទិន្នន័យដំបូងនូវចំនុះប្រេងកាតនៅពី ៤០០-៥០០លានធុង និងចំនុះឧស្ម័នពី ៦០-៩០ពាន់លានម៉ែត្រគូប ។ ប្រសិនបើផលិតកម្មនេះអូសបន្លាយរយៈពេល ២០-២៥ឆ្នាំ នោះចំនូលពីការលក់ប្រេងកាតនៅ និងឧស្ម័នអាចស្មើនឹង ៦-៧,៥ពាន់លានដុល្លារអាមេរិកក្នុងមួយឆ្នាំ គឺមានទំហំធំជាង ផសស ក្នុងឆ្នាំ២០០៥ ទៅទៀត ។ ទី២ វិស័យកាត់ដេរត្រូវបានសង្កេតឃើញថាជាវិស័យឈានមុខគេក្នុងការនាំចេញរបស់កម្ពុជា ហើយជាវិស័យមួយដែលជួយទ្រទ្រង់សេដ្ឋកិច្ចជាតិ ។ ប៉ុន្តែតាមការសិក្សារបស់ Omar Bargawi (2005) បានរកឃើញថា កម្ពុជាពុំទាន់បានទាញអត្ថប្រយោជន៍ឱ្យបានពេញលេញពីវិស័យកាត់ដេរនៅឡើយទេ ពីព្រោះកម្ពុជាធ្វើការនាំចូលវត្ថុធាតុដើមស្ទើរតែទាំងអស់សំរាប់វិស័យនេះ ហើយឧស្សាហកម្មមានតែសកម្មភាពកាត់និងដេរក្រណាត់ ដែលពុំសូវផ្តល់តំលៃបន្ថែម រឺប្រាក់ចំណេញខ្ពស់ឡើយ ។ ទី៣ ទោះបីផលិតកម្ម រ៉ែ ឧស្ម័ន និងទឹកមានការកើនឡើងក្តី ក៏វាពុំទាន់គ្រប់គ្រាន់ និងឆ្លើយតបចំពោះតំរូវការរបស់អតិថិជននៅឡើយ ។ តាមអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចប្រទេសកម្ពុជាក្នុងឆ្នាំ២០០៤ ប្រជាជនកម្ពុជា ប្រហែល ៨០% គ្មានភ្លើងអគ្គិសនី និងទឹក ហើយតំលៃរបស់វាមានកំរិតខ្ពស់ជាងប្រទេសជិតខាង ដែលធ្វើឱ្យតំលៃផលិតកម្មពិបាកប្រកួតប្រជែងក្នុងទីផ្សារអន្តរជាតិ ។

វិស័យសេវាកម្មដែលរួមចំនែក ៣៦% នៃ ផសស និងដែលផ្តល់ការងារ ២៧,៥% ដល់កំលាំងពលកម្មសរុប មានការលូតលាស់ ១២% ក្នុងឆ្នាំ២០០៥ ធៀបនឹងកំនើន ១១,៧% ក្នុងឆ្នាំ២០០៤ ។ សេវាកម្មសំខាន់ៗ រួមមានៈ ពាណិជ្ជកម្ម សណ្ឋាគារនិងភោជនីយដ្ឋាន ដឹកជញ្ជូននិងទូរគមនាគមន៍ សេវាកម្មពាណិជ្ជកម្មនិងអចលនវត្ថុ និងសេវាកម្មផ្សេងៗទៀត ។ កំនើននៃសេវាកម្មទាំងនេះស្មើនឹង ៨,៤% ១៧,៣% ១៣,១% ៦,៩% និង ១៧,៧% ក្នុងឆ្នាំ២០០៥ ។ ចំនុចដែលគួរឱ្យកត់សំគាល់ក្នុងវិស័យសេវាកម្មរួមមានៈ ទី១ ការសំរួលពាណិជ្ជកម្មផលិតផលកម្ពុជាគួរទទួលបាននូវការយកចិត្តទុកដាក់ជាបន្ថែមទៀត ពីព្រោះវាអាចជួយបង្កើតការងារដល់ប្រជាជននៅជនបទដែលសំបូរដោយជនក្រីក្រ ។ ទី២ ទោះបីជាចំនួនទេសចរមានកំនើនខ្លាំងគួឱ្យកត់សំគាល់ក៏ដោយ គេសង្កេតឃើញថាតំលៃបន្ថែមនៃភោជនីយដ្ឋាន មានកំនើនតែបន្តិចបន្តួចប៉ុណ្ណោះ ដែលជាការបញ្ជាក់ឱ្យដឹងថា ភោជនីយដ្ឋាន ក៏ពុំទាន់ទទួលអត្ថប្រយោជន៍ពេញលេញពីវិស័យទេសចរណ៍នៅឡើយ ។ ទី៣ វិស័យដឹកជញ្ជូន និងទូរគមនាគមន៍ដែលសំរួលដល់ពាណិជ្ជកម្ម ក៏ពុំទាន់មានការអភិវឌ្ឍន៍ទូលំទូលាយនៅឡើយ ។ ថ្លៃដឹកជញ្ជូន និងទូរគមនាគមន៍ ក៏មានតំលៃខ្ពស់ជាងប្រទេសជិតខាងដែរ ។ ដូចនេះ ការបង្កើតបណ្តាញដឹកជញ្ជូន និងទូរគមនាគមន៍ ដែលមានលក្ខណៈងាយស្រួលទូលំទូលាយ មានសុវត្ថិភាព និងមានប្រសិទ្ធភាពថ្លៃ ដែលអាចជួយជំរុញវិស័យពាណិជ្ជកម្ម និងការអភិវឌ្ឍន៍ជនបទទាមទារឱ្យមានការខិតខំបន្ថែមទៀត ។

សេដ្ឋកិច្ចកម្ពុជាមានកំនើនលឿនជាងការស្មានទុក ក្នុងឆ្នាំ២០០៥ ។ វិស័យកសិកម្មកើនខ្ពស់លើសពីការរំពឹងទុកហើយ វិស័យនេះបានរួមចំនែកយ៉ាងសំខាន់ដល់កំនើនសេដ្ឋកិច្ច ។ វិស័យឧស្សាហកម្ម និងសេវាកម្ម នៅតែជាម៉ាស៊ីនចំបងនៃកំនើន ។

ផសស ពិត ត្រូវបានរំពឹងថានឹងអាចកើនឡើងប្រហែល ៥% ក្នុងឆ្នាំ២០០៦ ។ កំនើននេះនឹងត្រូវបានជំរុញដោយគ្រប់វិស័យ តែនៅតែពឹងផ្អែកខ្លាំងទៅលើការនាំចេញសំលៀកបំពាក់ និងទេសចរណ៍ ។ វិស័យកសិកម្មអាចកើនឡើងប្រហែល ៦% ជាមួយនឹងដំណាំ និងបសុសត្វដែលជាផលិតកម្មនាំមុខក្នុងវិស័យនេះ ។ វិស័យឧស្សាហកម្មអាចនឹងកើនប្រហែល ១០% ។ វាយនភ័ណ្ឌ និងសំណង់ រំពឹងនឹងកើនឡើង ១២% និង ៨% ។ វិស័យសេវាកម្មសង្ឃឹមនឹងលូតលាស់ ៩% ក្នុងឆ្នាំ២០០៦ ។

## ២. តុល្យភាពពាណិជ្ជកម្ម

តុល្យភាពទូទៅរបស់កម្ពុជានៅឆ្នាំ២០០៥ មានអតិរេក ៥លានដុល្លារ រឺស្មើនឹង ០,១% នៃ ផសស ។ គណនីចរន្ត នៅឆ្នាំ២០០៥ មានឱនភាព ៥៩១លានដុល្លារ រីឯគណនីមូលធន មានអតិរេក ២៩៦លានដុល្លារ ។ ជាធម្មតា តុល្យភាព ទូទៅ តុល្យភាពគណនីចរន្ត និងតុល្យភាពគណនីមូលធនរបស់កម្ពុជានៅឆ្នាំ២០០៥ ស្ថិតក្នុងស្ថានភាពនឹងនរ ដែលមិន មានបញ្ហាចោទដល់សេដ្ឋកិច្ចទេ ។

ទោះបីជាតុល្យភាពទូទៅរបស់កម្ពុជា មើលទៅដូចជាមានស្ថិរភាព ដែលមិនមានបញ្ហាចោទធ្ងន់ធ្ងរដល់ សេដ្ឋកិច្ចក្តី ក៏កម្ពុជានៅតែពឹងផ្អែកលើជំនួយបរទេសសំរាប់ជាប្រភពហិរញ្ញវត្ថុសំខាន់ក្នុងការផ្តល់ហិរញ្ញប្បទានដល់ ឱនភាពគណនីចរន្ត ។ ក្នុងន័យនេះ រដ្ឋាភិបាលត្រូវការបង្កើតយុទ្ធសាស្រ្តដើម្បីស្វែងរកមធ្យោបាយ ដែលខ្លួនអាចយក ធនធានហិរញ្ញវត្ថុទៅផ្តល់ហិរញ្ញប្បទានដល់ឱនភាព ដោយមិនពឹងផ្អែកជំនួយបរទេស ។

ពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជា បានកើនឡើងយ៉ាងខ្លាំង ដោយសារកត្តាសំខាន់ៗ ដូចជាគោល នយោបាយសេដ្ឋកិច្ច និងពាណិជ្ជកម្ម មានលក្ខណៈសេរីជាងមុន និងការចូលរួមយ៉ាងសកម្មក្នុងកិច្ចព្រមព្រៀង ពាណិជ្ជកម្មបែបទ្វេភាគីក្នុងតំបន់ និងលើសកលលោក ។ ការនាំចេញសរុបនៅឆ្នាំ២០០៥ មានចំនួន ២.៩១០លាន ដុល្លារ រឺកើនឡើង ២៣% ធៀបនឹងឆ្នាំមុន ។ ផលិតផលសំលៀកបំពាក់ និងវាយនភ័ណ្ឌ នៅតែជាសមាសភាគនាំមុខ គេនៃការនាំចេញ ស្មើនឹង ៧៨% នៃការនាំចេញសរុប ។ ផលិតផលនាំចេញផ្សេងទៀតរួមមាន កៅស៊ូ ព្រៃឈើ និងផលិតផលជលផល ។ ការនាំចូលសរុបនៅឆ្នាំ២០០៥ មានចំនួន ៣.៩២៨លានដុល្លារ រឺ ៦៣% នៃ ផសស ។ ផលិតផលនាំចូលសំខាន់គឺ ម្ហូបអាហារ/ភេសជ្ជៈ/ថ្នាំពេទ្យ សំភារៈសាងសង់ វាយនភ័ណ្ឌ យានយន្ត និងថាមពល ។ ពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជារំពឹងថា នឹងកើនឡើងយ៉ាងខ្លាំងទៀតនៅប៉ុន្មានឆ្នាំខាងមុខនិងដើរតួកាន់តែ សំខាន់ថែមទៀតក្នុងសេដ្ឋកិច្ច ។ ការនាំចូលរំពឹងថានឹងកើនឡើងទៀតដែរដើម្បីឆ្លើយតបនឹងកំណើនតំរូវការ ដោយ សារតែកំណើនសេដ្ឋកិច្ចនិងកំណើនប្រជាជនខ្ពស់ ។ ការនាំចេញ ក៏រំពឹងថានឹងកើនឡើងដែរ ជាពិសេសផលិតផល សំលៀកបំពាក់ និងវាយនភ័ណ្ឌ ។ ដោយសារតែការផ្លាស់ប្តូរគោលនយោបាយអន្តរជាតិ ក្នុងការគ្រប់គ្រងពាណិជ្ជកម្ម សំលៀកបំពាក់ និងវាយនភ័ណ្ឌ កិច្ចខិតខំប្រឹងប្រែងបន្តបន្ទាប់ដើម្បីពង្រឹងផលិតភាព និងសមត្ថភាពប្រកួតប្រជែង របស់វិស័យកាត់ដេរ ក៏ដូចជាដើម្បីបង្កើនមុខទំនិញនាំចេញ គឺជាគោលនយោបាយត្រឹមត្រូវ ដែលនឹងជំរុញកំណើន សេដ្ឋកិច្ច ។

## ៣. ជញ្ជីងថវិកា ស្ថានភាពរូបិយវត្ថុនិងអតិផរណា

ឱនភាពជញ្ជីងថវិកាកម្ពុជាមានស្ថានភាពល្អប្រសើរ ក្នុងអំឡុងពេលបីឆ្នាំចុងក្រោយនេះ ។ ក្នុងឆ្នាំ២០០៥ ឱនភាព ជញ្ជីងថវិកា បានធ្លាក់ចុះមកត្រឹម ៨២៨ពាន់លានរៀល ឬស្មើនឹង ៣,៣% នៃផសស ។ ជាងនេះទៅទៀតចំណូល ក្នុងស្រុកបានកើនឡើង ២៣% ពីឆ្នាំ២០០៤ ឬស្មើនឹង ១០% នៃ ផសស ព្រមជាមួយនឹងការពង្រីកថវិកាចំណាយ របស់រដ្ឋ ១៥% ក្នុងឆ្នាំ២០០៥ ។ ក្នុងពេលនេះបើទោះបីជាមានឱនភាពលើជញ្ជីងថវិការដ្ឋ តែចំណូលក្នុងស្រុកកើន ឡើងលើសពីគំរោងចំណូលថវិការបស់រដ្ឋ ដោយការប្រមូលពន្ធកើនឡើងរហូតដល់១១០% ។

កម្ពុជាជាប្រទេសដែលពឹងផ្អែកទាំងស្រុងលើជំនួយបរទេស ។ នៅចុងឆ្នាំ២០០៥ បំណុលជាសាធារណៈ

មានចំនួន ៣,៤ លានដុល្លារ ដែលក្នុងនោះ ៣,២លានដុល្លារជាបំណុលបរទេស ។ ស្មើរតែ ២ភាគ៣ នៃបំណុលបរទេសកម្ពុជា បានជំពាក់សហរដ្ឋអាមេរិក ( ១៦២លានដុល្លារ) និងសហព័ន្ធរុស្ស៊ី ( ១៥២០លានដុល្លារ) ។

រូបិយវត្ថុទូទៅ (M2) ដែលរួមផ្សំដោយរូបិយវត្ថុក្រៅប្រព័ន្ធធនាគារ និងប្រាក់បញ្ញើរបស់អតិថិជននៅក្នុងប្រព័ន្ធធនាគារ កើនឡើង ១៦% ដល់ ៥០២៤,៩៣ពាន់លានរៀល ។ រូបិយវត្ថុទូទៅ (M2) ត្រូវបានរៀបចំឡើងដើម្បីការពារការកើតមានឡើងនៃអតិផរណាក្នុងកម្រិតខ្ពស់មួយ ។ ធនាគារមានតួនាទីសំខាន់ក្នុងការផ្តល់នូវរូបិយវត្ថុសំរាប់បរិស្ថានសេដ្ឋកិច្ច និងតាមរយៈសកម្មភាពរបស់គេ អាចជះឥទ្ធិពលទៅលើលំហូរនៃរូបិយវត្ថុ និងឥណទាន ក៏ដូចជាស្ថានភាពសេដ្ឋកិច្ចទាំងមូល ។ ក្នុងឆ្នាំនេះដែរ អត្រាប្តូរប្រាក់រៀលបន្តធ្លាក់ថ្លៃ ២,២% ទល់នឹងដុល្លារ ដោយប្តូរក្នុងតំលៃ ៤១០៣,៣ រៀល/ដុល្លារ ។ អត្រាអតិផរណាក្នុងទីក្រុងភ្នំពេញ កើនឡើងពី ៣,៩% ក្នុងឆ្នាំ២០០៤ ទៅដល់ ៥,៨% ក្នុងឆ្នាំ២០០៥ ។ អត្រាអតិផរណាក្នុងឆ្នាំ២០០៥ គឺបណ្តាលមកពីការកើនឡើងនៃថ្លៃប្រេង និងថ្លៃអាហារដោយរួមមានថ្លៃអង្ករជាដើម ។ម្យ៉ាងវិញទៀត តម្លៃនៃម្ហូបអាហារកើនឡើង គឺបណ្តាលមកពីភាពខ្សោះ និងជំងឺលើសត្វបក្សី ។ ការធ្លាក់ថ្លៃប្រាក់រៀល ជាហេតុបណ្តាលអោយថ្លៃទំនិញនាំចូលកើនឡើង ។ ទោះបីជាអត្រាអតិផរណាមិនបានជះឥទ្ធិពលលើកំនើនសេដ្ឋកិច្ច តែវាបានបង្កើតនូវការព្រួយបារម្ភអោយប្រជាជនដែលមានចំណូលទាប ។ បើសិនជាថ្លៃទំនិញជាមូលដ្ឋាន នៅតែបន្តឡើងថ្លៃ ស្ថានភាពសេដ្ឋកិច្ចរបស់ប្រជាជនក្រីក្រ នឹងជះឥទ្ធិពលដល់ដំណើរការអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា ។

## ៤. ការងារ និង ស្ថានភាពកម្មករងាយរងគ្រោះ

កម្ពុជាពឹងផ្អែកលើវិស័យកសិកម្ម ហើយវិស័យនេះបានទាញកំលាំងពលកម្មច្រើនលើសលុបបើធៀបនឹងផ្នែកផ្សេងៗ ។ កំនើនកំលាំងពលកម្មក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កើន ៣,៧% ពី ៤៥២០ពាន់នាក់នៅឆ្នាំ២០០៤ ទៅ ៤៦៥៥ពាន់នាក់នៅឆ្នាំ២០០៥ ។ ដោយឡែកឆ្នាំ២០០៥ កំនើនកំលាំងពលកម្មក្នុងវិស័យឧស្សាហកម្មកើនឡើងដល់ ១៩% គឺ ១០៥៩ពាន់នាក់ ឯផ្នែកសេវាកម្មកើន ១៨.១% ដល់ ២១៦៣ពាន់នាក់ក្នុងឆ្នាំ ២០០៥ ។

យោងតាមការអង្កេតរបស់អង្គការ CDRI ទៅលើកម្មករងាយរងគ្រោះចំនួន ១០ក្រុម កម្មករប្រហែល ៩០% ឆ្លើយថាបានចំណាកស្រុកបណ្តោះអាសន្នមកពីតំបន់ជនបទ ហើយពួកគេស្ទើរតែទាំងអស់រស់នៅក្រោមបន្ទាត់ភាពក្រីក្រ ដែលកំពង់តែប្រឈមមុខនឹងការរកចំណូលសំរាប់ចិញ្ចឹមក្នុងគ្រួសារ ។ នៅឆ្នាំ២០០៥ ចំណូលប្រចាំថ្ងៃរបស់កម្មករងាយរងគ្រោះទាំង ១០ក្រុម កើនឡើង ៧,៧% គឺ ៨៣០៤រៀល ធៀបនឹងឆ្នាំ២០០៤ ឯចំណូលកម្មករកាត់ដេរធ្លាក់ចុះ ៣.៥% ធៀបនឹងឆ្នាំ២០០៤ ។ ការអង្កេតបានបង្ហាញអោយឃើញថា ចំនួនកម្មករងាយរងគ្រោះទំនងជាកើនឡើងជាបន្តបន្ទាប់នៅទីក្រុងភ្នំពេញ ពិសេសប្រជាជនដែលគ្មានដីស្រែឬមានផលិតផលកសិកម្មមិនគ្រប់គ្រាន់សំរាប់ផ្គត់ផ្គង់ក្នុងគ្រួសារ ។ ម្យ៉ាងវិញទៀត ការចំណាកស្រុករបស់យុវជនពីជនបទមកភ្នំពេញ អាចនឹងកើនឡើង បន្ទាប់ពីពួកគេត្រូវបង្ខំចិត្តឈប់រៀនដោយសារជីវភាពក្នុងគ្រួសារជួបខ្វះខាត ។

# ៣. វិនិយោគផ្ទាល់បរទេស និង ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា

ដោយ ហ៊ីង វុត្ថា និង ទូត សុខផល្លី

## សេចក្តីសង្ខេប

មានការសិក្សាជាលក្ខណៈអន្តរជាតិមួយចំនួនបានបង្ហាញថា វិនិយោគផ្ទាល់បរទេសបានផ្តល់ផលប្រយោជន៍កាន់តែច្រើនឡើងដល់ប្រទេសកំពុងអភិវឌ្ឍន៍ហើយ ការចូលរួមចំណែករបស់វិនិយោគផ្ទាល់បរទេសក្នុងកំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍន៍ក៏កាន់តែលេចធ្លោ ។ ប្រសិនបើប្រទេសអ្នកទទួលមានគោលនយោបាយសមស្របនិងមានការអភិវឌ្ឍន៍ក្នុងកំរិតមួយ វិនិយោគផ្ទាល់បរទេសអាចផ្តល់ប្រយោជន៍ដល់ប្រទេសអ្នកទទួល តាមរយៈការផ្ទេរនិងការផ្សព្វផ្សាយបច្ចេកវិជ្ជា ការបង្កើតការងារ ការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ ការបង្កើនការនាំចេញនិងការប្រកួតប្រជែង ការពង្រឹងដល់ការអភិវឌ្ឍន៍សហគ្រាសនិងវិស័យឯកជនក្នុងស្រុក ព្រមទាំងការធ្វើឱ្យបរិយាកាសអាជីវកម្មបានប្រសើរឡើង ។ ទាំងអស់នេះជាកត្តាកំណត់គន្លឹះនៃកំណើនសេដ្ឋកិច្ច (OECD 2002) ។ ទោះយ៉ាងនេះក្តី គេសង្កេតឃើញថាពុំមានភស្តុតាងគ្រប់គ្រាន់ជាលក្ខណៈវិទ្យាសាស្ត្រ ដែលបង្ហាញអំពីកំរិត និងយន្តការ ដែលវិនិយោគផ្ទាល់បរទេសចូលរួមកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសអ្នកទទួលឡើយ ។

ប្រទេសកម្ពុជាបានស្រូបទាញវិនិយោគផ្ទាល់បរទេស បានច្រើនគួរឱ្យកត់សំគាល់ចាប់ពីដើមទសវត្សរ៍ឆ្នាំ១៩៩០ ។ ប្រទេសនេះបានធ្វើសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក ដោយធ្វើសេរីភាវូបនីយកម្មក្របខ័ណ្ឌពាណិជ្ជកម្ម និងវិនិយោគទុន។ ប្រទេសនេះក៏បានរក្សានូវលំនឹងម៉ាក្រូសេដ្ឋកិច្ច ពង្រឹងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និងក្របខ័ណ្ឌច្បាប់ ព្រមទាំងកែលំអបរិយាកាសអាជីវកម្មបានប្រសើរឡើង ។ ទាំងនេះជាការទាក់ទាញដល់ការអភិវឌ្ឍន៍វិស័យឯកជន និងវិនិយោគផ្ទាល់បរទេស ។ ជាក់ស្តែងក្នុងអំឡុងឆ្នាំ១៩៩៥-២០០៥ វិនិយោគផ្ទាល់បរទេសដែលបានអនុម័តរួចមានចំនួន ៧,៦ពាន់លានដុល្លារ និងបានចូលរួមយ៉ាងខ្លាំងដល់ការបង្កើតទុននៅក្នុងប្រទេស ។ វិនិយោគផ្ទាល់បរទេស បានដើរតួជាកត្តាកំណត់គន្លឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងទសវត្សរ៍កន្លងទៅ ។ ឧទាហរណ៍ វិស័យកាត់ដេរ និងទេសចរណ៍ដែលស្រូបទាញវិនិយោគផ្ទាល់បរទេសបានច្រើនជាងគេ បានក្លាយជាសមាសភាគសំខាន់នៃសេដ្ឋកិច្ចកម្ពុជា (World Bank 2006) ។

ដោយសារពុំមានការសិក្សាអំពីទំនាក់ទំនងរវាងវិនិយោគផ្ទាល់បរទេស និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា យើងបានធ្វើការសិក្សាមួយដើម្បីចាប់ផ្តើមស្វែងយល់អំពីការចូលរួមរបស់វិនិយោគផ្ទាល់បរទេសក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ដោយឆ្លើយសំនួរមួយចំនួន ដូចជា ១) តើវិនិយោគផ្ទាល់បរទេស ចូលរួមក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជាក្នុងកំរិតណា? ២) តើមានយន្តការអ្វីខ្លះ ដែលផលប្រយោជន៍ពីវិនិយោគផ្ទាល់បរទេសអាចចែកចាយដល់ជនក្រីក្រ? ៣) តើដើម្បីពង្រឹងទំនាក់ទំនងរវាងវិនិយោគផ្ទាល់បរទេស និងការកាត់បន្ថយភាពក្រីក្រ គេគួរធ្វើអ្វីខ្លះ? ដោយសារព័ត៌មានដើម្បីសិក្សាអំពីបញ្ហានេះមានកំរិត ការសិក្សានេះបានប្រើប្រាស់ឧបករណ៍វិភាគបែបសាមញ្ញ គឺ រីក្រេសិនសាមញ្ញដើម្បីបង្ហាញអំពីទំនាក់ទំនងរវាងវិនិយោគផ្ទាល់បរទេស ជាមួយការងារ និងកំណើនសេដ្ឋកិច្ច ។ សេចក្តីសង្ខេបនៃការសិក្សានេះមានបរិយាយដូចខាងក្រោម ។

ឥទ្ធិពលវិនិយោគផ្ទាល់បរទេសលើការកាត់បន្ថយភាពក្រីក្រ អាចពិនិត្យបានតាមរយៈទំនាក់ទំនងរវាង

វិនិយោគផ្ទាល់បរទេសទៅនឹងការងារ និងទៅនឹងកំណើនសេដ្ឋកិច្ច ។ តាមរយៈការងារវិនិយោគផ្ទាល់បរទេសមានឥទ្ធិពលកាត់បន្ថយភាពក្រីក្រដោយបង្កើតការងារ ដែលការងារនេះរួមមានៈ ការងារបង្កើតឡើងដោយសហគ្រាសរបស់វិនិយោគិនបរទេស ដែលហៅថាការងារដោយផ្ទាល់ និងការងារបង្កើតឡើងនៅតាមបណ្ដាសហគ្រាសដែលបំរើ ឬផ្ដល់វត្ថុធាតុដើមឱ្យសហគ្រាសរបស់វិនិយោគិនបរទេស ដែលហៅថាការងារដោយប្រយោល ។ តាមរយៈកំណើនសេដ្ឋកិច្ច វិនិយោគផ្ទាល់បរទេសអាចមានឥទ្ធិពលកាត់បន្ថយភាពក្រីក្រដោយប្រយោល ពោលគឺបង្កើតកំណើនសេដ្ឋកិច្ច ដែលជាកត្តាសំខាន់សំរាប់កាត់បន្ថយភាពក្រីក្រ ។

## កាត់បន្ថយភាពក្រីក្រតាមរយៈការងារ

វិនិយោគផ្ទាល់បរទេស គឺជាប្រភពផ្ដល់ការងារដ៏សំខាន់មួយនៅកម្ពុជាអស់រយៈពេលជាងមួយទសវត្សរ៍កន្លងមក ។ វិស័យមួយចំនួនដែលបានទទួលវិនិយោគផ្ទាល់បរទេសខ្ពស់ជាងគេដូចជា កាត់ដេរ និងទេសចរណ៍ បានបង្កើតការងារជាច្រើន ដោយផ្ទាល់និងដោយប្រយោល សំរាប់កម្មករដែលចេះតែកើនឡើង រួមទាំងពលករដែលចាកចេញពីវិស័យកសិកម្ម ។ លើសពីនេះ ការវិភាគរីគ្រេសិនសាមញ្ញអំពីវិនិយោគបរទេសផ្ទាល់និងការងារបានបង្ហាញថា ចំនួនការងារអាស្រ័យលើកំរិតវិនិយោគបរទេសផ្ទាល់ ។ ប៉ុន្តែលទ្ធភាពកាត់បន្ថយភាពក្រីក្រ ដែលវិនិយោគផ្ទាល់បរទេសបង្កើតបានតាមរយៈការបង្កើតការងារនោះ មានភាពផ្សេងៗគ្នាទៅតាមវិស័យ លក្ខណៈសម្បត្តិការងារ និងការចូលរួមរបស់អ្នកក្រ ។ ឧទាហរណ៍ វិនិយោគផ្ទាល់បរទេសក្នុងវិស័យកាត់ដេរចូលរួមក្នុងការកាត់បន្ថយភាពក្រីក្រដោយបង្កើតការងារចំនួន ៣២០.០០០នាក់ក្នុងឆ្នាំ២០០៥ ជាងនេះទៅទៀត ការសិក្សាមួយចំនួនបានបញ្ជាក់ថា វិស័យនេះបានជួយលើកកំពស់ជីវភាពប្រជាជននៅតាមជនបទបានមួយកំរិតដោយប្រយោល ។ ជាក់ស្ដែង លោក Lundstorom និង Ronnas (2006) បានរកឃើញថាវិស័យកាត់ដេរដើរតួនាទីសំខាន់ក្នុងការបង្កើតប្រាក់ចំណូល និងកាត់បន្ថយភាពក្រីក្រ ដោយបង្កើតការងារដល់នារីជនបទដែលជាក្រុមទន់ខ្សោយនិងងាយរងគ្រោះ ព្រមទាំងបង្កើតប្រាក់ចំណូលបន្ថែមដល់ក្រុមគ្រួសារនៅតាមជនបទ ។

## កាត់បន្ថយភាពក្រីក្រតាមរយៈកំណើនសេដ្ឋកិច្ច

វិនិយោគផ្ទាល់បរទេសបានដើរតួសំខាន់ក្នុងកំណើនសេដ្ឋកិច្ចនៅកម្ពុជា អស់រយៈពេលជាងមួយទសវត្សរ៍កន្លងមក ។ វិស័យកាត់ដេរ និងទេសចរណ៍ ដែលបានទទួលវិនិយោគផ្ទាល់បរទេសច្រើនជាងគេ បានក្លាយជាម៉ាស៊ីនសេដ្ឋកិច្ចដ៏សំខាន់ក្នុងរយៈពេលជាងមួយទសវត្សរ៍កន្លងមក ។ លើសពីនេះ ការវិភាគរីគ្រេសិនសាមញ្ញអំពីវិនិយោគបរទេសផ្ទាល់និងផលិតផលសរុបនៃវិស័យឧស្សាហកម្មនិងសេវាកម្មបានបង្ហាញថា កំណើនផលិតផលសរុបនៃវិស័យទាំងពីរអាស្រ័យនឹងបរិមាណវិនិយោគផ្ទាល់បរទេសដែលអនុម័តរួចក្នុងវិស័យទាំងពីរ ។

ប៉ុន្តែបើយោងតាមការសិក្សាមួយចំនួន គេសង្កេតឃើញថា កំណើនសេដ្ឋកិច្ចនៅកម្ពុជាក្នុងមួយទសវត្សរ៍កន្លងមក បានចូលរួមកាត់បន្ថយភាពក្រីក្រក្នុងកំរិតតិចតួច ។ តាមការសិក្សា (World Bank 2006) គេសង្កេតឃើញថា ក្នុងទសវត្សរ៍កន្លងមក កំណើនផលិតផលសរុបក្នុងមនុស្សម្នាក់ៗនៅកម្ពុជាមានជាមធ្យម ៤,១% ក្នុងមួយឆ្នាំ ឯកំរិតកាត់បន្ថយភាពក្រីក្រមានជាមធ្យម ១ ទៅ ១,៥% ក្នុងមួយឆ្នាំ ដែលជាកំរិតទាបជាងមធ្យមភាគអត្រាកាត់បន្ថយភាពក្រីក្រនៃកំណើនសេដ្ឋកិច្ចក្នុងពិភពលោក ។ ជាលទ្ធផល គេអាចសន្និដ្ឋានថា កំណើនសេដ្ឋកិច្ចខ្ពស់របស់កម្ពុជា គួរតែអាចចូលរួមកាត់បន្ថយភាពក្រីក្របានក្នុងកំរិតមួយខ្ពស់ជាងក្នុងកំរិតបច្ចុប្បន្ន ដូចនេះកំណើន

សេដ្ឋកិច្ចក្នុងឆ្នាំកន្លងទៅពុំមានលក្ខណៈអំណោយផលច្រើនដល់អ្នកក្រទេ ។

មូលហេតុដែលវិនិយោគផ្ទាល់បរទេស ចូលរួមកាត់បន្ថយភាពក្រីក្រតាមរយៈកំណើនសេដ្ឋកិច្ចក្នុងកំរិតទាបនោះ គឺដោយសាររបាយវិនិយោគផ្ទាល់បរទេស ដែលកម្ពុជាទទួលបានក្នុងរយៈពេលជាងមួយទសវត្សរ៍កន្លងមកមានលក្ខណៈប្រមូលផ្តុំច្រើនក្នុងវិស័យមួយចំនួន ។ គេសង្កេតឃើញវិស័យកសិកម្មដែលស្រូបទាញកំលាំងពលកម្មដល់ទៅ ៧០% នៃកំលាំងពលកម្មសរុបនោះ ទទួលបានបរិមាណវិនិយោគផ្ទាល់បរទេសដែលបានអនុម័តរួចសរុបចំនួនតែ ៤០៣លានដុល្លារប៉ុណ្ណោះក្នុងអំឡុងឆ្នាំ១៩៩៥-២០០៥ បើធៀបនឹង ៣.៤៨៨លានដុល្លារក្នុងវិស័យឧស្សាហកម្ម និង៣.៩៣២លានដុល្លារក្នុងវិស័យសេវាកម្ម ។ គួរឱ្យកត់សំគាល់ដែរថា ចំណែកខ្លះនៃវិនិយោគដែលបានអនុម័តរួច មិនត្រូវបានអនុវត្ត ហើយអត្រាភាគរយនៃវិនិយោគដែលមិនអនុវត្តមានជាមធ្យមមានខ្ពស់ដល់ទៅ ៧៨% នៃវិនិយោគដែលបានអនុម័តរួច ។

សរុបសេចក្តីមក វិនិយោគផ្ទាល់បរទេសបានចូលរួមយ៉ាងខ្លាំងដល់កិច្ចអភិវឌ្ឍន៍ជាតិ ដូចជាតាមរយៈការបង្កើតការងារ និងកំណើនសេដ្ឋកិច្ចជាតិ ។ ប៉ុន្តែលទ្ធភាពដែលវិនិយោគផ្ទាល់បរទេសអាចចូលរួមកាត់បន្ថយភាពក្រីក្រនៅមានកំរិតដោយសារមូលហេតុមួយចំនួន ដូចជា ១) ការងារដែលបង្កើតដោយវិនិយោគផ្ទាល់បរទេសមានចំនួនមិនគ្រប់គ្រាន់ ដែលមិនអាចស្រូបទាញកំណើនកំលាំងពលកម្មបានទាំងស្រុង ។ ២) ការងារភាគច្រើនបានប្រមូលផ្តុំនៅតាមតំបន់ប្រជុំជន និងទាមទារនូវជំនាញនិងចំណេះដឹងដែលប្រជាជនក្រីក្រខ្វះខាតនិងពុំមានលទ្ធភាពទទួលបាន ។ ៣) វិនិយោគផ្ទាល់បរទេសមានច្រើនសន្ធឹកក្នុងវិស័យឧស្សាកម្ម និងសេវាកម្ម ឯប្រជាជនភាគច្រើននិងជាពិសេសជនក្រីក្រប្រកបរបរកសិកម្ម ។

ដើម្បីពង្រឹងទំនាក់ទំនងរវាងវិនិយោគផ្ទាល់បរទេសនិងការកាត់បន្ថយភាពក្រីក្រ យើងគួរពិចារណាលើវិធានការមួយចំនួនដូចជាៈ ពង្រឹងកំណើនសេដ្ឋកិច្ច តាមរយៈការទាក់ទាញវិនិយោគផ្ទាល់បរទេសបន្ថែមទៀតដោយផ្តល់នូវក្របខ័ណ្ឌច្បាប់ទំលាប់គ្រប់គ្រាន់ អភិបាលកិច្ចល្អ ប្រសិទ្ធភាពស្ថាប័នរដ្ឋនិងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច-សង្គម ។ រដ្ឋាភិបាលគួរចាត់វិធានការដើម្បីបែងចែកផលប្រយោជន៍ពីកំណើនសេដ្ឋកិច្ចដល់ជនក្រីក្រ ។ ឧទាហរណ៍គោលនយោបាយពន្ធអាចជាឧបករណ៍ប្រកបដោយថាមពលមួយ ដែលអាចពង្រឹងសមធម៌ក្នុងកំណើនសេដ្ឋកិច្ច ។ បន្ទាប់មក គេអាចផ្តោតលើការទាក់ទាញវិនិយោគផ្ទាល់បរទេសដែលមានឥទ្ធិពលកាត់បន្ថយភាពក្រីក្រខ្ពស់ ដោយគិតអំពីអត្ថប្រយោជន៍ប្រៀបធៀបរបស់កម្ពុជា ។វិស័យដែលគេអាចពិចារណានិងធ្វើការសិក្សាអំពីសមត្ថភាពប្រកួតប្រជែងបន្ថែម រួមមាន កសិពាណិជ្ជកម្ម និងការវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេស ដោយនៅតែបន្តគាំទ្រទាក់ទាញវិនិយោគផ្ទាល់បរទេសលើវិស័យដែលប្រើប្រាស់កំលាំងពលកម្មច្រើន ដូចជា វិស័យកាត់ដេរជាដើម ។

ជាសេចក្តីសន្និដ្ឋាន ចំពោះបណ្តាប្រទេសដូចប្រទេសកម្ពុជា ដែលខ្វះការសន្សំនិងវិនិយោគក្នុងស្រុក វិនិយោគផ្ទាល់បរទេសជាការចាំបាច់ណាស់ក្នុងការអភិវឌ្ឍន៍និងកំណើនសេដ្ឋកិច្ច ។ ទោះបីជាវិនិយោគផ្ទាល់បរទេសមានឥទ្ធិពលកាត់បន្ថយភាពក្រីក្របានតែក្នុងកំរិតមួយក្តី វិនិយោគផ្ទាល់បរទេសបានចូលរួមក្នុងកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍន៍វិស័យឯកជន ដែលជាធាតុផ្សំសំខាន់ក្នុងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ។ ជាងនេះទៅទៀត វិនិយោគផ្ទាល់បរទេស អាចបំរើជាចំណុចប្រសព្វសំរាប់ប្រមូលផ្តុំធនធានដើម្បីសំរេចបាននូវគោលដៅកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។

# ៤. ចំណូលពីធនធានធម្មជាតិអាចជាគុណប្រយោជន៍ផង និងជាគុណវិបត្តិផងក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច

ដោយ សុខ ស៊ីណា

ក្នុងជាង ៦០ឆ្នាំចុងក្រោយនេះ មានការសិក្សាជាច្រើនស្តីពីសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ ។ នៅរវាងឆ្នាំ១៩៥០ និង ១៩៦០ ការសិក្សាច្រើនតែផ្តោតលើកង្វះដើមទុនផលិតកម្ម (capital shortage) ដែលគេយល់ថាជាមូលហេតុរាំងស្ទះដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចនៃប្រទេសក្រីក្រទាំងឡាយ ។ ទ្រឹស្តីអភិវឌ្ឍន៍នាសម័យនោះ បានចង្អុលបង្ហាញថា ដើម្បីចេញឱ្យផុតពីភាពក្រីក្របាន ប្រទេសទាំងនោះត្រូវតែបង្កើនដើមទុនផលិតកម្មឱ្យបានច្រើន ។

ក៏ប៉ុន្តែការសិក្សាជាច្រើននៅប៉ុន្មានឆ្នាំចុងក្រោយនេះបានបង្ហាញចំនុចគួរឱ្យចាប់អារម្មណ៍ថា ប្រទេសសំបូរធនធានធម្មជាតិច្រើនមានការលូតលាស់យឺតយ៉ាវ បើទោះជាប្រទេសទាំងនោះ បានទទួលប្រាក់ចំណូលច្រើនពីការនាំចេញផលិតផលពីធម្មជាតិ ដូចជា រ៉ែប្រេងកាត រ៉ែមាសពេជ្រ និងរ៉ែមានតំលៃដទៃទៀត ។ ភាគច្រើននៃប្រទេសមានធនធានធម្មជាតិច្រើនសន្ធឹកសន្ធាប់ តែងមានកំណើនសេដ្ឋកិច្ច ទាបជាងប្រទេសពុំមានធនធានធម្មជាតិ ។ អត្ថបទដ៏ខ្លីនេះ ព្យាយាមឆ្លើយនឹងសំនួរថា តើមូលហេតុអ្វីខ្លះដែលបណ្តាលឱ្យប្រទេសមានធនធានធម្មជាតិដ៏ច្រើននោះ បែរជាមានសេដ្ឋកិច្ចលូតលាស់យឺតទៅវិញ ។ អត្ថបទនេះ ក៏ផ្តល់ជាអនុសាសន៍មួយចំនួនសំរាប់ទប់ស្កាត់ផលអាក្រក់ទាំងឡាយទាក់ទិននឹងចំណូលពីធនធានធម្មជាតិ ជាពិសេសសំរាប់ប្រទេសកម្ពុជាដែលនឹងចាប់ផ្តើមធ្វើប្រតិបត្តិការបូមយកប្រេងកាតនៅឆ្នាំ២០០៨ រឺ ២០០៩ ខាងមុខ ។

ផលអវិជ្ជមានចំបងបំផុតនៃធនធានធម្មជាតិ គឺផលប៉ះពាល់មួយដែលអ្នកសេដ្ឋកិច្ចហៅថា ជំងឺហូឡង់ (Dutch Disease) ។ ជំងឺហូឡង់នេះកើតមាននៅរវាងឆ្នាំ១៩៦០ និង ១៩៧០ នៅពេលដែលប្រទេសហូឡង់បានទទួលប្រាក់ចំណូលសន្ធឹកសន្ធាប់ពីការនាំចេញប្រេងកាត និងឧស្ម័នធម្មជាតិ ។ ជាទូទៅជំងឺហូឡង់នេះអាចពន្យល់ដោយសង្ខេបថា ជាការធ្លាក់ចុះផលិតកម្មក្នុងស្រុកផ្សេងៗដែលបំរើដល់ការនាំចេញ ។ ការធ្លាក់ចុះនេះមានមូលហេតុពីរយ៉ាង ។ ទីមួយ គឺបណ្តាលមកពីកំណើនតំលៃផលិត ដោយសារការចាយវាយចំណូលប្រេងដ៏សន្ធឹកសន្ធាប់នេះ ។ ទីពីរ គឺបណ្តាលមកពីការឡើងថ្លៃរូបិយវត្ថុក្នុងស្រុក ធៀបនឹងរូបិយវត្ថុក្រៅស្រុក (appreciation of domestic currency) ដែលធ្វើឱ្យផលិតផលនាំចេញ ឡើងថ្លៃនៅលើទីផ្សារអន្តរជាតិ ។ ដូច្នេះទំហំនៃការនាំចេញអាចស្រុតចុះ ហើយប្រទាញអោយផលិតកម្មក្នុងស្រុកស្រុតចុះដែរ ។ ជាទូទៅ ផលអវិជ្ជមានទាំងនេះបានកើតឡើងស្ទើរក្នុងគ្រប់ប្រទេសទាំងអស់ដែលមាននាំចេញផលិតផលធម្មជាតិដ៏ច្រើន ។

ការសិក្សាជាច្រើនបានរកឃើញថា ប្រទេសសំបូរធនធានធម្មជាតិ ច្រើនតែមានភាពមិនប្រក្រតីក្នុងការគ្រប់គ្រងធនធានទាំងនោះ ។ ឧទាហរណ៍ប្រទេសនីហ្សេរីយ៉ា (Nigeria) សំបូររ៉ែប្រេងកាត តែត្រូវបានបំផ្លាញដោយអំពើពុករលួយក្នុងនេះប្រាក់ចំនូលពីប្រេងកាតត្រូវបានបែងចែកក្នុងចំណោមអ្នកនយោបាយនៃប្រទេសនោះ ។ ម្យ៉ាងវិញទៀត ប្រទេសសំបូរធនធានធម្មជាតិ ច្រើនតែខកខានក្នុងការលើកស្ទួយផ្នែកអប់រំ ដែលជាកត្តាសំខាន់បំផុតសំរាប់ការអភិវឌ្ឍន៍ប្រទេសនីមួយៗ ។ បច្ចុប្បន្ន ផ្នែកអប់រំពុំគ្រាន់តែជាមធ្យោបាយជួយកាត់បន្ថយភាពក្រីក្រប៉ុណ្ណោះទេ ប៉ុន្តែជាចលករមួយដ៏សំខាន់ក្នុងការធានាចីរភាពនៃកំណើនសេដ្ឋកិច្ច ។ ប្រទេសដែលមានធនធានធម្មជាតិច្រើនតែងមានការចំណាយតិចទៅលើការអប់រំ ប៉ុន្តែមានចំណាយច្រើនទៅលើសន្តិសុខសង្គម ។ គេបានសន្និដ្ឋានថា ប្រទេសសំបូរធនធានធម្មជាតិច្រើន ច្រើនតែជាប្រទេសមាននិន្នាការប្រកាន់របបបែបផ្តាច់ការ ជាជាង

អនុវត្តរបបប្រជាធិបតេយ្យ ។ ការសន្និដ្ឋាននេះ ផ្អែកលើការសិក្សា មួយចំនួនដែលបង្ហាញថា របបប្រជាធិបតេយ្យមានកំណើនសេដ្ឋកិច្ចខ្ពស់ជាងរបបផ្តាច់ការ ។ ប៉ុន្តែ ការសន្និដ្ឋានបែបនេះ ពុំសូវសុក្រិតទេ ពីព្រោះប្រទេសប្រកាន់របបផ្តាច់ការមួយចំនួន ក៏មានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សំគាល់ដែរ ឧទាហរណ៍ដូចជា ឥណ្ឌូនេស៊ីនៅក្រោមការដឹកនាំរបស់លោកប្រធានាធិបតី ស៊ូហាតូ ជាដើម ។ ទោះយ៉ាងនេះក្តី អ្នកសិក្សាបានឯកភាពគ្នាថា តំលាភាព ការទទួលខុសត្រូវ និងការគោរពច្បាប់ គឺជាកត្តាសំខាន់បំផុតសំរាប់កំណើនសេដ្ឋកិច្ចហើយកត្តាទាំងបីនេះច្រើនកើតមាននៅក្នុងប្រទេសដែលមាននិន្នាការបែបប្រជាធិបតេយ្យ ។

ការសិក្សាមួយចំនួនទៀតបង្ហាញថា ប្រទេសសំបូរធនធានធម្មជាតិ តែងមានវិនិយោគក៏រិតទាបដែលធ្វើឱ្យកំណើនសេដ្ឋកិច្ចមានក៏រិតទាបដែរ ហើយមូលហេតុចំបងគឺ អំពើពុករលួយដែលជះឥទ្ធិពលអវិជ្ជមានទៅលើកំណើនសេដ្ឋកិច្ច ។ វិនិយោគក្នុងវិស័យសាធារណៈពុំមានប្រសិទ្ធភាពទេ ។ ដូច្នេះប្រទេសសំបូរធនធានធម្មជាតិនៅតែខ្វះខាតដើមទុនផលិតកម្មដដែល ទោះបីជាប្រទេសនោះទទួលបានចំណូលដ៏ច្រើនពីធនធាននេះក្តី ។

យោងតាមការសិក្សាខ្លះទៀត ធនធានធម្មជាតិអាចជាកត្តាមួយនាំឱ្យមានសង្គ្រាមស៊ីវិល និងធ្វើឱ្យលិចលង់សេដ្ឋកិច្ចប្រទេសនោះ ។ គេសង្កេតឃើញប្រទេសមួយចំនួននៅអាហ្វ្រិក ដូចជា អង់ហ្គូឡា (Angola) និង ឆាត (Chad) មានកើតសង្គ្រាមរ៉ាំរ៉ៃរាប់ឆ្នាំ និងមហន្តរាយសេដ្ឋកិច្ចដ៏ធំសំបើម ។ ពួកបះបោរព្យាយាមដណ្តើមគ្រប់គ្រងតំបន់ដែលសំបូរប្រេងកាត និងធនធានធម្មជាតិសំខាន់ៗឯទៀត ដូចជា មាស និងពេជ្រ ជាដើម ។ ប៉ុន្តែធនធានធម្មជាតិគ្រាន់តែជាមូលហេតុមួយក្នុងចំណោមមូលហេតុជាច្រើននៃសង្គ្រាមប៉ុណ្ណោះ ។ ការសិក្សាបង្ហាញថា ប្រទេសដែលមានរចនាសម្ព័ន្ធរដ្ឋខ្សោយ និងសំបូរទៅដោយអំពើពុករលួយ តែងងាយនឹងធ្លាក់ចូលទៅក្នុងសង្គ្រាមស៊ីវិល ដោយសារការមិនសប្បាយចិត្តពីក្រុមប្រឆាំង ។ ចំពោះប្រទេសដែលមានធនធានធម្មជាតិច្រើន ហើយបានប្រើប្រាស់ប្រភពចំនូលទាំងនេះសំរាប់ពង្រឹងផ្នែកសន្តិសុខ ប្រទេសនោះច្រើនតែមានស្ថិរភាពនយោបាយល្អ ។

សំរាប់ប្រទេសកម្ពុជា ចំណូលពីរ៉ែប្រេងកាតអាចជាមធ្យោបាយដ៏សំខាន់សំរាប់កាត់បន្ថយការពឹងផ្អែកលើជំនួយ និងការខ្ចីប្រាក់ពីបរទេស ។ ប៉ុន្តែដូចបានរៀបរាប់ពីខាងដើម ចំណូលដ៏សន្ធឹកសន្ធាប់នៃរ៉ែប្រេងកាត ក៏អាចបង្កបញ្ហាដល់សេដ្ឋកិច្ចរបស់កម្ពុជាបានដែរ ។ ផលអវិជ្ជមានដែលទំនងនឹងកើតមាននៅពេលបូមយករ៉ែប្រេងកាតដែលនាំឱ្យមានលំហូររូបិយប័ណ្ណចូលមកក្នុងប្រទេស គឺការឡើងថ្លៃទំនិញក្នុងស្រុក ដូចជាផ្នែកសំណង់ និងសេវាកម្មផ្សេងៗជាដើម ។ ការឡើងថ្លៃនេះ នឹងធ្វើឱ្យវត្ថុធាតុដើមឡើងថ្លៃ ។ ទំនិញនាំចេញមួយចំនួន ដូចជា ស្រូវ អង្ករជាពិសេស ទំនិញនៃឧស្សាហកម្មកាត់ដេរ ក៏នឹងត្រូវឡើងថ្លៃ ហើយបង្កបញ្ហាដល់ការប្រកួតប្រជែង ។ ខណៈដែលរូបិយប័ណ្ណនឹងត្រូវប្រមូលយកបានពីការនាំចេញប្រេងកាត ប្រាក់រៀលនឹងអាចឡើងថ្លៃ ហើយធ្វើឱ្យថយចុះការនាំចេញទំនិញជាពិសេសមុខទំនិញដែលប្រើកំលាំងពលកម្មច្រើន ដូចជាផ្នែកកាត់ដេរជាដើម ។ ទំនិញផ្នែកនេះច្រើនតែពឹងផ្អែកលើតំលៃដើម គឺបានន័យថា តំលៃជាកត្តាកំណត់ភាពខ្លាំង រឺក៏ភាពខ្សោយនៃការប្រកួតប្រជែង ។ ដូច្នេះការឡើងថ្លៃទំនិញនាំចេញ នឹងធ្វើឱ្យផលិតកម្មក្នុងផ្នែកនេះស្រុតចុះវិញ ។

ដីធ្លីផ្ទះ និងអគារអាចឡើងថ្លៃ ប្រសិនបើចំណូលពីប្រេងកាតត្រូវបានចាយវាយទៅលើផ្នែកនេះ ។ ការឡើងថ្លៃដីធ្លីអាចបង្កការលំបាកដល់វិនិយោគទាំងឡាយណាដែលប្រើដីធំ ដូចជាកសិឧស្សាហកម្ម និងកសិកម្ម ។ ម្យ៉ាងទៀត ទំនិញក្នុងស្រុកក៏អាចឡើងថ្លៃ ប្រសិនបើចំណូលពីប្រេងកាតត្រូវបានចាយ ទៅលើមុខចំណាយជាប្រចាំដូចជា ការតំលើងប្រាក់បៀវត្សរ៍ ។ ប៉ុន្តែក៏រិតនៃការឡើងថ្លៃទំនិញ អាស្រ័យទៅលើអត្រាកំណើនប្រាក់បៀវត្សរ៍ ។ ដូចនេះ ការតំលើងប្រាក់បៀវត្សរ៍សន្សឹមៗអាចជួយសំរាលការឡើងថ្លៃទំនិញបាន ។ ទោះយ៉ាងនេះក្តី ជាទូទៅតំលៃទំនិញវាអាស្រ័យទៅលើទំហំនៃការផ្គត់ផ្គង់ (supply side) និងតំរូវការ (demand side) ។ ដោយសារមាន

ចំណូលពីប្រេងកាត ទំហំតំរូវការអាចកើនឡើង ដូច្នេះប្រសិនបើការផ្គត់ផ្គង់ពុំមានតុល្យភាពនឹងតំរូវការទេ ទំនិញក្នុងស្រុកអាចនឹងឡើងថ្លៃ ។ គេអាចដោះស្រាយបញ្ហានេះបាន ដោយបង្កើនការនាំចូលទំនិញពីបរទេសរឺក៏គ្រប់គ្រងតំរូវការឱ្យមានកំនើនសន្សឹមៗជៀសវាងភាពគំហុក ។ បទពិសោធន៍នៃប្រទេសមួយចំនួន ដូចជាឥណ្ឌូនេស៊ីជាដើម គឺរដ្ឋបានជួយផ្ទុងផ្តើមផលិតកម្មក្នុងស្រុក និងការពារផ្នែកនេះដោយយកចំណូលពីប្រេងកាតមកចាយវាយ ។ នៅពេលផ្នែកនេះអាចឈរជើងដោយខ្លួនឯងបានហើយ ប្រទេសនោះអាចជៀសផុតពីផលអវិជ្ជមាននៃជំងឺហូឡង់ ។

## អនុសាសន៍

ចំណូលពីធនធានធម្មជាតិអាចធ្វើឱ្យប្រទេសមួយរុងរឿងបាន ប៉ុន្តែក៏អាចបំផ្លាញប្រទេសនោះដែរ ប្រសិនបើពុំមានវិធានការជាក់លាក់សំរាប់គ្រប់គ្រង និងតាមដានផលអវិជ្ជមាននានា ។ ប្រទេសមួយចំនួន ដូចជា ន័រវែ កាណាដា ឥណ្ឌូនេស៊ី និងហូឡង់ ជាដើម អាចទាញយកផលប្រយោជន៍ពីធនធានធម្មជាតិបានយ៉ាងពិតប្រាកដ ។ ខាងក្រោមនេះ គឺជាវិធានការណ៍មួយចំនួនសំរាប់ទប់ស្កាត់ផលអវិជ្ជមានៈ

ទប់ស្កាត់ការឡើងថ្លៃរូបិយវត្ថុក្នុងស្រុក ។ សេដ្ឋវិទូខ្លះ ដូចជា Stiglitz (2004) បានផ្តល់យោបល់ថា គួរទុករូបិយប័ណ្ណដែលប្រមូលបាននោះនៅឯក្រៅស្រុកដើម្បីទប់ស្កាត់កុំឱ្យរូបិយវត្ថុក្នុងស្រុកឡើងថ្លៃ ។ ប៉ុន្តែគំនិតនេះមិនសុក្រិតទេ ពីព្រោះបើធ្វើដូច្នោះ រូបិយប័ណ្ណទាំងនោះនឹងបំរើប្រយោជន៍ប្រទេសដទៃ ជាជាងបំរើប្រយោជន៍ក្នុងស្រុក ។ គេអាចនាំយករូបិយប័ណ្ណដែលប្រមូលបាន មកប្រើប្រាស់ក្នុងស្រុក ដើម្បីជំរុញកំណើនសេដ្ឋកិច្ច ក៏ប៉ុន្តែត្រូវគោរពតាមគោលការណ៍តំលាភាព គណនេយ្យភាព និងប្រសិទ្ធភាព ។ រូបិយប័ណ្ណទាំងនោះ អាចចាយវាយសំរាប់ការវិនិយោគទៅលើធនធានផលិតកម្ម (capital investment) ដូចជា ការកសាងផ្លូវ សាលារៀន មន្ទីរពេទ្យសំរាប់ធានាកំណើនសេដ្ឋកិច្ចឱ្យមានចីរភាព ។ ប្រទេសមានទំហំសេដ្ឋកិច្ចតូច ដូចជាកម្ពុជាយើងមានរចនាសម្ព័ន្ធផលិតកម្មពុំទាន់រឹងមាំ ដូច្នេះកំណើនដ៏គំហុកនៃវិនិយោគអាចនាំឱ្យចោទបញ្ហាខាងអតិផរណា ពីព្រោះផលិតកម្មក្នុងស្រុកត្រូវការរយៈពេលមួយ ដើម្បីឆ្លើយតបទៅនឹងតំរូវការ ។ ដូចនេះ ការវិនិយោគសន្សឹមៗ រឺក៏ការនាំចូលផលិតផលពីបរទេសសំរាប់ផលិតកម្ម អាចបន្ថយសន្ទុះឡើងថ្លៃនៃទំនិញបាន ។ ទំហំវិនិយោគសាធារណៈទំនងជាមិនរុញច្រានរឺកាត់បន្ថយវិនិយោគឯកជន ដូចជាការគិតគូររបស់សេដ្ឋវិទូខ្លះនោះទេ ពីព្រោះក្នុងប្រទេសកំពុងអភិវឌ្ឍន៍នៅមានធនធានច្រើនណាស់ ដែលពុំទាន់យកមកប្រើប្រាស់ ដូចជា កំលាំងពលកម្ម និងដីធ្លីជាដើម ។ ម្យ៉ាងវិញទៀត វិនិយោគសាធារណៈទៅលើវិស័យហេដ្ឋារចនាសម្ព័ន្ធ ដូចជាផ្លូវទឹក និងអគ្គិសនី ជាដើម រឺតែជួយទាក់ទាញផ្នែកឯកជនឱ្យមានសកម្មភាពផលិតកាន់តែខ្លាំង ពីព្រោះវាជួយបញ្ចុះតំលៃដើម ។

## សេចក្តីសន្និដ្ឋាន

ប្រទេសក្រីក្រទាំងឡាយ តែងចង់បានចំណូលពីធនធានធម្មជាតិ ប៉ុន្តែសេដ្ឋវិទូបានពញ្ញាក់អារម្មណ៍ថា ចំណូលប្រភេទនេះអាចធ្វើឱ្យសេដ្ឋកិច្ចស្រុតចុះ ជាជាងធ្វើឱ្យសេដ្ឋកិច្ចកើនឡើង ។ ប្រទេសខ្លះនៅតែក្រ ទោះបីទាញផលបានច្រើនពីធនធានធម្មជាតិដ៏សំបូរក៏ដោយ ។ មូលហេតុចំបងដែលនាំឱ្យធនធានធម្មជាតិមិនអាចជួយជំរុញកំណើនសេដ្ឋកិច្ចបាន គឺជំងឺហូឡង់ និងកង្វះតំលាភាពក្នុងការគ្រប់គ្រងចំណូល ។

ការពង្រឹងតំលាភាពចំណូលនិងប្រសិទ្ធភាពចំនាយរួមទាំងការអនុវត្តន៍នយោបាយរូបិយវត្ថុនិងហិរញ្ញវត្ថុឱ្យបានសមស្រប វាអាចជួយទប់ស្កាត់ រឺកាត់បន្ថយផលអវិជ្ជមាននានាបានដូចដែលប្រទេសមួយចំនួនធ្លាប់បានអនុវត្ត ។

# ៥. ផលិតកម្មសត្វនិងសេវាកម្មបសុព្យាបាលនៅកម្ពុជា

ដោយ ប្រ៊ែត បាឡាដ និង ធន់ វឌ្ឍនា

## សេចក្តីផ្តើម

សត្វបានដើរតួនាទីយ៉ាងសំខាន់ ក្នុងវិស័យកសិកម្មកម្ពុជា ឧទាហរណ៍ សត្វធំៗ ដូចជាគោក្របី ជាប្រភពកំលាំងអូសទាញ ដឹកជញ្ជូន និងជាប្រភពជីធម្មជាតិ ដែលកសិករប្រើក្នុងការដាំដុះដំណាំ ស្រូវ និងដំណាំផ្សេងៗទៀត ។ ក្រៅពីនេះសត្វជាប្រភពប្រូតេអ៊ីន ប្រាក់ចំនូល និងប្រាក់សន្សំរបស់គ្រួសារនៅទីជនបទផងដែរ ។ ក្នុងសេដ្ឋកិច្ច តំលៃសត្វសរុបមាន ១៥% នៃតំលៃផលិតផលកសិកម្មសរុប ហើយកសិកម្មមាន ៣២% នៃផលិតផលក្នុងស្រុកសរុប ។ កសិដ្ឋានខ្នាតតូចភាគច្រើនដំណើរការដោយអ្នកក្រតាមជនបទ និងរួមចំណែក ៨៥% នៃផលិតកម្មសត្វ នាំអោយផលិតកម្មសត្វអាចជាផ្នែកមួយសំខាន់ក្នុងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ។

ប៉ុន្តែចំនួនសត្វដែលកសិករ មានបង្ហាញថា ប្រយោជន៍ដែលទទួលពីផលិតកម្មសត្វមិនស្មើគ្នាទេ ។ ភាពជាម្ចាស់លើចំនួនសត្វជាសូចនាករសំខាន់មួយប្រាប់ពីស្ថានភាពសេដ្ឋកិច្ចគ្រួសារ ដោយគ្រួសារក្រជាទូទៅមានចំនួនសត្វតិចជាងគ្រួសារអ្នកមាន ។ លើសពីនេះទៀត អ្នកក្រជាញឹកញាប់មិនអាចទទួលបាននូវសេវាបសុព្យាបាលដែលមានប្រសិទ្ធភាព សំរាប់សត្វតែប៉ុន្មានក្បាលដែលគេមានឡើយ ហើយត្រូវពឹងផ្អែកលើការព្យាបាលតាមបែបបុរាណដែលអស់កំរៃតិច ។ ទិន្នផលសត្វជួបប្រទះឧបសគ្គដោយសារជំងឺឆ្លងដូចជា អុតក្តាម ដង្កោកាច់ និងផ្តាសាយបក្សីជាដើម ហើយកសិករបន្តពឹងផ្អែកលើវិធីចិញ្ចឹម និងព្យាបាលសត្វតាមបែបបុរាណ ដោយសារកង្វះសេវាកម្មផ្សព្វផ្សាយបច្ចេកវិទ្យាការពារ និងព្យាបាលទំនើប ។ ដើម្បីកាត់បន្ថយភាពក្រីក្រនៅជនបទ ចាំបាច់ត្រូវលើកកំពស់ទិន្នផលសត្វ និងកែលំអប្រព័ន្ធទីផ្សារដែលពាក់ព័ន្ធ ។

ទោះសំខាន់ក៏ដោយ ក៏ផលិតកម្មសត្វ និងសេវាបសុព្យាបាល មិនទាន់លេចចេញជាដុំកំភួន ក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្ម និងកាត់បន្ថយភាពក្រីក្រនៅឡើយទេ ។ អត្ថបទនេះ សំដៅលើកកំពស់ផលិតកម្មសត្វ និងសេវាបសុព្យាបាល ក្នុងក្របខ័ណ្ឌគោលនយោបាយកាត់បន្ថយភាពក្រីក្រ និងបង្កើនពាណិជ្ជកម្មសត្វ ។

## ១. ស្ថានភាពទូទៅនៃផលិតកម្មសត្វ

ផ្នែកនេះធ្វើការពិភាក្សាអំពីបញ្ហាការផ្គត់ផ្គង់ និង តំរូវការផលិតផលសត្វ បន្ទាប់មកពិភាក្សាលើកត្តានៃការលូតលាស់ផលិតកម្មសត្វ បញ្ហាទីផ្សារ និងពាណិជ្ជកម្មឆ្លងដែន ។

*ផលិតកម្មសត្វ (ការផ្គត់ផ្គង់ និងតំរូវការ)*

គោលដៅនៃផលិតកម្មសត្វនៅកម្ពុជាដល់ឆ្នាំ២០១០ គឺការធានាអោយបានគ្រប់គ្រាន់នូវ គោប្រើជាកំលាំងអូសទាញ ការផ្គត់ផ្គង់សាច់មានគុណភាព និងការនាំចេញ ។ ក្រសួងកសិកម្មលើកទឹកចិត្ត ការផលិតក្នុងស្រុក ជំនួសការនាំចូល (ជ្រូកនិងបក្សី) ។ ការផ្គត់ផ្គង់មានការកើនឡើង តែមិនទាន់ឆ្លើយតបនឹងតំរូវការទីផ្សារនៅក្នុងស្រុកនៅឡើយទេ ។ ការនេះទាមទារការបង្កើនផលិតកម្ម តាមរយៈការប្តូរផ្លាស់ទៅរកផលិតកម្មបែបទំនើបជាងពេលបច្ចុប្បន្ន ។

តំរូវការសាច់នៅកម្ពុជា នឹងបន្តកើនឡើងដោយសារកំរិតទាបនៃការទទួលទានសាច់ក្នុងម្នាក់ៗ កំណើនប្រជាជន កំនើនប្រាក់ចំណូលរបស់ពលរដ្ឋ និងការរីកចំរើនផ្នែកនគរូបនីយកម្មជាដើម ។ ឯតំរូវការក្នុងតំបន់ក៏កើនឡើង ដែលធ្វើអោយតំរូវការសត្វមានច្រើន ដែលជាការលើកទឹកចិត្តដល់ការផលិត ។ ការបង្កើនផលិតកម្មទាមទារប្រាក់កំចីក្នុងអត្រាការប្រាក់សមរម្យ បច្ចេកវិទ្យាថ្មីៗ និងការកំចាត់ជំងឺ ។ ជំងឺជាបញ្ហាចំបងដែលប្រឈមមុខកសិករខ្មែរ - ជំងឺផ្តាសាយបក្សី បានរួមចំណែកធ្វើអោយធ្លាក់ចុះផលិតកម្មបសុបក្សីស្មើរ ១0% ក្នុងឆ្នាំ២00៤ ។ ដោយសារបសុពេទ្យរដ្ឋមិនអាចធ្វើការបានពេញលេញ កិច្ចសហការជាមួយភ្នាក់ងារសុខភាពសត្វសហគមន៏ (ភសសស) ដែលបង្កើតដោយរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ដើរតួសំខាន់ក្នុងការឃ្លាំមើលលទ្ធភាពសាយភាយជំងឺ ការពារជំងឺ កត់ត្រាទិន្នន័យ ផ្សព្វផ្សាយ និងផ្តល់សេវាបសុព្យាបាលនៅមូលដ្ឋាន ។

### *ទីផ្សារ និង ពាណិជ្ជកម្មឆ្លងដែន*

នៅកម្ពុជា អ្នកជំនួញខ្នាតតូច ទិញ និងដឹកជញ្ជូនសត្វពីសហគមន៏ ហើយលក់អោយអ្នកជំនួញធំៗនៅកន្លែងប្រមូលផ្តុំ ដែលភាគច្រើននៅក្បែរទីប្រជុំជន បន្ទាប់មកសត្វទាំងនោះត្រូវគេដឹកទៅទីសត្តឃាត សំលាប់យកសាច់លក់អោយអតិថិជន ។ ប្រព័ន្ធទីផ្សារហាក់ដូចជាល្អដែរ តែចំនាយលើការដឹកជញ្ជូនខ្ពស់ ដោយសារតំលៃសាំងខ្ពស់ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនមិនសូវល្អ មធ្យោបាយដឹកជញ្ជូនគ្មានប្រសិទ្ធភាព និងការទារប្រាក់ខុសគោលការណ៏ ។ ការនេះរួមចំណែកធ្វើអោយមានគំលាតគ្នាខ្លាំងរវាងតំលៃដែលកសិករទទួលបាន ធៀបនឹងតំលៃទីផ្សារ និងធ្វើអោយកសិករនៅជនបទទទួលបានកំរៃពីសត្វដូចគ្នា តិចជាងកសិករនៅជិតផ្សារ ។ កង្វះព័ត៌មានទីផ្សារ បានធ្វើអោយកសិករបាត់បង់ឱកាសទារថ្លៃសំរាប់ផលិតផលរបស់គេ ។ តំលាភាពទីផ្សារតាមរយៈការផ្តល់ព័ត៌មានអំពីតំលៃរាយនិងដុំ តំរូវការនិងការផ្គត់ផ្គង់ក្នុង និងក្រៅប្រទេស អាចជាប្រយោជន៏ដល់កសិករ អ្នកជំនួញ អ្នកបរិភោគ និងអ្នកធ្វើពាណិជ្ជកម្មឆ្លងដែនផងដែរ ។

ពាណិជ្ជកម្មឆ្លងដែនជួយពង្រីកទីផ្សារ និងធ្វើអោយតំលៃទំនិញមានស្ថិរភាព តែវាត្រូវការផលិតផលដែលមានគុណភាព និងតំលៃទាបសមរម្យ ដើម្បីវាតយកទីផ្សារនៅក្រៅប្រទេសបាន ។ ជាមួយគ្នានឹងគុណប្រយោជន៏របស់វា ក៏មានហានិភ័យផងដែរ នោះគឺបញ្ហាជំងឺឆ្លងសត្វ ជាពិសេសពេលដែលមានការរត់ពន្ធសត្វនាំរដូវផ្ទុះជំងឺ ។ ការនេះកើតមានដោយសារកង្វះសេវាបសុព្យាបាលដែលមានគុណភាព និងសេវាត្រួតពិនិត្យមើលសុខភាពសត្វពេលធ្វើចលនាឆ្លងតំបន់ ។ ម្យ៉ាងទៀត ក៏អាចមានពាណិជ្ជកម្មឆ្លងដែនមិនស្មើភាព ឧទាហរណ៏ដំណើរទស្សនកិច្ចនៅកសិដ្ឋានជ្រូក San Miguel ដែលជាកសិដ្ឋានជ្រូកធំមួយនៅវៀតណាម បានបង្ហាញថា គេធ្លាប់លក់ជ្រូកទៅភ្នំពេញ ក្នុងតំលៃ១៥-២0% ក្រោមថ្លៃផលិតកម្ម ។ ការនេះទាមទារនូវវិធានការសមស្រប បើមិនដូច្នេះទេ វាធ្វើអោយប៉ះពាល់ដល់កសិករតូចតាច និងការកាត់បន្ថយភាពក្រីក្រជាមិនខាន ។ ហេតុនេះគួរមានការសិក្សាប្រៀបធៀប ថ្លៃផលិតកម្ម រវាងប្រទេសមួយទៅនឹងប្រទេសផ្សេងទៀតក្នុងតំបន់ពាក់ព័ន្ធ ។

## ២. សេវាបសុព្យាបាលសហគមន៍

សេវាបសុព្យាបាលមិនទាក់ទាញអ្នកបច្ចេកទេសដែលមានសមត្ថភាពពីខាងក្រៅទេ ហេតុនេះទាមទារអោយមានការហ្វឹកហ្វឺនដល់អ្នកក្នុងសហគមន៏ អោយចេះ និងផ្តល់សេវាបសុព្យាបាល ។ ផ្នែកនេះនឹងពិភាក្សាអំពីនិរន្តរភាពនៃការផ្តល់សេវាបសុព្យាបាលឯកជនតាមសហគមន៏ ដោយសិក្សាលើ ភសសស ១៧២នាក់ (ប្រុស១៣៩ ស្រី៣៣) ដែលបណ្តុះបណ្តាលដោយអង្គការ CWS ហើយបានដំណើរការដោយខ្លួនឯងអស់ពេល ៦ឆ្នាំ ក្នុងខេត្តបាត់ដំបង

និងបន្ទាយមានជ័យ ។ ការសិក្សាមានពីរលើក លើកទី១ឆ្នាំ២០០៣ និងលើកទី២ឆ្នាំ២០០៦ ។ ភសសស ទទួលពិន្ទុផ្អែកលើភាពសកម្ម ក្នុងការផ្តល់សេវា និងសមាមាត្រប្រាក់ចំនូលពីសេវានោះ ធៀបនឹងចំនូលសរុប - A (សកម្មខ្លាំង) ៦ពិន្ទុ B (សកម្ម) ៤ C (មិនសូវសកម្ម) ២ និង D (ឈប់សកម្មភាព) 0 ។

ពិន្ទុជាមធ្យមក្នុងឆ្នាំ២០០៣ គឺ ២.២ ស្ត្រីបានតែ ១.៥ ឯបុរសបាន២.៤ ។ ក្នុងចំណោមបុរសមាន ៤៥.៣% ស្ថិតក្នុងលំដាប់ A និង B ហើយ ៣៩.៣% បាន D ។ ក្នុងចំនោមស្ត្រីវិញមាន ៣០.៣% ស្ថិតក្នុងលំដាប់ A និង B ហើយ ៥៤.៥% បាន D ។ អត្រាបោះបង់សេវាបសុព្យាបាល អាស្រ័យមួយផ្នែកលើចំនួន ភសសស ដែលមានច្រើនលើសតំរូវការសេវាក្នុងសហគមន៍ ។ ក្នុងឆ្នាំ២០០៦ ការសិក្សាបង្ហាញអោយឃើញថា ភាគរយនៃក្រុម A និង B បានថយចុះបន្តិចនៅបាត់ដំបង តែថយចុះយ៉ាងខ្លាំងនៅខេត្តបន្ទាយមានជ័យ ។ ការនេះមានការពាក់ព័ន្ធទៅនឹងល្បឿនលូតលាស់របស់ផលិតកម្មសត្វ និងការពង្រីកសមត្ថភាពរបស់ ភសសស ដែលធ្វើអោយគាត់ម្នាក់អាចបំរើសេវាហួសពីភូមិរបស់ខ្លួន ពោលគឺឆ្លងឃុំ និងស្រុក ។ ការថយចុះនៃសេវាបសុព្យាបាល ក៏ទាក់ទិននឹងកត្តាផ្សេងទៀតដែរ ដូចជា ការសុំចុះថ្លៃសេវានិងថ្នាំ ការជំពាក់ថ្លៃយូរ និងការមិនសងថ្លៃព្យាបាល ។ ប្រការមួយទៀតគឺការផ្តល់សេវាគ្មានគុណភាព ដែលនាំអោយកសិករបាត់ជំនឿ ហើយរកអ្នកផ្សេងក្រៅពី ភសសស ។

## ៣. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

កម្ពុជាមានឱកាសបង្កើនផលិតកម្មសត្វព្រោះ កំណើនប្រជាជនខ្ពស់គួរសម ក៏រិតបរិភោគសាច់ក្នុងម្នាក់ៗនៅទាប និងកំណើនតំរូវការសាច់សត្វក្នុងប្រទេសនិងក្នុងតំបន់បានកើតឡើងដោយសារ កំណើននគររូបនីយកម្ម និងកំនើនប្រាក់ចំណូលរបស់ពលរដ្ឋម្នាក់ៗ ។ ប៉ុន្តែកសិករខ្មែរមិនទាន់អាចយកចំនេញលើឱកាសនេះបាននៅឡើយ - កម្ពុជាត្រូវប្តូរពីផលិតកម្មអន់ថយ ទៅផលិតកម្មទំនើប ពង្រឹងប្រព័ន្ធទីផ្សារបច្ចុប្បន្ន និងជំរុញការបន្ថែមថ្លៃផលិតផលតាមរយៈការវេចខ្ចប់ និងកែច្នៃ ។

ផ្នែកឯកជនអាចជួយបង្កើនផលិតកម្ម ព្រោះគេមានលទ្ធភាពនាំមកនូវបច្ចេកវិទ្យាថ្មី និងទុនវិនិយោគ តែរដ្ឋាភិបាលត្រូវមានគោលនយោបាយសំរួលដល់ផ្នែកឯកជន អោយគេអាចជួយដល់ផលិតកម្មតូចៗ ដើម្បីជាមធ្យោបាយកាត់បន្ថយភាពក្រីក្រ ។ ជាមួយគ្នានេះ រដ្ឋាភិបាលត្រូវចាត់ការយ៉ាងណាធ្វើអោយ សោហ៊ុយនៃការធ្វើជំនួញថយចុះ និងមានតំលាភាពទីផ្សារ ដើម្បីជាការជំរុញ ផលិតកម្ម និងពាណិជ្ជកម្ម ។ សារព័ត៌មានអាចដើរតួនាទីយ៉ាងសំខាន់ក្នុងកិច្ចការនេះ ។

ដើម្បីកុំអោយរាំងស្ទះដល់ពាណិជ្ជកម្មឆ្លងដែន ដែលបណ្តាលពីជំងឺឆ្លង ចាំបាច់ត្រូវមានឧបករណ៍ និងវិធានការដែលអាចធានាបាននូវការត្រួតពិនិត្យឬត់ចត់មុនមានចលនាសត្វឆ្លងដែន ។ វិធានការសំរាប់ឆ្លើយតបភាពអាសន្នក្នុងករណីផ្ទុះជំងឺ ក៏ត្រូវរៀបចំទុកមុនផងដែរ ដើម្បីធានានូវប្រសិទ្ធភាព និងអន្តរាគមន៍ទាន់ពេលវេលា ។ ជាមួយគ្នានេះ ក៏ត្រូវមានសហប្រតិបត្តិការល្អរវាង ស្ថាប័នពាក់ព័ន្ធក្នុងប្រទេស និងក្នុងតំបន់ ដើម្បីឈានទៅរកការបង្កើតបណ្តាញព័ត៌មានមួយដែលប្រកបដោយប្រសិទ្ធភាព ។

ដើម្បីជួយដល់កសិករតូចតាចក្នុងការបង្កើនផលិតកម្មសត្វ និងជំរុញពាណិជ្ជកម្មក្នុងស្រុក និងតំបន់ រដ្ឋាភិបាល និងភ្នាក់ងារអភិវឌ្ឍន៍នានា ត្រូវពង្រឹងបណ្តាញ ភសសស ។ ទោះបីជាបណ្តាញនេះងាយបែកបាក់ តែវាគឺជាយន្តការនៅនឹងកន្លែង ហើយដែលអាចចូលទៅដល់កសិករតូចតាចបាន ដើម្បីផ្សព្វផ្សាយអំពីសុខភាពសត្វ រួមទាំងព័ត៌មានស្តីអំពី ទីផ្សារ និងផលិតកម្មផងដែរ ។

ភសសស មួយចំនួនមានយុទ្ធសាស្រ្ត ក្នុងការចាត់ចែងសេវារបស់ខ្លួន រួមមានការតថ្លៃគ្នា ការប្រតិបត្តិជាក់ស្តែង និងការអនុវត្តន៏តាមកិច្ចសន្យាជាដើម ។ ក្នុងពេលជាមួយគ្នានោះដែរ ភសសស មួយចំនួនទៀត បញ្ឈប់សេវាកម្មរបស់ខ្លួនដោយសារហេតុផលផ្សេងៗ ។ ភេទ អាយុ កេរ្តិ៍ឈ្មោះ និងចំណូលរបស់គ្រួសារគឺជាស្ថានការណ៍បង្ហាញពីសមត្ថភាពរបស់ ភសសស ក្នុងការបន្តផ្តល់សេវា ។ សូចនាករបង្ហាញថា ភសសស ក្រីក្រ រឺខ្វះកេរ្តិ៍ឈ្មោះច្រើនតែបញ្ឈប់សេវាក្នុងពេលណាមួយ ។ ការនេះក៏បង្ហាញអោយឃើញនូវប្រភេទ ទំហំ និងរយៈពេលដែលត្រូវឧបត្ថម្ភអោយពួកគេពីសំណាក់រដ្ឋាភិបាល ម្ចាស់ជំនួយ អង្គការសង្គមស៊ីវិល និងអ្នកវិនិយោគឯកជន ។ បញ្ហាមួយក្នុងចំណោមបញ្ហាសំខាន់ៗដែល ភសសស ជួបប្រទះគឺ ការសុំជំពាក់លុយថ្លៃព្យាបាល ។ អន្តរាគមន៏ក្នុងបញ្ហានេះគឺ ការផ្តល់នូវឥណទានមានការប្រាក់ទាបដល់ ភសសស ។ គេអាចពង្រឹង ភសសស តាមរយៈយុទ្ធនាការរួមគ្នាក្នុងការចាក់ថ្នាំការពារជំងឺសត្វ ការរាប់ចំនួនសត្វ និងការតាមដានមើលស្ថានភាពជំងឺឆ្លង ដោយប្រើប្រាស់កំលាំង ភសសស ដែលមានស្រាប់ ។

# ៦. សម្បត្តិធម្មជាតិរួម និងភាពក្រីក្រ៖ ការវិភាគលើចំណងទាក់ទង រវាងភាពក្រីក្រជនបទ និងការប្រើប្រាស់ធនធានធម្មជាតិ

ដោយលោក កាស្ពើ_ហាសិន គ្រីសស្មៀន_ស្កុត និង តុប_នេត


## សេចក្តីសង្ខេប

អត្ថបទនេះពិនិត្យពីទំនាក់ទំនងរវាងភាពក្រីក្រ ឬជីវភាពអ្នកជនបទ និងសម្បត្តិធម្មជាតិរួម (Common Property Resources, CPR) ដូចជា ធនធានព្រៃឈើ និងជលផលជាដើម ហើយនិងការប្រែប្រួលធនធានទាំងនេះ ដោយផ្អែកលើលទ្ធផលនៃការស្រាវជ្រាវអំពីជីវភាពអ្នកជនបទ និងសម្បត្តិធម្មជាតិ ។ មានការសិក្សាជាច្រើនបានធ្វើឡើងដោយបណ្តាស្ថាប័ននានា ដូចជា ការសិក្សារបស់ធនាគារពិភពលោក (WB) ដែលមានចំណងជើងថា "ការវាយតម្លៃភាពក្រីក្រ" ការសិក្សារបស់វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ-CDRI) ក្រោមចំណងជើងថា "ការសិក្សាពីការចាកផុតពីភាពក្រីក្រ" (Moving out of Poverty Study, MOPS) និង "ការវាយតម្លៃភាពក្រីក្រដោយមានការចូលរួម" (Participatory Poverty Assessment, PPA) ព្រមទាំងការសិក្សាស្រាវជ្រាវសេដ្ឋកិច្ច-សង្គមកិច្ចជាច្រើនទៀត និងការវាយតម្លៃផលិតផលព្រៃឈើ ដែលអនុវត្តដោយកម្មវិធីធនធានធម្មជាតិ និងបរិស្ថាន (NRE) នៃវិទ្យាស្ថាន វបសអ ។ ដោយផ្អែកលើលទ្ធផលបានពីការសិក្សាខាងលើ និងលទ្ធផលថ្មីៗជាច្រើនបានពីការសិក្សាក្នុងកម្មវិធី NRE នៃ វបសអ ។ អត្ថបទនេះនឹងពិភាក្សាស៊ីជំរៅពីទំនាក់ទំនងរវាងជីវភាពអ្នកជនបទ និងការប្រើប្រាស់សម្បត្តិធម្មជាតិរួមនៅកម្ពុជា ។


*(អត្រាប្តូរប្រាក់នៅឆ្នាំ២០០៤/០៥ គឺប្រមាណ ៤១០០រៀល ក្នុងមួយដុល្លារសហរដ្ឋអាមេរិក)*

## សេចក្តីផ្តើម

កម្មវិធីកាត់បន្ថយភាពក្រីក្រទទួលការយកចិត្តទុកដាក់យ៉ាងខ្លាំងនាពេលបច្ចុប្បន្ននៅប្រទេសកម្ពុជា ។ ធនាគារពិភពលោកបានធ្វើការវាយតម្លៃទំនោរនៃភាពក្រីក្រថ្នាក់ជាតិនៅឆ្នាំ១៩៩៣/៩៤ និងនៅឆ្នាំ២០០៤ ។ ការវាយតំលៃបានផ្អែកលើទិន្នន័យជាច្រើន ដែលបានសិក្សាដោយ "អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា" (Cambodian Socio-Economic Survey) ធនាគារពិភពលោក និងវិទ្យាស្ថាន វបសអ នៅឆ្នាំ២០០៤/០៥ ។ ហេតុនេះយើងមានបំណងធ្វើការវិភាគឱ្យកាន់តែជ្រៅជ្រះថែមទៀតអំពីសារៈសំខាន់នៃសម្បត្តិធម្មជាតិរួម ចំពោះជីវភាពគ្រួសារនៅតាមជនបទ ។ ឈរលើមូលដ្ឋាននៃលទ្ធផលវិភាគនេះ យើងសង្ឃឹមថា អត្ថបទនេះអាចជាវិភាគទានចំពោះការចូលរួមកាត់បន្ថយភាពក្រីក្រផងដែរ ពិសេសគ្រួសារនៅតាមជនបទ ។

## សំយោគលទ្ធផលសិក្សា

អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចនៅឆ្នាំ២០០៤ បានបង្ហាញថា ប្រជាពលរដ្ឋកម្ពុជាប្រហែល ៣៥% កំពុងរស់នៅក្រោមខ្សែបន្ទាត់ក្រីក្រ ដែលស្មើនឹង ២៣៥១ រៀល/ថ្ងៃ នៅភ្នំពេញ ១៩៥២រៀល/ថ្ងៃ នៅទីរួមខេត្ត-ក្រុងផ្សេង និង ១៧៥៣រៀល/ថ្ងៃ នៅទីជនបទ ។ ការអង្កេតនៅឆ្នាំ២០០៤ ខាងលើក៏បង្ហាញដែរថា ៩១% នៃអ្នកក្រីក្ររស់នៅ

តាមជនបទដាច់ស្រយាល ដោយខ្វះខាតផ្លូវថ្នល់ ទីផ្សារសមស្រប និងសេវាកម្មសាធារណៈចាំបាច់នានា ។ ទោះយ៉ាងនេះក្តី ការវិភាគក៏បានបង្ហាញថា ភាពក្រីក្របានថយចុះ ១,១% ក្នុងមួយឆ្នាំនៅឆ្នាំ១៩៩៣-៩៤ និង ២០០៤ ។ គួរកត់សំគាល់ថា ការថយចុះនៃភាពក្រីក្រនេះ គឺជាតួលេខមួយទាបបំផុត បើប្រៀបធៀបទៅនឹងប្រទេសឯទៀតៗ ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានៅក្នុងទសវត្សរ៍ ១៩៩០ ។

ចំនុចគួរចាប់អារម្មណ៍ជាងគេក្នុងការសិក្សាខាងលើគឺថា ខណៈភាពក្រីក្រថយចុះ **អសមធម៌**ក៏កើនឡើងគួរកត់សំគាល់ ។ ភាពក្រីក្រនេះ អាចកាត់បន្ថយបានយ៉ាងមានប្រសិទ្ធភាពនៅតំបន់ទីក្រុង ដែលបណ្តាលឱ្យមានគំលាតកាន់តែធំឡើងរវាងអ្នកធូរធារនៅទីក្រុង និងអ្នកក្រនៅតាមជនបទ ។ ផែនការអភិវឌ្ឍន៍យុទ្ធសាស្រ្តជាតិឆ្នាំ២០០៦-២០១០ របស់រាជរដ្ឋាភិបាលកម្ពុជាក៏បានបង្ហាញដែរថា ភាពក្រីក្រនៅតាមជនបទគឺជាបញ្ហាចោទធំបំផុត ។ គន្លឹះចំបងគេចំពោះការកាត់បន្ថយភាពក្រីក្រនៅជនបទគឺ ការធានានូវសមធម៌ក្នុងការទទួលផលពីសម្បត្តិធម្មជាតិរួម ។

កម្មវិធីធនធានធម្មជាតិនៃវិទ្យាស្ថាន វបសអ បានធ្វើការសិក្សាមួយអំពីប្រជាពលរដ្ឋក្រីក្រ ចំនួន ៥០២ គ្រួសាររស់នៅក្នុង ១៦សហគមន៍ ក្បែរតំបន់ព្រៃឈើ ដោយបែងចែកគ្រួសារជនបទជាពីរប្រភេទគឺ គ្រួសារក្រីក្រ និងគ្រួសារធូរធារមធ្យម ។ លទ្ធផលបង្ហាញថា ក្នុងក៏រិត ១០០% នៃផលចំណូលប្រចាំជីវភាព គ្រួសារក្រីក្រទទួលបាន ៤២% នៃប្រាក់ចំណូលសរុបរបស់គាត់ពីអនុផលព្រៃឈើ ហើយក្នុងក៏រិត ១០០% នៃផលចំណូលប្រចាំជីវភាពដូចគ្នា គ្រួសារធូរធារមធ្យមទទួលបាន ៣០% នៃប្រាក់ចំណូលសរុបពីអនុផលព្រៃឈើ ។ ម្យ៉ាងទៀត ថ្វីត្បិតតែអត្រាប្រាក់ចំណូលបានពីព្រៃឈើរបស់គ្រួសារធូរធារមធ្យម តូចជាងអត្រាប្រាក់ចំណូលពីព្រៃឈើរបស់គ្រួសារក្រីក្រ (៣០% ទល់នឹង ៤២%) ក៏ដោយ ក៏គ្រួសារធូរធារមធ្យមប្រើប្រាស់ផល-អនុផលព្រៃឈើច្រើនជាងគ្រួសារក្រីក្រដែរ គឺ ៣៤៥ដុល្លារ ទល់នឹង ២៨០ដុល្លារ ក្នុងមួយឆ្នាំ ។ ប្រភេទផល-អនុផលព្រៃឈើទាំងនោះគឺ សាច់សត្វព្រៃ អុស សំភារៈសំណង់ ជ័រគ្រប់ប្រភេទ បន្លែ និងរុក្ខជាតិឱសថ ។ ផលិតផលទាំងនេះចាំបាច់ណាស់សំរាប់សន្តិសុខស្បៀង ប្រាក់ចំណូល និងសំភារៈលំនៅដ្ឋាន ។

ក្រៅពីភាពចាំបាច់សំរាប់ជីវភាពជនបទ អនុផលព្រៃឈើក៏ជាប្រភពប្រាក់ចំណូលចំបងជាងគេ ដោយអាចផ្តល់ ១៣៧ដុល្លារ ដល់គ្រួសារក្រីក្រ និង ១៨៨ដុល្លារ ដល់គ្រួសារធូរធារមធ្យម ។ ប្រជាពលរដ្ឋម្នាក់នៅខេត្តសៀមរាបបានលើកឡើងថាៈ *ព្រៃឈើមានសារៈសំខាន់ណាស់ដល់ការទ្រទ្រង់ជីវភាពរបស់ពួកយើង ។ ព្រៃឈើផ្តល់ឱ្យយើងនូវគ្រឿងសំណង់ អាហារ បន្លែ និងការប្តូរយកប្រាក់ចំណូលខ្លះៗទៀតផង ។ ប៉ុន្តែឥឡូវនេះ យើងត្រូវទៅកាន់តែឆ្ងាយពីផ្ទះដើម្បីរកផល-អនុផលទាំងនោះ ព្រោះព្រៃឈើត្រូវគេកាប់អស់ហើយ ។ ដោយសារអស់ព្រៃឈើ យើងជួបបញ្ហារាំងស្ងួត-ខ្វះទឹកធ្វើស្រែ ឬទឹកជន់លិចស្រូវអស់ ។*

គ្រួសារក្រីក្ររកបានពី ១០០០-២០០០រៀល ក្នុងមួយថ្ងៃ ពីការប្រមូលអុស រីឯគ្រួសារធូរធារមធ្យម រកបានពី ៣០០០-៥០០០រៀល ចំពោះការងារដូចគ្នា ដោយសារពួកគេមានរទេះគោ ឬមធ្យោបាយផ្សេងទៀត ។ ចំពោះការលក់ផល-អនុផលព្រៃឈើ ការដឹកជញ្ជូន គឺជាចំណាយធំជាងគេ ។ ចំពោះភូមិខ្លះ ការលក់ធ្យូង គឺជាប្រភពប្រាក់ចំណូលសំខាន់បំផុត ដូចភូមិមួយនៅខេត្តពោធិ៍សាត់ ជាឧទាហរណ៍ដ៏គួរឱ្យកត់សំគាល់ៈ អ្នកភូមិចំណាយ ១៧០.០០០រៀល សំរាប់សង់ឡធ្យូងមួយដែលអាចផ្តល់ធ្យូងប្រមាណ ៣តោន ក្នុងមួយលើកៗ ហើយគេត្រូវយកដើមឈើប្រភេទ ត្បែង ត្រាច ខ្លុង និងពេលខ្លះ សុក្រំ ដែលមានអង្កត់ផ្ចិតពី ២០-២៥ស.ម មកដុត ។ ឡធ្យូងភាគច្រើនជាកម្មសិទ្ធិរបស់គ្រួសារធូរធារ មធ្យម ហើយគ្រួសារក្រីក្រទទួលបាន ២៥០០រៀល/ថ្ងៃ ពីការលក់

ពលកម្មដុតធ្យូង ។ កត្តាដ៏សំខាន់ចំពោះការកាប់ឈើសំរាប់ប្រាក់ចំណូលរបស់គ្រួសារក្រីក្រ គឺឧបករណ៍កាប់ឈើ ។ គេឃើញមានតែគ្រួសារធូរធារមធ្យម និងអ្នកធូរធារជាងនេះទេ ដែលមានលទ្ធភាពទិញម៉ាស៊ីនកាត់ឈើ រីឯគ្រួសារក្រីក្រមានតែដឹង ពូថៅ ហើយនិងកាំបិត ។ ពេលខ្លះគ្រួសារក្រីក្រមានតែកាំបិតសំរាប់កាប់ឈើប៉ុណ្ណោះ ដែលជាការលំបាកជាទីបំផុតហើយ មិនមានប្រសិទ្ធភាពទៀតផង ។ ហេតុនេះ ជារឿយៗគេឃើញគ្រួសារក្រីក្រលក់ពលកម្មឱ្យគ្រួសារធូរធារ ឬធូរធារមធ្យម ដើម្បីទទួលបានកំរៃ សំរាប់ទ្រទ្រង់ជីវភាព ។

របាយការណ៍ស្តីពី "ការវាយតម្លៃភាពក្រីក្រដោយមានការចូលរួម" (PPA) បានស្រង់សំដីអ្នកភូមិម្នាក់ថា: *មានមនុស្សពីក្រៅភូមិមកទីនេះជាច្រើនចាប់តាំងពីឆ្នាំ២០០១ មក ។ ពួកគេយកមកជាមួយនូវម៉ាស៊ីនកាត់ឈើ រទេះគោរាប់រយមកពីភូមិដទៃ ហើយឡានដឹកឈើធំៗ ជញ្ជូនឈើគ្មានឈប់ពេញមួយឆ្នាំ២០០២ ។ ក្នុងពេលដែលគេធ្វើការកាប់ឈើ អ្នកភូមិក្រីក្រទទួលផលតែពីការលក់ពលកម្មប៉ុណ្ណោះ ។ ពួកគេមានគំនរឈើ ដ៏ធំនៅខេត្តសៀមរាប ។ ប៉ុន្តែឥឡូវនេះគ្មានទេ ព្រោះគ្មានឈើល្អៗនៅសល់ទៀត (ប្រភព: ADB/CDRI)* ។

**ករណីសិក្សា: ការកាប់ឈើនៅភូមិស្រឡៅ ខេត្តកំពង់ធំ**

បន្ទាប់ពីការបោះឆ្នោតនៅឆ្នាំ១៩៩៣ មានមនុស្សជាច្រើនជាអ្នកធូរធារ និងក្រុមមន្ត្រីរដ្ឋាភិបាល (ពួកអ្នកភូមិមិនដឹងថាអ្នកកាប់ឈើទាំងនោះមកពីខាងណាទេ) បានមកធ្វើការកាប់ឈើនៅព្រៃអំបៅ ចំងាយប្រមាណ ៣០គ.ម ពីភូមិ ។ ភូមិស្រឡៅ ជាភូមិមួយមានទីតាំងនៅជាប់ព្រំប្រទល់ខេត្តកំពង់ធំ និងខេត្តសៀមរាប ។ អ្នកភូមិទាំងប្រុស ទាំងស្រី ដែលមានអាយុពី ៣០ ដល់ ៤០ឆ្នាំ ត្រូវបានគេជួលឱ្យចូលរួមកាប់ឈើ ។ បុរសៗទទួលបានកម្រៃពីការកាប់ឈើប្រមាណ ៥០០០រៀលក្នុងឈើមួយដើម រីឯស្ត្រីទទួលបាន ៣០០០រៀលក្នុងការងារសំអាតផ្លូវឡានចំនួនមួយថ្ងៃ ។

នៅពេលបច្ចុប្បន្ន ទីនោះបានក្លាយជាដែនជម្រកសត្វព្រៃហើយ ។ ចាប់តាំងពីឆ្នាំ២០០១ មក ប្រជាពលរដ្ឋនៅភូមិស្រឡៅ បានប្តូរកន្លែងកាប់ឈើរបស់ពួកគេទៅកាប់នៅព្រៃកំពង់ចាមវិញ ដែលនៅចំងាយប្រមាណ ២០គ.ម ពីភូមិ ។ មានតែបុរសៗទេ ដែលចូលព្រៃកាប់ឈើ ហើយមានតែគ្រួសារធូធារមធ្យម ឬគ្រួសារធូធារទេ ដែលមានលទ្ធភាពដឹកជញ្ជូន និងមានអាហារខ្ចប់ រីឯគ្រួសារក្រីក្រមានតែលក់កំលាំងពលកម្មឱ្យគេប៉ុណ្ណោះ ។

*ប្រភព: ADB/CDRI*

អនុផលព្រៃឈើ ជាអាទិ៍មាន រុក្ខជាតិព្រៃ សត្វព្រៃ ជ័រទឹក និងអនុផលផ្សេងៗទៀត ត្រូវបានប្រជាពលរដ្ឋមូលដ្ឋានយកមកប្រើប្រាស់យ៉ាងទូលំទូលាយ ។ ពួកគេលក់អនុផលព្រៃឈើបានប្រាក់ពី ២០០០ ទៅ ៣០០០រៀល ក្នុងមួយថ្ងៃ ។ គ្រួសារក្រីក្រនានាបានលើកឡើងថា: *បន្ទាប់ពីការរាំងស្ងួតនៅឆ្នាំកន្លងមក ដែលនាំឱ្យស្រូវងាប់អស់ជាច្រើន យើងបានចាប់ផ្តើមប្រមូលបន្លែព្រៃ សត្វព្រៃ អុស សំរាប់ជីវភាពប្រចាំថ្ងៃ ។ អនុផលព្រៃឈើទាំងនោះអាចជួយស្រោចស្រង់ជីវិតរបស់ពួកយើង ។ តម្លៃលក់ឈើនៅក្នុងព្រៃទាបណាស់ បើប្រៀបធៀបទៅនឹងទីផ្សារ ។ យើងលក់ឈើនៅកន្លែងកាប់រំលំ បាន ៣០.០០០រៀល ក្នុងឈើមួយដើម តែតម្លៃឡើងដល់ ១៤០.០០០រៀល បើគេលក់វានៅផ្សារកំពង់ក្តី ខេត្តសៀមរាប ។ យើងត្រូវតែបង្ខំចិត្តលក់ឈើនៅនឹងកន្លែង ព្រោះយើងគ្មានរទេះគោដឹកវាយកទៅផ្សារទេ* ។

**ប្រវត្តិការបាត់បង់ព្រៃឈើនៅភូមិខ្លាក្រពើ ខេត្តពោធិ៍សាត់**

ក្រោយរបប ប៉ុល ពត ឆ្នាំ១៩៧៩ អ្នកភូមិខ្លាក្រពើមិនដែលខ្វល់ខ្វាយពីការខ្វះខាតធនធានធម្មជាតិ ដូចជាឈើសំណង់ ឬសត្វព្រៃសំរាប់ជីវភាព របស់ពួកគេឡើយ ។ ត្រពាំងនានាពោរពេញទៅដោយសត្វនិងរុក្ខជាតិច្រើនយ៉ាងដូចជា កង្កែប ត្រី ក្តាម ខ្យង អាពីង ក្រពើ និងបន្លែបង្កាព្រៃ ច្រើនមុខ ដូចជា ទំពាំង ។ល។ អ្នកភូមិមិនដែលខ្វះបាយ ឬចំណីអាហារហូបទេ ។ ប៉ុន្តែក្នុងរយៈពេល ១០ឆ្នាំ (១៩៨០-៩០) កងទ័ពវៀតណាមបានកាប់ឈើរហូត ។ ជាផលវិបាកគឺ ឈើធំៗក៏បានបាត់បង់អស់ ហើយសត្វព្រៃទាំងធំទាំងតូច ត្រូវបានគេសំលាប់ ឬរត់គេចខ្លួនទៅកន្លែងផ្សេងដែលមានសុវត្ថិភាពជាង ។ ដោយសារមូលហេតុនេះ អ្នកភូមិក៏ត្រូវបាត់បង់ឈើសំរាប់សង់ផ្ទះ និងសត្វព្រៃ ។ ចំពោះឈើ ឬ សត្វព្រៃ ដែលនៅសេសសល់ ក៏ទទួលរងការបំផ្លិចបំផ្លាញជាបន្តទៀតដោយអ្នកមកពីក្រៅ និងអ្នកភូមិខ្លួនឯង ។ ក្នុងចន្លោះឆ្នាំ២០០០ និង ២០០៥ ប្រជាពលរដ្ឋទទួលបានប្រាក់កំរៃតិចតួចបំផុតពីផលិតផលកសិកម្ម ព្រោះជួបប្រទះនឹងការរាំងស្ងួត ។ ដូច្នេះហើយអ្នកភូមិ និងអ្នកមកពីក្រៅផងដែរ បាននាំគ្នាចូលកាប់ឈើ និងរុករកអុសសំរាប់លក់ ដែលនាំឱ្យព្រៃឈើនៅតំបន់នោះវិនាសបាត់បង់ជាបន្តបន្ទាប់ ។ ជាផលវិបាក ព្រៃឈើនៅជុំវិញភូមិក៏បាត់បង់អស់ ត្រពាំងក៏រីង ហើយសត្វក្នុងទឹកក៏គ្មានទៀត នាំឱ្យអ្នកភូមិជួបការលំបាកក្នុងជីវភាពកាន់តែខ្លាំងឡើង ។

*ប្រភព: ADB/CDRI*

ការសិក្សានេះ ក៏បង្ហាញផងដែរអំពីផលព្រៃឈើ ដែលភាគច្រើនបានទៅក្រុមអ្នកមានអំណាច និងអ្នកធូរធារ ប៉ុន្តែបន្ទុកថែរក្សាព្រៃឈើដែលនៅសេសសល់បែរជាត្រូវរ៉ាប់រងដោយអ្នកក្រីក្រទៅវិញ ។ ពិសេសទៅទៀត អ្នកភូមិក្រីក្រទាំងនោះមិនអាចរកអ្វីផ្សេង ដើម្បីជំនួស ក្រៅពីការបង្ខំចិត្តប្រើប្រាស់ព្រៃឈើរេចរិលនេះទេនៅពេលគេជួបការរាំងស្ងួត គ្មានអង្ករបរិភោគ ។ ការទប់ស្កាត់បញ្ហាទាំងឡាយដូចខាងលើនឹងអាចជួយឱ្យរាជរដ្ឋាភិបាល ឈានទៅសំរេចគោលដៅកាត់បន្ថយភាពក្រីក្រនាសហស្សវត្សរ៍ថ្មី ។

ម្យ៉ាងទៀតយោងតាម "ការសិក្សាពីការចាកផុតពីភាពក្រីក្រ" របស់វិទ្យាស្ថាន វបសអ គ្រួសារក្រីក្រទទួលបានកំរៃពីជលផល ៩៥ដុល្លារ/ឆ្នាំ ហើយគ្រួសារធូរធារមធ្យមទទួលបាន ១២៨ដុល្លារ/ឆ្នាំ (មើលក្រាហ្វិកខាងក្រោម) ។ មានមតិស្របគ្នាជាច្រើនថា ជីវភាពប្រជាពលរដ្ឋកម្ពុជា ពឹងផ្អែកយ៉ាងខ្លាំងលើជលផល (ត្រី) ដែលអាចផ្តល់ផលឱ្យពួកគេជាម្ហូបអាហារ ឬប្រាក់កំរៃ ។ លទ្ធផលស្រាវជ្រាវជាច្រើននៃកម្មវិធីធនធានធម្មជាតិ (NRE Programme) នៃវិទ្យាស្ថាន វបសអ ក៏បង្ហាញផងដែរ ពីសារៈសំខាន់នៃជលផលបឹងទន្លេសាបចំពោះជីវភាពប្រជាពលរដ្ឋនៅជនបទ ។ សារៈសំខាន់នេះអាចដឹងបានតាមសំដីរបស់អ្នកនេសាទម្នាក់ថា: *យើងទាំងអស់គ្នានៅទីនេះ រស់នៅដោយពឹងពាក់យ៉ាងខ្លាំងលើការនេសាទ លើកលែងតែគ្រួសារមួយចំនួនតូចដែលមិនរកត្រី ដោយសារពួកគេមានលុយសំរាប់ធ្វើជំនួញដូញដូរត្រី ឬឱ្យគេខ្ចីបុល ។ ចំពោះមធ្យោបាយនេសាទត្រី វាអាចប្រែប្រួលទៅតាមកំរិតធនធានរបស់អ្នកនេសាទគឺអ្នកមានលុយច្រើនទិញឧបករណ៍នេសាទល្អជាងនិងមានសមត្ថភាពចាប់ត្រីបានច្រើនជាងអ្នកមានលុយតិច (ប្រភព: ADB/CDRI) ។*

ផលចំណូល ( ប្រាក់ និងផលិតផល) ដែលទទួលបានពីលទ្ធផលសិក្សាលើ CPR នៃ MOPS




ការគ្រប់គ្រងធនធានជលផលនៅបឹងទន្លេសាប អាចជួបនឹងការទិតៀនច្រើន ដូចពាក្យត្អូញត្អែររបស់អ្នកនេសាទម្នាក់ថាៈ *យើងជួបការលំបាកចំពោះការនេសាទ ពិសេសនៅខែប្រាំងទឹកតិច គឺពីខែ មីនា ដល់ ឧសភា ដោយផ្ទៃទឹកនេសាទរួមចុះតូច និងដោយយើងគ្មានឧបករណ៍នេសាទទំនើបសំរាប់ចាប់ត្រី ។ នៅពេលនោះ ទិន្នផលត្រីមិនអាចទទួលបានគ្រប់គ្រាន់សំរាប់ជីវភាពប្រចាំថ្ងៃរបស់យើងទេ ។ យើងត្រូវខ្ចីលុយពីគ្រួសារអ្នកមាន ហើយត្រូវសងគេវិញនៅពេលត្រីលក់បានថោក ។ ការខ្វះខាតនេះកាន់តែលំបាកទៅទៀតនៅពេលកូនយើងឈឺចំពេលដែល យើងគ្មានលុយបង់ថ្លៃថ្នាំពេទ្យ ( ប្រភពៈ ADB/CDRI)* ។ អ្នកនេសាទម្នាក់ទៀតបានលើកដែរថាៈ *អ្នកក្រីក្រដូចប្ដីខ្ញុំរកប្រាក់កម្រៃបាន ៥០០០-១០.០០០រៀលក្នុងមួយថ្ងៃ នៅអំឡុងខែមករា-ឧសភា ហើយបាន ១០០០-២០០០ រៀល នៅខែ មិថុនា-ធ្នូ ( ប្រភពៈ ADB/CDRI)* ។ ក្រៅពីការនេសាទសំរាប់ជីវភាព គ្រួសារអ្នកក្រីក្រធ្វើការបន្ថែមឱ្យគ្រួសារអ្នកធូរធារជាង ហើយទទួលបានកំរៃប្រមាណ ២០០០-៤០០០រៀល ក្នុងមួយថ្ងៃ ។ ដូចគ្នានឹងផល-អនុផលព្រៃឈើដែរ គ្រួសារក្រីក្រតែងតែពឹងពាក់គ្រួសារអ្នកធូរធារដើម្បីទទួលកម្រៃពីការលក់ពលកម្មសំរាប់ប្រមូលផលពីសម្បត្តិធម្មជាតិរួម ។

ការលក់ដូរ ឬជំនួញផលត្រី តែងធ្វើឡើងលាយឡំជាមួយនឹងការឱ្យខ្ចីប្រាក់ឯកជនដោយគ្មានការគ្រប់គ្រងពីរដ្ឋ ។ សកម្មភាពបែបនេះ តែងនាំឱ្យការប្រាក់ឡើងខ្ពស់ណាស់ ។ ឧទាហរណ៍ បើខ្ចីប្រាក់ ១០.០០០រៀល គេនឹងត្រូវបង់សងវិញ ១១.០០០រៀល នៅថ្ងៃបន្ទាប់ ។ ការប្រាក់ ១០០០រៀល គឺច្រើនខ្លាំងណាស់ចំពោះគ្រួសារក្រីក្រសំរាប់រយៈពេលមួយថ្ងៃ ពិសេសចំពោះអ្នករស់នៅក្រោមខ្សែបន្ទាត់ក្រីក្រ ។ តម្លៃត្រីដែលលក់ឱ្យម្ចាស់បំណុលតែងតែទាបជាងតម្លៃនៅទីផ្សារធម្មតា ពី ១០០ ទៅ ៧០០រៀល ក្នុងមួយគីឡូក្រាម ។ ដូចសំដីរបស់អ្នកនេសាទម្នាក់ថា *"នៅពេលយើងមានត្រី យើងត្រូវលក់ឱ្យម្ចាស់បំណុលក្នុងតម្លៃទាបជាងទីផ្សារពី ១០០ ទៅ ២០០រៀល ។ បើយើងមិនលក់ឱ្យម្ចាស់បំណុលនោះម្ចាស់បំណុលនឹងបង្ខំឱ្យយើងសងលុយគេវិញ ។ ពេលខ្លះទោះបីយើងទៅនេសាទឆ្ងាយៗមានរយៈពេលរាប់ខែក៏ដោយ ក៏ម្ចាស់បំណុលទៅតាមយកត្រីពីកន្លែងនេសាទផ្ទាល់តែម្ដង ព្រោះយើងបានខ្ចីលុយគេសំរាប់ទិញឧបករណ៍នេសាទ ឬទិញថ្នាំពេទ្យសំរាប់កូនឈឺ"* ។

របាយការណ៍ "ការវាយតម្លៃភាពក្រីក្រដោយមានការចូលរួម" បង្ហាញថា ធនធានត្រីបានថយចុះយ៉ាងខ្លាំងនៅបឹងទន្លេសាប ។ គេឃើញមានអ្នកនេសាទកាន់តែច្រើនឡើងៗ ការនេសាទក៏កើនឡើងជាលំដាប់ ហើយការប្រើឧបករណ៍ខុសច្បាប់ក៏ចេះតែកើតមានជារឿយៗ ។ ក្រៅពីនេះនៅមានសកម្មភាពជាច្រើនទៀត ដែលរំខានដល់ការបន្តពូជរបស់ត្រីដូចជា ការកាប់ព្រៃលិចទឹក ការដាក់សំរាស់បង្ខាំងចរាចរត្រី ជាដើម ដែលប៉ះពាល់ដល់គុណភាព និងបរិមាណត្រីនៅបឹងទន្លេសាប ។

## សន្និដ្ឋាន និងអនុសាសន៍

បញ្ហាភាពក្រីក្រ គឺជាចំណុចយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ហើយត្រូវបានគេធ្វើការសិក្សាជាច្រើនមកហើយដែរ ។ ចំនុចដ៏គួរឱ្យកត់សំគាល់មួយគឺ គំលាតភាពក្រីក្រថ្នាក់ជាតិនៅឆ្នាំ១៩៩៣/៩៤ និង ២០០៤ ។ ការសិក្សានេះគឺជាសំយោគរបាយការណ៍ពីការប្រើប្រាស់ធនធានធម្មជាតិកន្លងមក ។ ការវិភាគក្នុង "អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា" ឆ្នាំ២០០៣/២០០៤ និង "ការសិក្សាពីចាកផុតពីភាពក្រីក្រ" ឆ្នាំ២០០៤/២០០៥ ដែលធ្វើការពិនិត្យពីជីវភាពអ្នកពឹងអាស្រ័យលើធនធានធម្មជាតិនៅខេត្តចំនួន ៧ បានបង្ហាញថា គ្រួសារដែលពឹងអាស្រ័យតែទៅលើធនធានធម្មជាតិមួយមុខ មានជីវភាពយ៉ាប់យ៉ឺនជាងគ្រួសារដែលមានលទ្ធភាពពឹងពាក់លើធនធានធម្មជាតិផងនិងមុខរបរផ្សេងៗទៀត ។

លទ្ធផលបង្ហាញថាៈ ក្នុងមួយឆ្នាំ សហមគន៏ជនបទទទួលកម្រៃពីធនធានព្រៃឈើបាន ២៨០ដុល្លារ ចំពោះគ្រួសារក្រីក្រ និង ៣៤៥ដុល្លារ ចំពោះគ្រួសារធូរធារមធ្យម ។ ដូចគ្នាដែរ ក្នុងមួយឆ្នាំ កម្រៃទទួលបានពីជលផលគឺ ៩៥ដុល្លារ ចំពោះគ្រួសារក្រីក្រ និង ១២៨ដុល្លារ ចំពោះ គ្រួសារធូរធារមធ្យម ។ តួលេខនេះបញ្ជាក់ថា ធនធានធម្មជាតិមានតម្លៃណាស់ចំពោះជីវភាពគ្រួសារក្រីក្រ ប៉ុន្តែគ្រួសារធូរធារមធ្យមតែងទទួលផលបានច្រើនជាងគ្រួសារក្រីក្រ ។

បញ្ហាចោទចំពោះគ្រួសារក្រីក្រគឺ ថវិកា និងមធ្យោបាយទាញយកផលពីធនធានធម្មជាតិ ។ ពួកគេខ្វះខាតលុយកាក់ និងមធ្យោបាយសំរាប់ធ្វើដំណើរឆ្ងាយៗ ជាពិសេសដើម្បីដឹកទំនិញទៅទីផ្សារ ។ ផលដែលគ្រួសារភាគច្រើនទទួលបានពីសម្បត្តិធម្មជាតិរួម គឺត្រឹមតែគ្រប់គ្រាន់សំរាប់ទ្រទ្រង់ជីវភាព ។ ជាញឹកញយគ្រួសារក្រីក្រត្រូវលក់ពលកម្មទៅឱ្យគ្រួសារធូរធារមធ្យម ឬគ្រួសារធូរធារ ដែលតែងទទួលបានផលច្រើន ពីធនធានធម្មជាតិ ហើយមិនសូវចំណាយកំលាំងពលកម្មច្រើនដូចគ្រួសារក្រីក្រទេ ។

របាយការណ៍សិក្សាពី "ការវាយតម្លៃភាពក្រីក្រដោយមានការចូលរួម" និង "ការសិក្សាពីការចាកផុតពីភាពក្រីក្រ" បានបង្ហាញថា ធនធានធម្មជាតិមានការថយចុះយ៉ាងខ្លាំង ។ កត្តាមួយដែលនាំឱ្យធនធានធម្មជាតិថយចុះគឺ ចំនួនប្រជាពលរដ្ឋក្នុងភូមិកើនឡើងឥតឈប់ឈរ ។ ម្យ៉ាងទៀត គេឃើញមានជនពីក្រៅភូមិចូលមកប្រព្រឹត្តសកម្មភាពខុសច្បាប់ជាច្រើនដូចជា កាប់ឈើខុសច្បាប់ និងឆក់ត្រី ជាដើម ។ នាបច្ចុប្បន្ន អ្នកនៅក្នុងភូមិហាក់ដូចជាទទួលផលពីធម្មជាតិបានតិចជាងអ្នកមកពីក្រៅភូមិ ពីព្រោះពួកនោះមានលទ្ធភាពទំនាក់ទំនងទីផ្សារ និងមធ្យោបាយផ្សេងទៀតប្រសើរជាង ។ ហេតុនេះ ដើម្បីទទួលបានជោគជ័យលើយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ អ្នកពាក់ព័ន្ធ ឬអ្នកកសាងគោលនយោបាយ គួរយកចិត្តទុកដាក់ឱ្យបានខ្លាំងក្លា និងមុនគេទាំងអស់ លើការលើកស្ទួយជីវភាពគ្រួសារក្រីក្រ ពិសេសគ្រួសារនៅតាមជនបទ ។

# ៧. ពលកម្មចំណាកស្រុកក្នុងជីវភាពជនបទ៖ បញ្ហាប្រឈម និងការលានុវត្តិភាព

សូ សុវណ្ណារិទ្ធិ លឹម សុវណ្ណារា និង នូ កែវ សុទ្ធា

ទំហំការស្រាវជ្រាវស្តីពីបញ្ហាចំណាកស្រុកនៅកម្ពុជា កាន់តែរីកធំឡើង១ ដោយសង្កត់ធ្ងន់លើកត្តាជំរុញ និងកត្តាទាក់ទាញ ។ មានការមើលឃើញជាទូទៅថា ការធ្វើចំណាកស្រុក ជាលទ្ធផលនៃការកែប្រែទីផ្សារការងារ ដែលបង្កើតឡើងដោយគំលាតនៃការអភិវឌ្ឍន៏រវាងតំបន់ជនបទ និងទីក្រុង ។ ចំណងទាក់ទងរវាងការធ្វើចំណាកស្រុក និងការកាត់បន្ថយភាពក្រីក្រ មានភាពស្មុគស្មាញណាស់ ។ ឧទាហរណ៍ ការធ្វើចំណាកស្រុកមានការយល់ឃើញថា ជាលទ្ធផលនៃភាពក្រីក្រ និងកង្វះខាតការងារធ្វើ រឺថាជាកត្តានាំទៅរកភាពក្រីក្រនៅជនបទ និងទីក្រុង ។

ចំណាកស្រុកនៅកម្ពុជា អាចធ្វើចំណាត់ថ្នាក់ជាពីរប្រភេទ៖ ចំណាកស្រុកក្នុងស្រុក និងឆ្លងកាត់ព្រំដែន ។ ចំនួនអ្នកធ្វើចំណាកស្រុក ទាំងក្នុងស្រុក និងឆ្លងព្រំដែន មាននិន្នាការកើនឡើង ជាពិសេសនៅអំឡុងពេល ៥ឆ្នាំចុងក្រោយ ដោយសារតែកត្តាជំរុញ និងកត្តាទាក់ទាញ ។

កម្មករចំណាកស្រុកភាគច្រើន មកពីគ្រួសារក្រីក្រ ខ្លះមកពីគ្រួសារជីវភាពមធ្យម រឺទុរគត ។ គ្រួសារអ្នកមានសំរេចចិត្តនៅស្ងៀម និងមិនធ្វើចំណាកស្រុក ពីព្រោះពួកគេមានសមត្ថភាពបង្កើតប្រភពចំណូលបានច្រើន ខណៈដែលសមត្ថភាពគ្រួសារទុរគត ក្នុងការចេញទៅខាងក្រៅ និងស្វែងរកការងារធ្វើ ត្រូវថយចុះដោយសារកំហិតហិរញ្ញវត្ថុ ។ ចំណុចនេះបង្ហាញថា មានតែសមាជិកមកពីប្រភេទគ្រួសារក្រីក្រ និងជីវភាពមធ្យមទេដែលធ្វើចំណាកស្រុក ។

តាមការសំគាល់ អ្នកនៅក្នុងភូមិផ្អែកលើធនធានដី (កសិកម្ម កសិកម្ម-ព្រៃឈើ កសិកម្ម-នេសាទ) មានទំនោរធ្វើចំណាកស្រុក ច្រើនជាងអ្នកនៅក្នុងភូមិផ្អែកលើធនធានទឹក (នេសាទ នេសាទ-កសិកម្ម) រីឯអ្នកភូមិនៅតាមទីប្រជុំជន បានពឹងផ្អែកយ៉ាងខ្លាំងលើការធ្វើចំណាកស្រុក ។ អ្នកភូមិជាទូទៅ ធ្វើចំណាកស្រុកតាមរដូវកាល ដើម្បីរកការងារខាងកសិកម្ម រឺនេសាទ ដោយផ្តោតលើភូមិនៅក្បែរខាង រឺភូមិនៅជុំវិញបឹងទន្លេសាប រីឯការចំណាកស្រុករយៈពេលវែង ផ្តោតលើការងារសំណង់ និងរោងចក្រកាត់ដេរនៅក្នុងទីក្រុង និងខេត្តធំៗ ។

ការធ្លាក់ចុះធនធានធម្មជាតិ ភាពក្រីក្រ ការជំពាក់បំណុល ភាពគ្មានដី គ្រោះធម្មជាតិ ដូចជាទឹកជំនន់ និងគ្រោះរាំងស្ងួត ការធ្លាក់ចុះពេលវេលាធ្វើកសិកម្ម ហើយនិងផ្លូវថ្នល់ល្អ គមនាគមន៏ល្អ ទូរគមនាគមន៏ល្អ និងបណ្តាញសង្គមល្អ ដើរតួនាទីយ៉ាងសំខាន់ជំរុញដល់ការធ្វើចំណាកស្រុក ។

នៅក្នុងស្រុក កំណើនវិនិយោគក្នុងឧស្សាហកម្មកាត់ដេរ សំណង់ និងទេសចរណ៍ គឺជាកំលាំងសំខាន់ក្នុងការទាក់ទាញប្រជាជនឱ្យចាកចេញពីតំបន់ជនបទទៅទីក្រុងនានា និងទៅតាមបណ្តោយព្រំដែន ។ កំណើនយ៉ាងខ្ពស់នៃឧស្សាហកម្មកាត់ដេរនៅជាយក្រុងភ្នំពេញ បានទាក់ទាញស្ត្រីកម្មករជិតទង់ៗរាប់រយពាន់នាក់ឱ្យផ្លាស់ទីមករកការងារនៅទីក្រុង ដើម្បីជំនួសការងារកសិកម្ម និងនេសាទរបស់ខ្លួន ។ បុរសអ្នកចំណាកស្រុកភាគច្រើន ទៅធ្វើការងារខាងផ្នែកសំណង់ដែលកំពុងរីកលូតលាស់ក្នុងទីក្រុងធំៗនៅពាសពេញប្រទេស ។

ចំពោះចំណាកស្រុកឆ្លងកាត់ព្រំដែន ប្រជាជនកម្ពុជាច្រើនធ្វើចំណាកស្រុកទៅប្រទេសថៃ ម៉ាឡេស៊ី និងវៀតណាម ។ នៅពេលជាមួយគ្នា ប្រទេសកម្ពុជា ក៏ទទួលកម្មករចំណាកស្រុកមកពីប្រទេសវៀតណាម និងចិន

ផងដែរ ។ ការធ្វើចំណាកស្រុកជាលក្ខណៈអន្តរជាតិ ចូលមក និងចេញក្រៅកម្ពុជា មានចរិតលក្ខណៈជា "អ្នកចំណាកស្រុកចេញគ្មានជំនាញ" និង "អ្នកចំណាកស្រុកចូលមានជំនាញ និងពាក់កណ្តាលជំនាញ" ។ ចំនួនកម្មករធ្វើចំណាកស្រុកអន្តរជាតិ គឺកំពុងកើនឡើង ទោះបីគ្មានទិន្នន័យច្បាស់លាស់ក្តី ពីព្រោះកម្មករភាគច្រើនពុំមានឯកសារទេ ។

ដំណើរការសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់យ៉ាងឆាប់រហ័ស និងតំរូវការយ៉ាងខ្ពស់នៃកំលាំងពលកម្មគ្មានជំនាញនៅក្នុងប្រទេស នៅក្បែរកម្ពុជា (ថៃ និងវៀតណាម) និងនៅម៉ាឡេស៊ី បានទាក់ទាញកម្មករចំណាកស្រុកកម្ពុជាយ៉ាងច្រើនក្នុងពេលថ្មីៗនេះ ។ មានការទទួលស្គាល់ជាទូទៅថា សក្តានុពលសំរាប់ឱកាសរកចំណូលនៅក្រៅប្រទេស គឺជាចំណុចខ្លាំងក្នុងការជំរុញការធ្វើចំណាកស្រុកឆ្លងកាត់ព្រំដែន ។

គេដឹងច្បាស់ថា កត្តាជំរុញមានកំលាំងខ្លាំង ជាងកត្តាទាក់ទាញយ៉ាងច្រើន ។ ទោះជាយ៉ាងណាក្តី កត្តាជំរុញតែឯង មិនគ្រប់គ្រាន់ក្នុងការនាំឱ្យមានការធ្វើចំណាកស្រុកកំលាំងពលកម្មនោះទេ ។ ចំណាកស្រុកកំលាំងពលកម្ម ក៏មានការជួយសំរួលពីកត្តាទាក់ទាញផងដែរ ។ សរុបមក ការធ្វើចំណាកស្រុកចេញក្រៅ កំពុងកើនឡើងយ៉ាងខ្លាំងពីដំបូងដោយសារកត្តាជំរុញ ហើយក្រោយមកដោយសារកត្តាតំរូវការ ។

ប្រាក់ផ្ញើទៅផ្ទះ មិនមែនជាវិធីតែមួយគត់ក្នុងការបង្កើតឱកាសសំរាប់ការអភិវឌ្ឍន៍ និងកាត់បន្ថយភាពក្រីក្រនៅជនបទនោះទេ ។ ទោះជាយ៉ាងណាក្តី ទំហំ និងផលប៉ះពាល់នៃប្រាក់ផ្ញើទៅផ្ទះ ទៅលើការអភិវឌ្ឍន៍ និងកាត់បន្ថយភាពក្រីក្រនៅជនបទ មិនទាន់មានការយល់ដឹងបានច្បាស់លាស់ទេ ប៉ុន្តែគេជឿថាវាមានសារៈសំខាន់យ៉ាងខ្លាំង ។ ឥទ្ធិពលខាងសេដ្ឋកិច្ចនៃការធ្វើចំណាកស្រុក ទាំងក្នុងស្រុក និងឆ្លងកាត់ព្រំដែន ចំពោះជីវភាពរស់នៅរបស់ប្រជាជនជនបទ ភាគច្រើនមានលក្ខណៈវិជ្ជមាន ។ ការធ្វើចំណាកស្រុកកំលាំងពលកម្ម បន្តដើរតួកាន់តែសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេស ដែលមានប្រជាជនប្រហែល ៣៥% រស់នៅក្រោមបន្ទាត់ភាពក្រីក្រ ។ វាបានក្លាយជាប្រភពសំខាន់នៃជីវភាពនៅក្នុងភូមិទីប្រជុំជន និងក៏បានក្លាយជាប្រភពចំណូលមួយទៀតសំរាប់ភូមិកសិកម្ម និងនេសាទ ។ ការធ្វើចំណាកស្រុក ជួយឱ្យមានប្រភពចំណូលចំរុះ ជួយឱ្យប្រជាជនអាចសន្សំព្រមទាំងជួយឱ្យពួកគេមានស្ថានភាពខ្លាំងខាងហិរញ្ញវត្ថុ ក្នុងការដោះស្រាយបញ្ហាវិបត្តិចំពោះសុខភាព និងជីវភាពរស់នៅរបស់ខ្លួន ។ វាក៏បានក្លាយជាយុទ្ធសាស្ត្រដោះស្រាយសំខាន់មួយ សំរាប់អ្នកក្រីក្រអត់ដីធ្លីផងដែរ ។

ផលត្រលប់មកពីពលកម្មចំណាកស្រុក បានប្រើប្រាស់ជាសំខាន់សំរាប់ប៉ះប៉ូវកង្វះខាតស្បៀងអាហារដោយនៅសល់តិចតួចណាស់ សំរាប់គោលដៅផលិតកម្មផ្សេងៗ ។ ក្រៅពីការប៉ះប៉ូវកង្វះខាតស្បៀងអាហារចំណាកស្រុកក៏អាចឱ្យគ្រួសារមួយចំនួនពង្រឹងជីវភាពរបស់ខ្លួន ពីក្រក្រីទៅកំរិតមធ្យមបាន ក្នុងរយៈ ១០ឆ្នាំចុងក្រោយនេះ ។ កសិករមួយចំនួនប្រើប្រាស់ប្រាក់ផ្ញើបានមកពីប្តីប្រពន្ធ រឺកូនរបស់គេ ក្នុងការទិញត្រាក់ទ័រដៃ ម៉ាស៊ីនបោកបែន និងជីគីមី ដើម្បីបង្កើនផលស្រូវ ។ នាបច្ចុប្បន្ន ប្រាក់ចំណូលរបស់កម្មករចំណាកស្រុកម្នាក់ អាចចាត់ទុកថាស្មើនឹងផលកសិកម្មមួយហិកតាដីសំរាប់សុវត្ថិភាពស្បៀងក្នុងគ្រួសារ ។ ការធ្វើចំណាកស្រុក អាចជួយឱ្យប្រជាជនមានជីវភាពគ្រួសារឡើងទៅចំណាត់ថ្នាក់ល្អបាន ប៉ុន្តែក្នុងចំណោមរឿងល្អនៃអ្នកភូមិដែលផ្ញើប្រាក់ទៅផ្ទះ ហើយជួយលើកស្ទួយសុខមាលភាពក្នុងគ្រួសារ ក៏គ្រួសារមួយចំនួនដែលមានជីវភាពធ្លាក់ចុះបន្ទាប់ពីសមាជិកគ្រួសារបានចាញ់បោកអ្នករត់ការដែរ ។

នៅក្នុងភូមិភាគច្រើន មានគេរាយការណ៍ទូទៅថា ប្រាក់ចំណូលពីចំណាកស្រុក បានកើនឡើងយ៉ាងខ្លាំងនៅ ៥ឆ្នាំចុងក្រោយនេះ ។ អ្នកទៅធ្វើការនៅតំបន់ទីក្រុង រឺនៅប្រទេសថៃ បានផ្ញើប្រាក់អោយក្រុមគ្រួសារខ្លួន ។

អ្នកចំណាកស្រុកមួយចំនួនបានជួយជំរុញទំនើបភាវូបនីយកម្មក្នុងវិស័យកសិកម្ម ដោយបាននាំមកនូវបច្ចេកទេសថ្មីៗដែលពួកគេបានរៀនសូត្រនៅប្រទេសថៃ ហើយដែលបានផ្តល់ផលល្អប្រសើរជាងមុន ។ ទោះជាយ៉ាងណាក្តី មិនមានភ័ស្តុតាងអ្វីច្បាស់លាស់ទេថា ការធ្វើចំណាកស្រុក វាស្មើនឹងការអភិវឌ្ឍន៍ជនបទនោះ ។ ការធ្វើចំណាកស្រុក បានផ្តល់នូវប្រភពចំណូលបន្ថែម រឺប្រភពចំណូលផ្សេងទៀត ប៉ុន្តែវាជាដំណោះស្រាយសំរាប់រយៈពេលខ្លី ហើយមិនអាចចាត់ទុកជាយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទប្រកបដោយចីរភាពបានទេ ។ ចំណាកស្រុកកំលាំងពលកម្ម មិនមែនជាវិធីសាស្ត្រជំនួសមួយសំរាប់ការអភិវឌ្ឍន៍ជនបទទេ ទោះបីជាវាបានជួយសំរួល និងពន្លឿនការអភិវឌ្ឍន៍ជនបទដែលមានដំណើរការយឺតៗនៅកម្ពុជាក្តី ។

ជាទូទៅ ចំណាកស្រុកពីជនបទទៅជនបទ តែងប្រឈមនឹងការលំបាកតិចតួច បើប្រៀបធៀបទៅនឹងចំណាកស្រុកពីជនបទទៅទីក្រុង ។ ប្រាក់ និងបណ្តាញសង្គម ត្រូវមានចាំបាច់សំរាប់ធ្វើចំណាកស្រុកពីជនបទទៅទីក្រុង ដូច្នេះកំហិតហិរញ្ញវត្ថុ និងបណ្តាញសង្គមទន់ខ្សោយ គឺជារនាំងយ៉ាងធំចំពោះកម្មករក្រីក្រ ។ ចំពោះចំណាកស្រុកឆ្លងព្រំដែន កម្មករអាចរកបានប្រាក់ចំណូល ច្រើនជាងកម្មករចំណាកស្រុកក្នុងស្រុក ។ ប៉ុន្តែកម្មករចំណាកស្រុកឆ្លងព្រំដែន ត្រូវប្រឈមនឹងហានិភ័យកំរិតខ្ពស់ជាង ពីព្រោះតែស្ថានភាពខុសច្បាប់ និងកង្វះព័ត៌មាន និងយន្តការការពារនៅកន្លែងគោលដៅទៅធ្វើការងារ ។ អ្នកចំណាកស្រុកភាគច្រើន ដែលទៅប្រទេសថៃ គឺជាកម្មករពុំមានឯកសារ ដូច្នេះត្រូវជួបប្រទះការរំលោភបំពាន និងការកេងប្រវ័ញ្ចគ្រប់ប្រភេទ ។ យន្តការច្បាប់ល្អប្រសើរជាងមុន អាចឱ្យប្រជាជនកាន់តែច្រើនអាចរកការងារបានច្រើនថែមទៀតនៅក្រៅប្រទេស ។

ហានិភ័យពាក់ព័ន្ធនឹងកម្មករចំណាកស្រុក ភាគច្រើនទាក់ទងនឹងការទទួលប្រាក់ឈ្នួល គ្រោះថ្នាក់ថៃដន្យ ជំងឺ និងការរំលោភបំពាន ។ គ្មានអ្វីគួរភ្ញាក់ផ្អើលទេដែលកម្មករចំណាកស្រុកឆ្លងកាត់ព្រំដែន ត្រូវជួបប្រទះបញ្ហាច្រើនជាង បើធៀបនឹងកម្មករចំណាកស្រុកក្នុងស្រុក ។ ចំណាកស្រុកកំលាំងពលកម្មឆ្លងកាត់ព្រំដែន វាផ្តល់ឱកាសការងារក៏ពិតមែន ប៉ុន្តែក៏អាចមានហានិភ័យនិងបញ្ហាប្រឈមជាច្រើនផងដែរ ។

ចំណាកស្រុកនៅជនបទកម្ពុជា នៅតែជាបាតុភូតនៃភាពក្រីក្រ ដោយប្រជាជនត្រូវបង្ខំចិត្ត ជាជាងធ្វើការជ្រើសរើសដើម្បីផ្លាស់ទីលំនៅ ដូច្នេះគេនៅតែចាត់ទុកវាជា លទ្ធផលនៃកាលៈទេសៈ មិនមែនជាលទ្ធផលនៃជំរើសនោះទេ ។ និន្នាការនេះបង្ហាញពីតំរូវការនៃការអភិវឌ្ឍន៍ស៊ីជំរៅនៅតំបន់ជនបទកម្ពុជា ដើម្បីធ្វើឱ្យចំណាកស្រុកមានផលវិជ្ជមានជាអតិបរមា ។ ការធ្វើចំណាកស្រុកកំលាំងពលកម្ម គឺជាឧបករណ៍មួយសំរាប់កាត់បន្ថយភាពក្រីក្រ ប៉ុន្តែប្រសិទ្ធភាពរបស់វាមានតិចតួចប៉ុណ្ណោះ ។ ដូច្នេះ នៅតែមានតំរូវការ នូវការសិក្សាសមស្របមួយស្តីពីផលប៉ះពាល់នៃប្រាក់ផ្ញើទៅលើសេដ្ឋកិច្ចគ្រួសារនៅជនបទ ។

ដោយសារតែហានិភ័យ និងការលំបាកជាច្រើនដែលកម្មករចំណាកស្រុកត្រូវប្រឈម ជាពិសេសកម្មករចំណាកស្រុកឆ្លងកាត់ព្រំដែន អត្ថប្រយោជន៍បានមកពីការធ្វើចំណាកស្រុក នៅមិនទាន់មានជាអតិបរមានៅឡើយទេ ។ កម្មករចំណាកស្រុកក្នុងស្រុក ដែលប្រឈមនឹងហានិភ័យតិច នៅតែជួបការលំបាកក្នុងការទទួលព័ត៌មានត្រឹមត្រូវនិងទាន់ពេល ហើយពួកគេភាគច្រើនមានកំហិតហិរញ្ញវត្ថុ ។ អ្នកក្រីក្រគ្មានដី និងអ្នកក្រីក្រមានដីតិចតួចចាត់ទុកការធ្វើចំណាកស្រុកជាមធ្យោបាយសំខាន់សំរាប់ជីវភាពរស់នៅរបស់ខ្លួន ប៉ុន្តែពុំសូវទទួលបានផលចំណេញពេញលេញពីវាទេ ដោយសារជាសំខាន់កង្វះបណ្តាញសង្គម និងធនធាន ។ ចំពោះអ្នកចំណាកស្រុកឆ្លងកាត់ព្រំដែន ទោះបីជាមានអនុស្សរណៈព្រមព្រៀងរវាងប្រទេសកម្ពុជា និងថៃក្តី ក៏អ្នកចំណាកស្រុកកម្ពុជានៅតែ

ប្រឈមនឹងការរំលោភបំពានគ្រប់ប្រភេទ ពីសំណាក់មន្ត្រីនៅតាមបណ្តោយនិងកន្លែងឆ្លងកាត់ព្រំដែន ការបោកប្រាស់ដោយអ្នកតំណាង ការកេងប្រវ័ញ្ចដោយថៅកែ និងការចរាចរមនុស្ស ដោយសារតែអវត្តមានយន្តការដាក់បង្ខំអនុវត្តនីច្បាប់ ។

ជាសង្ខេប កង្វះខាតកិច្ចការពារតាមផ្លូវច្បាប់ ធ្វើឱ្យអ្នកចំណាកស្រុកងាយនឹងទទួលការរំលោភបំពានទាំងលើពាក្យសំដី និងរាងកាយ ការមិនបង់ប្រាក់ថ្លៃឈ្នួល ការចាប់ខ្លួននិងការធ្វើទារុណកម្ម កង្វះលទ្ធភាពទទួលបានសេវាថែទាំសុខភាពជាមូលដ្ឋាន ការអប់រំ និងសេវាចាំបាច់ផ្សេងៗទៀត ។

កម្មករចំណាកស្រុកឆ្លងកាត់ព្រំដែនកម្ពុជា ភាគច្រើនជាកម្មករខុសច្បាស់ គ្មានជំនាញច្បាស់លាស់ ដែលត្រូវធ្វើការ នៅក្នុងបរិយាកាសការងារប៉ះពាល់ដល់សុខភាព និងប្រឈមមុខនឹងហានិភ័យខ្ពស់នៃការកេងប្រវ័ញ្ច ។ បើសិនជាចង់ឱ្យការធ្វើចំណាកស្រុកមានផលប៉ះពាល់វិជ្ជមានច្រើនជាអតិបរមាដល់ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍ជនបទ គេចាំបាច់ត្រូវកសាងធនធានមនុស្ស និងបង្កើនចំនួនកម្មករមានជំនាញ ដើម្បីបង្កើតនិងបង្កើនយន្តការការពារសិទ្ធិអ្នកចំណាកស្រុក និងពង្រឹងលក្ខខណ្ឌការងារនៃកម្មករចំណាកស្រុក ។

# ៨. គណនេយ្យភាពជាអ្វី? និងមានស្ថានភាពយ៉ាងដូចម្តេចនៅកម្ពុជា?

ដោយ ប៉ក់ គឹមជឿន និង ហ៊ង វុទ្ធី

ខែមករា ឆ្នាំ២០០៧

*"ឯកសាររបស់រដ្ឋាភិបាលជាច្រើនបានលើកឡើងថា គណនេយ្យភាពមានសារៈសំខាន់ណាស់ ហើយគេតែងតែឃើញមានការប្រើពាក្យនេះជាញឹកញាប់ ។ ដូច្នេះយើងខ្ញុំ (ដែលជាក្រុមប្រឹក្សាឃុំ/សង្កាត់) ក៏បានប្រើប្រាស់ពាក្យនេះជាច្រើនដែរ ។ ទោះជាយ៉ាងនេះក្តី យើងនៅមិនទាន់យល់ច្បាស់ថា ពាក្យនេះមានអត្ថន័យយ៉ាងណាអោយពិតប្រាកដនៅឡើយទេ ។ ក្រសួងមហាផ្ទៃបានអោយនិយមន័យមួយលើពាក្យនេះ ចំណែកឯអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗទៀត ក៏ផ្តល់អោយយើងនូវនិយមន័យខុសៗគ្នា ដែលជាហេតុធ្វើឱ្យយើងខ្ញុំមានការភាន់ច្រឡំលើអត្ថន័យនៃពាក្យនេះ ។ ដូច្នេះ វាគួរតែមាននិយមន័យរួមមួយអំពីពាក្យនេះដើម្បីអោយអ្នកយកទៅប្រើប្រាស់មានការយល់ឃើញដូចគ្នា ។"*

*យោបល់ក្រុមប្រឹក្សាឃុំ-សង្កាត់ដែលបានលើកឡើងក្នុងពេលសន្និសីទថ្នាក់ជាតិ*
*ស្តីពីវិមជ្ឈការ ឆ្នាំ២០០៦ ក្រោមប្រធានបទអភិបាលកិច្ចល្អ*

យោបល់របស់មន្ត្រីថ្នាក់ឃុំខាងលើ ជាឧទាហរណ៍មួយ បង្ហាញពីកង្វះខាតនូវការយល់ដឹងពីពាក្យគណនេយ្យភាពនៅកម្ពុជា បើទោះជាពាក្យនេះត្រូវបានប្រើយ៉ាងទូលំទូលាយ និងមានសារៈសំខាន់សំរាប់អភិបាលកិច្ចល្អ និងការអភិវឌ្ឍន៏ក៏ដោយ ។ អត្ថបទនេះសំដៅចូលរួមជាគំនិតបន្ថែម ដោយជួយបំភ្លឺលើចំណុចពីរៈ តើអ្វីទៅជាគណនេយ្យភាព ហើយធ្វើយ៉ាងណាដើម្បីពង្រឹងគណនេយ្យភាព ដោយផ្អែកតាមទ្រឹស្តី និងស្ថានភាពជាក់ស្តែងរបស់កម្ពុជា ។

## គណនេយ្យភាពមានអត្ថន័យយ៉ាងដូចម្តេច?

តាមការស្រាវជ្រាវ គណនេយ្យភាព[១] សំដៅដល់ទំនាក់ទំនងរវាងភាគីពីរ អាចជាមនុស្សពីរនាក់ឬស្ថាប័នពីរក្តី ដែលក្នុងនោះភាគីមួយ (ឧ. ភាគី "ក") ត្រូវមានការទទួលខុសត្រូវចំពោះភាគីម្ខាងទៀត (ឧ. ភាគី "ខ") ទៅលើភារកិច្ចអ្វីមួយ ។ តាមទ្រឹស្តី ដើម្បីអោយមានគណនេយ្យភាព ត្រូវមានលក្ខខណ្ឌ ៥ ដូចខាងក្រោមៈ ១) ភាគី "ក" ត្រូវទទួលបានការប្រគល់យ៉ាងច្បាស់លាស់ថា ខ្លួនត្រូវធ្វើភារកិច្ចអ្វី និងលើចំនុចណាខ្លះ ។ ប្រសិនបើគ្មានការប្រគល់

---

[១] គណនេយ្យភាពអាចសំដៅលើបញ្ហាផ្សេងៗគ្នា ។ សំរាប់អត្ថបទនេះ គណនេយ្យភាព គឺសំដៅដល់គណនេយ្យភាពដែលជួយដល់ប្រជាជនក្រីក្រ តាមរយៈធ្វើឱ្យប្រសើរឡើងនូវគុណភាពសេវាសាធារណៈនៅមូលដ្ឋាន ។ គួរចងចាំផងដែរថា អត្ថបទនេះមិនមែនអះអាងថា ប្រទេសកម្ពុជាគ្មានគណនេយ្យភាពនោះទេ តែប្រការសំខាន់គឺថាតើគណនេយ្យភាពដែលមានសព្វថ្ងៃនេះបំរើដល់ប្រយោជន៏ប្រជាជនក្រីក្រដែរឬទេ ឬក៏បំរើតែប្រយោជន៏របស់មនុស្សមួយចំនួនតូច ។ គោលបំណងរបស់អត្ថបទនេះ គឺចូលរួមបង្កើនចំណេះដឹងពីគណនេយ្យភាព តែផ្តោតសំខាន់ទៅលើប្រភេទគណនេយ្យភាពដែលបំរើដល់ប្រជាជនទូទៅ ជាពិសេសប្រជាជនក្រីក្រនៅតាមទីជនបទ ។

តួនាទីជាក់លាក់ទេនោះ អាចនឹងគ្មានគណនេយ្យភាព ព្រោះភាគី "ក" មិនប្រាកដថាខ្លួនទទួលខុសត្រូវលើអ្វីពិតប្រាកដ, ២) ភាគី "ក" ត្រូវទទួលបានធនធានគ្រប់គ្រាន់ សំរាប់ឱ្យខ្លួនមានលទ្ធភាពបំពេញភារកិច្ច ដែលបានប្រគល់ឱ្យ ។ ប្រសិនបើគ្មានធនធានទេ វាហាក់ដូចជាមិនសមហេតុផល ក្នុងការតំរូវឱ្យភាគី "ក" មានគណនេយ្យភាពចំពោះភារកិច្ចដែលប្រគល់ឱ្យ, ៣) ភាគី "ក" បន្ទាប់ពីបានទទួលធនធានហើយ ត្រូវតែមានសមត្ថភាពប្រើធនធានដើម្បីសំរេចភារកិច្ច, ៤) ភាគី "ក" ត្រូវរាយការណ៍ និងអះអាងដល់ភាគី "ខ" នូវភារកិច្ចដែលខ្លួនបានធ្វើ និង ៥) ភាគី "ខ" ត្រូវមានសិទ្ធិនិងមធ្យោបាយ ដើម្បីឱ្យជារង្វាន់ដល់ភាគី "ក" បើធ្វើការងារបានល្អ ឬដាក់ជាពិន័យដល់ភាគី "ក" ប្រសិនបើការងារធ្វើមិនបានល្អ ។

បន្ថែមពីនេះទៀត ពេលពិភាក្សាអំពីគណនេយ្យភាព យើងគួរចាប់ផ្តើមសួរសំណួរពីរៈ ទីមួយគឺ គណនេយ្យភាព របស់អ្នកណា ចំពោះអ្នកណា? ក្នុងនេះមានពីរករណី ១) គណនេយ្យភាពតាមខ្សែបណ្តោយ ដែលអាចចែកជាពីរគឺ គណនេយ្យភាពចំពោះអ្នកខាងក្រោម និងគណនេយ្យភាពចំពោះអ្នកខាងលើ និង ២) គណនេយ្យភាពតាមខ្សែទទឹង ។ ទីពីរគឺ គណនេយ្យភាពលើការងារអ្វី? ដែលក្នុងនេះ តាមបរិបទអភិបាលកិច្ច គេបែងចែកគណនេយ្យភាពទៅជាច្រើនប្រភេទសំខាន់ៗដូចមានរៀបរាប់នៅខាងក្រោមៈ

*គណនេយ្យភាពនយោបាយៈ* ចាំបាច់បំផុតសំរាប់សង្គមប្រជាធិបតេយ្យ និងសំដៅជាចំបងទៅលើគណនេយ្យភាពរបស់អ្នកនយោបាយ ចំពោះប្រជាជនដែលជាម្ចាស់ឆ្នោត ។ គណនេយ្យភាពប្រភេទនេះ ត្រូវអនុវត្តចំពោះប្រព័ន្ធគ្រប់ថ្នាក់ ទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ។ ឧទាហរណ៍ ក្រុមប្រឹក្សាឃុំត្រូវមានគណនេយ្យភាពបែបនយោបាយ ចំពោះប្រជាជននៅតាមមូលដ្ឋាន ព្រោះប្រជាជនជាអ្នកបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សា ។

*គណនេយ្យភាពរវាងភាគីពីរ*
- ការកំណត់ការងារច្បាស់លាស់
- ការផ្តល់ធនធានគ្រប់គ្រាន់
- សមត្ថភាពពេញលេញក្នុងការបំពេញការងារ
- ការជូនដំណឹងពីការអនុវត្តន៏ការងារ
- ការឱ្យរង្វាន់ ឬពិន័យ

***ទំនាក់ទំនងគណនេយ្យភាពអាច***
- ទៅលើ
- ចុះក្រោម
- តាមខ្សែទទឹង

*គណនេយ្យភាពអាចបែងចែកជាក្នុងលក្ខណៈ*
- នយោបាយ
- ការគ្រប់គ្រង
- ហិរញ្ញវត្ថុ

*គណនេយ្យភាពការគ្រប់គ្រងរដ្ឋបាលៈ* សំដៅដល់គណនេយ្យភាពរវាងភាគីផ្សេងៗ នៅក្នុងបរិបទនៃការងារគ្រប់គ្រងណាមួយ ។ ឧទាហរណ៍ជាក់ស្តែង ដូចជាគណនេយ្យភាពរវាងប្រធានមន្ទីរ និងមន្ត្រីក្រោមបង្គាប់ ឬរវាងមេឃុំ និងស្មៀន ។ គណនេយ្យភាពរវាងឃុំ ស្រុក និងខេត្ត ក៏ចាត់ជាគណនេយ្យភាពនៃការគ្រប់គ្រងដែរ ព្រោះពុំមានការបោះឆ្នោតប្រគល់ ឬផ្ទេរសិទ្ធិនយោបាយឡើយ ។

*គណនេយ្យភាពហិរញ្ញវត្ថុៈ* សំដៅជាពិសេសដល់ការតាមដាន និងរាយការណ៍ស្តីពីការបែងចែកថវិកា ការដកប្រាក់ ការប្រើប្រាស់ធនធានហិរញ្ញវត្ថុ ការធ្វើលទ្ធកម្ម សវនកម្ម និងកិច្ចការគណនេយ្យជាដើម ។ គណនេយ្យភាពប្រភេទនេះ ផ្តោតជាសំខាន់លើការគោរព ឬមិនគោរពរបស់ភាគីណាមួយ ចំពោះនីតិវិធីហិរញ្ញវត្ថុដែលបានដាក់ចេញ ។

គណនេយ្យភាពនៅក្នុងស្ថានភាពជាក់ស្តែង អាចស្មុគស្មាញ ជាងការដែលយើងគិតតាមទ្រឹស្តីខាងលើ ដោយសារបុគ្គលមួយ ទោះជារូបវន្តបុគ្គលក្តី ឬនីតិបុគ្គលក្តី ត្រូវមានគណនេយ្យភាពចំពោះបុគ្គលច្រើនគ្នា និងលើភារកិច្ច ឬបញ្ហាច្រើនមុខ ។ ឧទាហរណ៍ជាសាមញ្ញ មេឃុំម្នាក់អាចមានគណនេយ្យភាពដូចតទៅៈ ១) គណនេយ្យភាពចំពោះប្រជាជនមូលដ្ឋានលើកិច្ចការអភិវឌ្ឍន៍ និងជំរុញលទ្ធិប្រជាធិបតេយ្យតាមផ្លូវច្បាប់, ២) គណនេយ្យភាពចំពោះថ្នាក់លើ ដូចជា ស្រុក ខេត្ត និងក្រសួងមហាផ្ទៃ លើភារកិច្ចដែលត្រូវបានធ្វើប្រតិភូកម្មទៅឱ្យ ៣) គណនេយ្យភាពចំពោះគណបក្សនយោបាយរបស់គាត់ លើការបំពេញនិងចូលរួមក្នុងកិច្ចការបក្ស, ៤) គណនេយ្យភាពចំពោះក្រុមគ្រួសារទៅលើជីវភាព និងសុខមាលភាពរបស់សមាជិកក្រុមគ្រួសារគាត់ ។ល។ កាន់តែស្មុគស្មាញទៅទៀត ទំនាក់ទំនងគណនេយ្យភាពទាំងនេះ ពេលខ្លះផ្ទុយ និងប្រទាំងប្រទើសគ្នា ។ ឧទាហរណ៍ ពេលខ្លះប្រសិនបើមេឃុំខិតខំបំពេញគណនេយ្យភាពចំពោះគណបក្ស និងក្រុមគ្រួសារ គាត់អាចធ្វើឱ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់គណនេយ្យភាពចំពោះប្រជាជន ។ ដូច្នេះ នៅពេលពិភាក្សាពីគណនេយ្យភាពរបស់បុគ្គល ឬស្ថាប័នសាធារណៈណាមួយ សំខាន់ត្រូវធ្វើការកំណត់ឱ្យច្បាស់ថា តើយើងសង្កត់ធ្ងន់លើគណនេយ្យភាពរបស់បុគ្គលនោះចំពោះបុគ្គលឬស្ថាប័នណា និងទៅលើភារកិច្ចអ្វី? និងតើគណនេយ្យភាពណាមួយត្រូវចាត់ទុកជាអាទិភាព? ជាក់ស្តែង នៅក្នុងបរិបទអភិបាលកិច្ចល្អនៅថ្នាក់មូលដ្ឋាន មេឃុំនៅក្នុងឧទាហរណ៍របស់យើង ត្រូវមានគណនេយ្យភាពជាបឋម ចំពោះប្រជាពលរដ្ឋ ទៅលើកិច្ចការអភិវឌ្ឍន៍ និងជំរុញលទ្ធិប្រជាធិបតេយ្យ ។

## ធ្វើយ៉ាងណាដើម្បីពង្រឹងគណនេយ្យភាពនៅក្នុងកិច្ចការអភិបាលកិច្ចល្អ?

បើគ្រាន់តែប្រជាជនមានសិទ្ធិធ្វើការបោះឆ្នោតរៀងរាល់ ៤ ឬ ៥ឆ្នាំម្តងនោះ ពិតជាមិនគ្រប់គ្រាន់នឹងធានាថា រដ្ឋាភិបាលនោះនឹងបំរើប្រជាជនវិញ ប្រកបដោយគណនេយ្យភាពឡើយ ។ សំខាន់ត្រូវមានស្ថាប័ន និងយន្តការរឹងមាំ ដើម្បីជំរុញឱ្យរដ្ឋាភិបាលមានលទ្ធភាពបំរើរាស្ត្រ និងឱ្យប្រជាជនមានលទ្ធភាពទាមទារគណនេយ្យភាពពីរដ្ឋាភិបាល ប្រសិនបើមិនបានបំរើរាស្ត្រ ។ តាមការស្រាវជ្រាវ មានអ្នកប្រាជ្ញជាច្រើនបានគិតគូរលើបញ្ហាថាតើធ្វើយ៉ាងណា ដើម្បីធានាឱ្យមានគណនេយ្យភាពនៅក្នុងរបបប្រជាធិបតេយ្យមួយ ។ ដំបូងត្រូវរៀបចំឱ្យមានវិស័យសាធារណៈមួយដែលរឹងមាំ ។ សង្គមវិទូជនជាតិអាល្លឺម៉ង់ម្នាក់ឈ្មោះ ម៉ាក វិបប៊ើ នាដើមសតវត្សរ៍ទី២០ បានអះអាងថា ដើម្បីគ្រប់គ្រងវិស័យសាធារណៈមួយឱ្យបានល្អ គេត្រូវបង្កើតនូវក្បាលម៉ាស៊ីនការិយាធិបតេយ្យមួយ ដែលមិនរងឥទ្ធិពលពីក្បាលម៉ាស៊ីននយោបាយ (ពោលគឺបែងចែកឱ្យដាច់រវាងមន្ត្រីនយោបាយ និងមន្ត្រីបច្ចេកទេសនៅក្នុងរដ្ឋាភិបាល) និងស្ថិតក្រោមច្បាប់សាកលមួយ ។ តាមទ្រឹស្តីនេះ គណនេយ្យភាពក្នុងការគ្រប់គ្រងវិស័យសាធារណៈ នឹងត្រូវបង្កើត

និងពង្រឹង តាមរយៈការដាក់ច្បាប់ កំណត់តួនាទី ការផ្តល់ធនធាន និងសមត្ថភាពដែលសមស្របជាមួយនឹងការអនុវត្តន៍យ៉ាងតឹងរ៉ឹងនូវច្បាប់ទាំងនោះ (ឧ. ឱ្យរង្វាន់សំរាប់មន្ត្រីល្អ និងដាក់ពិន័យសំរាប់មន្ត្រីដែលប្រព្រឹត្តខុស) ។ ទ្រឹស្តីខាងលើត្រូវបានយកមកអនុវត្តយ៉ាងទូលំទូលាយ និងបង្កើតជាមូលដ្ឋានគ្រឹះនៃវិស័យសាធារណៈ ទាំងនៅប្រទេសជឿនលឿន និងប្រទេសកំពុងអភិវឌ្ឍន៍ ។ ទ្រឹស្តីនេះត្រូវបានយកមកប្រើដំបូងនៅកម្ពុជា នៅពេលបារាំងបានមកដាក់អាណានិគមលើប្រទេសយើង ។ ការបង្កើតឱ្យមានរចនាសម្ព័ន្ធរដ្ឋាភិបាលដូចដែលឃើញសព្វថ្ងៃ តួយ៉ាងដូចជា មានរចនាសម្ព័ន្ធក្រសួង មន្ទីរនានា មានមន្ត្រី មានប្រាក់បៀវត្សរ៍ រាជការមានច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការ ។ល។ សុទ្ធតែជាឧទាហរណ៍ជាក់ស្តែងនៃទ្រឹស្តីខាងលើ មកលើការគ្រប់គ្រងវិស័យសាធារណៈនៅកម្ពុជា ។

ទ្រឹស្តីរដ្ឋបាលសាធារណៈដូចរៀបរាប់ខាងលើ អាចដំណើរការបានល្អ លុះត្រាតែលក្ខខណ្ឌសំខាន់ៗដូចខាងលើ ត្រូវបានបំពេញ ។ ជាអកុសល ប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើនដែលយកទ្រឹស្តីនេះមកប្រើ ច្រើនមិនអាចបំពេញនូវរាល់លក្ខខណ្ឌទាំងនេះបានទេ ។ ជាក់ស្តែង ក្បាលម៉ាស៊ីនការិយាធិបតេយ្យនៅក្នុងប្រទេសទាំងនោះច្រើនត្រូវបានជ្រៀតជ្រែកដោយឥទ្ធិពលនយោបាយ និងក្រុមបក្សពួកមានអំណាច បូកបន្ថែមទាំងបញ្ហាខ្វះធនធាន និងសមត្ថភាពសំរាប់ដំណើរការងារគ្រប់គ្រងរដ្ឋបាល ។ លើសពីនេះ ក្បាលម៉ាស៊ីនប្រជាធិបតេយ្យតាមទ្រឹស្តីខាងលើត្រូវបានទិតៀនថា ពេលខ្លះមានលក្ខណៈរឹងត្អឹង សង្កត់ធ្ងន់ជ្រុលលើការគោរពគ្រប់ចំណុចនៃច្បាប់ និងនីតិវិធីផ្សេងៗ ជាជាងសង្កត់ធ្ងន់លើការសំរេចលទ្ធផលជាក់ស្តែង ។ និយាយម្យ៉ាងទៀត គណនេយ្យភាពតាមការគ្រប់គ្រងក្នុងទ្រឹស្តីនេះ ឱ្យទំងន់ខ្លាំងទៅលើការគោរពតាមក្បួនច្បាប់ជាធរមាន ជាជាងលើការសំរេចលទ្ធផលជាក់ស្តែង ។

ដើម្បីឆ្លើយតបទៅនឹងកង្វះខាតខាងលើ ទ្រឹស្តីគ្រប់គ្រងបែបថ្មីមួយក្នុងវិស័យសាធារណៈ ត្រូវបានបង្កើតឡើងនៅក្នុងទសវត្សរ៍ទី ៥០ ។ ទ្រឹស្តីថ្មីនេះទទួលបានគំនិតជាច្រើនពីគ្រូធំខាងទ្រឹស្តី "ការគ្រប់គ្រង" ឈ្មោះ ភីទើ ថ្រាក់ឃើ ។ ទ្រឹស្តីថ្មីនេះអះអាងថា ដើម្បីពង្រឹងគណនេយ្យភាពនៅក្នុងវិស័យសាធារណៈ សំខាន់គេត្រូវគ្រប់គ្រងវិស័យសាធារណៈ ឱ្យដូចជាក្នុងវិស័យឯកជន ដែលទូទៅគេមើលឃើញថាមានប្រសិទ្ធភាព និងផលិតភាពខ្ពស់ជាង ហើយបើធ្វើយ៉ាងនេះបាន គេនឹងអាចកាត់បន្ថយភាពអសកម្ម និងការខ្ជះខ្ជាយធនធានរដ្ឋ ។ ទ្រឹស្តីនេះជំរុញឱ្យមានការធ្វើឯកជនភាវូបនីយកម្ម ជួលក្រុមហ៊ុនឯកជនឱ្យធ្វើការងារសាធារណៈ ជំរុញឱ្យមានកំណែទំរង់រចនាសម្ព័ន្ធរាជការស៊ីវិល ដោយសង្កត់ធ្ងន់ជាចំបងលើលទ្ធផលជាជាងលើដំណើរការការងារ ព្រមទាំងពង្រឹងការសហការរវាងភាគីរដ្ឋាភិបាល និងភាគីមិនមែនរដ្ឋាភិបាល ។ ទ្រឹស្តីក៏ជំរុញឱ្យមានការផ្តល់ឆន្ទានុសិទ្ធិ និងការលើកទឹកចិត្តច្រើន និងបែបថ្មីៗថែមទៀត ដល់អ្នកគ្រប់គ្រងនៅក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ហើយជំរុញឱ្យមន្ត្រីទាំងនោះមើលមកប្រជាជនឱ្យដូចជា "អតិថិជន" របស់ខ្លួន ។ ក្នុងន័យនេះ រដ្ឋាភិបាលគួរដើរតួជា "អ្នកកាច់ចង្កូត ជាជាងអ្នកអុំ" នៅក្នុងកិច្ចការផ្តល់សេវាដល់ប្រជាជន ។ គួរសំគាល់ថា ទ្រឹស្តីថ្មីនេះ មិនមែនប៉ងជំនួសទ្រឹស្តីទីមួយទេ ប៉ុន្តែធ្វើការកែតំរូវ និងបំពេញបន្ថែមលើទ្រឹស្តីទីមួយ ។

ការអនុវត្តន៍ទ្រឹស្តីថ្មីនេះ ត្រូវបានប្រើយ៉ាងជោគជ័យនៅប្រទេសមួយចំនួន តួយ៉ាងដូចជាចក្រភពអង់គ្លេស ប្រទេសអូស្ត្រាលី និងប្រទេសនីវែលហ្សេឡង់ ។ នៅកម្ពុជា ការអនុវត្តន៍ទ្រឹស្តីនេះ ត្រូវបានស្តែងចេញឡើងតាមរយៈការធ្វើឯកជនភាវូបនីយកម្ម ការដេញថ្លៃឱ្យក្រុមហ៊ុនឯកជន និងអង្គការមិនមែនរដ្ឋាភិបាលបំពេញការងារសាធារណៈ ដូចជានៅក្នុងវិស័យសុខាភិបាល និងការផ្សព្វផ្សាយកសិកម្ម ។ល។ ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល មានទំនោរនឹងប្រើការគ្រប់គ្រងតាមការគ្រប់គ្រងបែបថ្មីនេះ ។ ប៉ុន្តែការមន្ទិលនៅតែមានថា តើទ្រឹស្តីនេះនឹងមានប្រសិទ្ធភាពប៉ុណ្ណានៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដូចជា កម្ពុជា ។ អ្នកជំនាញខ្លះលើកឡើងថា អាចនឹង

*ដើម្បីពង្រឹងគណនេយ្យភាព ក្នុងអភិបាលកិច្ចល្អ*

- ពង្រឹងការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យតាមរយៈការបោះឆ្នោត
- ពង្រឹងការគ្រប់គ្រងសាធារណៈ និងក្បាលម៉ាស៊ីន ការិយាធិបតេយ្យ តាមការធ្វើកំណែទំរង់
- ជំរុញឱ្យមានការចូលរួមពីវិស័យឯកជន និងសង្គមស៊ីវិលក្នុងការផ្តល់សេវា និងកិច្ចការអភិវឌ្ឍន៍
- ធ្វើវិមជ្ឈការទាំងនយោបាយ និងរដ្ឋបាល
- ពង្រឹងលទ្ធភាពរបស់ប្រជាជន និងសង្គមស៊ីវិល ក្នុងការទាមទារ គណនេយ្យភាពពីរដ្ឋាភិបាល

មិនទទួលបានជោគជ័យនៅប្រទេសកំពុងអភិវឌ្ឍន៍ឡើយ ព្រោះប្រទេសទាំងនេះនៅមិនទាន់មានរចនាសម្ព័ន្ធវិស័យសាធារណៈ និងប្រព័ន្ធទីផ្សារសេរីមួយដែលរឹងមាំ ។ មួយវិញទៀត ការគ្រប់គ្រងតាមបែបថ្មីនេះ នឹងជំរុញឱ្យមានគណនេយ្យភាពបែបចង្អៀតមួយ កាត់បន្ថយការសហការណ៏រវាងភាគីដែលពាក់ព័ន្ធ ព្រោះថាភាគីនីមួយៗ ដែលមានតួនាទីផ្តល់សេវាកម្ម (ឧ. ភ្នាក់ងាររដ្ឋាភិបាល ក្រុមហ៊ុនឯកជន និងអង្គការមិនមែនរដ្ឋាភិបាល) នឹងផ្តោតតែលើការងារដែលស្ថិតក្រោមសមត្ថកិច្ចនិងទំនួលខុសត្រូវរបស់ខ្លួន ហើយមិនសូវអើពើក្នុងការសហការណ៏ជាមួយភាគីផ្សេងទៀត ។

និន្នាការសំខាន់មួយទៀត ក្នុងការពង្រឹងគណនេយ្យភាព គឺការជំរុញឱ្យមានវិមជ្ឈការ ។ ដោយប្រតិបត្តិទៅតាមគោលការណ៏ "បង្វិតអ្នកផ្តល់សេវាទៅជិតអ្នកប្រើប្រាស់" វិមជ្ឈការលើកហេតុផលថា មុខងារអំណាច និងធនធាន គួរតែផ្តល់អោយទៅរដ្ឋាភិបាលថ្នាក់ក្រោមបំផុត ដែលមានសមត្ថភាពអនុវត្តមុខងារនោះបាន ។ នៅពេលរដ្ឋខិតជិតនឹងប្រជាជន ពួកគេអាចយល់ពីតំរូវការរបស់ពួកគាត់បានច្រើនជាង ហើយប្រជាជនក៏ងាយនឹងដឹងពីការខិតខំរបស់រដ្ឋវិញដែរ ។ នៅកម្ពុជាយើង ការបោះឆ្នោតឃុំនៅឆ្នាំ២០០២ គឺជាការធ្វើវិមជ្ឈការ ដើម្បីនាំយករដ្ឋឱ្យខិតជិតនឹងប្រជាជន ។ វិមជ្ឈការនេះ បានជំរុញឱ្យមានប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន និងឱ្យប្រជាជនបានចូលរួមក្នុងកិច្ចការអភិវឌ្ឍន៍នៅក្នុងតំបន់របស់ខ្លួន ។ ថ្មីៗនេះ រាជរដ្ឋាភិបាលបានកំពុងដំណើរការវិសហមជ្ឈការដល់ថ្នាក់ខេត្ត និងស្រុកទៀត ក្នុងបំណងធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែមានតួនាទី និងធនធានច្រើនជាងមុនក្នុងការផ្តល់សេវាកម្មដល់ប្រជាជន ។

មួយវិញទៀត ការពង្រឹងគណនេយ្យភាពពុំមែនសំដៅតែលើការពង្រឹងវិស័យសាធារណៈរបស់រដ្ឋាភិបាលនោះទេ ។ ប្រជាជនខ្លួនឯងក៏មានតួនាទីមិនអាចខ្វះបាន នៅក្នុងកិច្ចការនេះដែរ ហើយត្រូវតែមានការខិតខំ និងយន្តការដែលផ្តល់ឱ្យពួកគាត់នូវលទ្ធភាពដើម្បីដឹង និងចូលរួមទាមទារគណនេយ្យភាពពីរដ្ឋាភិបាលមកវិញ ។ គំនិតនេះគេហៅថា គណនេយ្យភាពសង្គម ។ យន្តការមួយចំនួនត្រូវបានប្រើដើម្បីពង្រឹងគណនេយ្យភាពសង្គម ដូចជាជួយឱ្យសំលេងរបស់ប្រជាជនបានលឺដល់រដ្ឋាភិបាល ការអនុញ្ញាតឱ្យមានការតវ៉ាដោយអហឹង្សា ការតស៊ូមតិ ការពង្រឹងក្រុមអង្គការមិនមែនរដ្ឋាភិបាល ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ដូចជា វិទ្យុ ទូរទស្សន៏ កាសែត ដើម្បីឱ្យប្រជាជនបានជ្រួតជ្រាបពីការងាររបស់រដ្ឋ និងការតំរូវឱ្យមានការចូលរួមក្នុងការងារអភិវឌ្ឍន៍ជាដើម ។

## តើការពង្រឹងគណនេយ្យភាព នៅក្នុងបរិបទនៃប្រទេសកម្ពុជាមានសភាពយ៉ាងណាដែរ?

បន្ទាប់ពីរ៉ាយរ៉ាប់ពីគំនិត និងទ្រឹស្តីសំខាន់ក្នុងការពង្រឹងគណនេយ្យភាព ចំណុចមួយដែលត្រូវកត់សំគាល់គឺថា គំនិតទាំងនេះភាគច្រើនត្រូវបានតាក់តែងដោយប្រទេសលោកខាងលិច ហើយយកមកអនុវត្តក្នុងប្រទេសកម្ពុជា ។ ដូច្នេះ អ្វីដែលអះអាងថាជោគជ័យក្នុងទ្រឹស្តី អាចនឹងត្រូវបរាជ័យនៅពេលអនុវត្តជាក់ស្តែង ។ វាប្រៀបដូចជាការប្រើឱសថ ដែលគេយកមកព្យាបាលកង្វះខាតគណនេយ្យភាពនៅកម្ពុជាដូច្នោះដែរ ។ គុណភាពឱសថគ្រាន់តែកត្តាមួយប៉ុណ្ណោះ សំខាន់មួយទៀតគឺថា តើវាត្រូវគ្នានឹងស្ថានភាពជាក់ស្តែងក៏រិតណា? ម្យ៉ាងវិញទៀត ការធ្វើអភិបាលកិច្ចលើប្រទេសមួយ ពុំមែនក៏រិតតែលើការអនុវត្តន៏តាមទ្រឹស្តីដែលនាំចូលមកពីខាងក្រៅនោះឡើយ ។ តាមពិតទៅកត្តាមនុស្ស សង្គម វប្បធម៌ ប្រពៃណី និងប្រវត្តិសាស្ត្រដែលមានស្រាប់របស់ប្រទេសនោះ ក៏ដើរតួសំខាន់ដែរក្នុងការគ្រប់គ្រងប្រទេស បើទោះជាចំណុចខ្លះមិនមានចែងជាសំណេរជាក់ច្បាស់ក៏ដោយ ។

ជាក់ស្តែង ប្រទេសកម្ពុជាយើងបានយកមកប្រើភាគច្រើននូវគំនិត និងទ្រឹស្តីខាងលើ តែក្នុងការអនុវត្តន៏អភិបាលកិច្ចរបស់យើងប្រៀបដូចជាមានប្រព័ន្ធពីរដែលដើរទន្ទឹមគ្នា ឬពេលខ្លះច្របាច់បញ្ចូលគ្នា: ទីមួយគឺប្រព័ន្ធរដ្ឋដែលតាក់តែងតាមទ្រឹស្តី និងមួយទៀតជាប្រព័ន្ធក្រៅផ្លូវការអនុវត្តតាមបែបបណ្តាញស្គាល់គ្នារវាងបុគ្គលតាមរយៈខ្សែ-ខ្នង ។ តាមការស្រាវជ្រាវ ប្រព័ន្ធក្រៅផ្លូវការនេះមានឥទ្ធិពលណាស់ ហើយរីកសុះសាយប្រទាក់ក្រឡាពីមួយទៅមួយ ពីលើទៅក្រោម (ឧ. ពីថ្នាក់ជាតិ ទៅថ្នាក់ក្រោមជាតិ) និងពីក្នុងទៅក្រៅរដ្ឋាភិបាល (ឧ. រវាងមន្ត្រីរដ្ឋាភិបាល និងអ្នកជំនួញ) ។

តាមពិត បណ្តាញខ្សែ-ខ្នងមានកើតឡើងជាធម្មតា ទោះក្នុងសង្គមណាក៏ដោយ ព្រោះមនុស្សជាភាវៈសង្គម ត្រូវការប្រាស្រ័យទាក់ទងជួយគ្នាទៅវិញទៅមក ។ មានការសិក្សាជាច្រើនអំពីប្រព័ន្ធខ្សែ-ខ្នងនេះនៅប្រទេសនានា ហើយកំណត់បានជាចរិតលក្ខណៈរួមមួយចំនួន បើទោះថាមានភាពខុសគ្នាខ្លះៗទៅតាមស្ថានភាពនីមួយៗក៏ដោយ ។ ជាទូទៅនៅក្នុងបណ្តាញនោះ មានខ្នង និងអ្នកក្រោមគាត់ ។ ភាគច្រើនខ្នង និងអ្នកក្រោមគាត់សហការគ្នាជាបុគ្គល និងបុគ្គលដោយពុំឈរលើការយល់ព្រមជាផ្លូវការណាឡើយ ហើយអ្នកក្រោមជួយរកប្រយោជន៏ឱ្យខ្នង ជាថ្នូរនឹងលាភសក្ការៈផ្សេងៗមកវិញ ។ ប៉ុន្តែជាទូទៅខ្នងមានអ្នកក្រោមច្រើន ហើយទទួលលទ្ធផលច្រើនពីបណ្តាញនោះ ។ នេះប្រៀបដូចជាពាក្យខ្មែរថា "ត្រីចង្វារចិញ្ចឹមត្រីឆ្តោ" ។ ក្នុងករណីខ្លះ ទំនាក់ទំនងរវាងខ្នង និងអ្នកក្រោមអាចកើតឡើង ដោយសារហេតុផលមនោសញ្ចេតនា ដូចជាបងប្អូន មិត្តភក្តិអនុស្សាវរីយ៏កំសត់កំរពីអតីតកាល ។ល។ ការស្មោះត្រង់ និងកត្តាមនោសញ្ចេតនាទាំងនេះ ដើរតួសំខាន់ណាស់នៅក្នុងការធានាឱ្យមានស្ថិរភាពរបស់បណ្តាញខ្សែ-ខ្នង ។ លើសពីនេះទៀត បណ្តាញខ្សែ-ខ្នង អាចរីកសុះសាយដោយមានជាច្រើនជាន់ ច្រើនថ្នាក់ និងច្រើនក្រុម ពោលគឺខ្នងនៅថ្នាក់មួយ អាចជាអ្នកក្រោមរបស់ខ្នងនៅថ្នាក់លើមួយទៀត ហើយអ្នកនៅកាន់តែខាងលើ នឹងកាន់តែបានលាភសក្ការៈច្រើន ជាងអ្នកខាងក្រោម ប្រៀបដូចជារាងពីរ៉ាមីត ។

កត្តាប្រវត្តិសាស្ត្រ វប្បធម៌ សាសនា និងប្រពៃណី ក៏ជះឥទ្ធិពលដល់ចរិតលក្ខណៈ និងដំណើរការរបស់បណ្តាញខ្សែ-ខ្នងដែរ ។ ឧទាហរណ៏ ការសិក្សានានាបានបង្ហាញថា ជាប្រវត្តិសាស្ត្រ កម្ពុជាមាននិន្នាការប្រមូលផ្តុំអំណាចរដ្ឋលើបុគ្គល ជាជាងលើតួនាទីផ្លូវច្បាប់ ។ ទោះនៅក្នុងសម័យអង្គរក្តី ឬសម័យក្រោយអាណានិគមនិយមបារាំងក្តី មេដឹកនាំយើង មាននិន្នាការប្រមូលផ្តុំអំណាចជុំវិញខ្លួន ហើយជំលោះច្រើនកើតមានដោយការប្រជែង

អំណាចរវាងក្រុមមនុស្សដែលស្មោះស្ម័គ្រនឹងបុគ្គលណាមួយនោះ ។ ប្រជាជននៅតាមមូលដ្ឋានឯណោះវិញ ក៏ទំលាប់រស់នៅពឹងពាក់លើខ្នង ដើម្បីជួយសំរាលនូវធុរៈសេដ្ឋកិច្ច និងសន្តិសុខរបស់ខ្លួន ។ ប្រវត្តិសាស្ត្រសង្គ្រាម និងហិង្សានាពេលថ្មីនេះ បានជំរុញឱ្យប្រជាជនទូទៅកាន់តែត្រូវរកខ្នង និងបញ្ចូលខ្លួនទៅក្នុងបណ្តាញណាមួយ ដើម្បីជារនាំងការពារខ្លួន ។

ដោយវិភាគទៅលើការពិភាក្សាខាងលើ ប្រព័ន្ធអភិបាលកិច្ចបច្ចុប្បន្នរបស់កម្ពុជាយើង គឺជាការច្របាច់បញ្ចូលគ្នារវាងប្រព័ន្ធគ្រប់គ្រងសាធារណៈតាក់តែងតាមគំនិត និងទ្រឹស្តីលោកខាងលិច ជាមួយនឹងបណ្តាញខ្សែ-ខ្នងដ៏មានឥទ្ធិពលមួយ ។ ជាលទ្ធផល យើងបានប្រព័ន្ធគ្រប់គ្រងរដ្ឋមួយ ដែលមើលពីខាងក្រៅដូចជាដើរតាមច្បាប់ និងនីតិវិធីនានា តែជាក់ស្តែងត្រូវបានគ្រប់ដណ្តប់ដោយបុគ្គលមានអំណាច និងបណ្តាញដ៏ខ្លាត់ខ្វែងរបស់ពួកគេ ។ កត្តានយោបាយ ក៏ត្រូវបានគេមើលឃើញថាដើរតួនាទីសំខាន់ជំរុញឱ្យមានបណ្តាញខ្សែ-ខ្នង ហើយធ្វើការជ្រៀតជ្រែកលើស្ទើរគ្រប់ទិដ្ឋភាព និងលំដាប់ថ្នាក់នៃក្បាលម៉ាស៊ីនការិយាធិបតេយ្យ ។ ស្ថានភាពបែបនេះបង្កឱ្យមានផលអវិជ្ជមាន ជាជាងវិជ្ជមាន ។ ជាពិសេស វាជំរុញឱ្យមានការប្រព្រឹត្តអំពើពុករលួយ ដែលមានលក្ខណៈជាប្រព័ន្ធ និងជាមូលហេតុចំបង នាំឱ្យមានការបាត់បង់ចំណូលរដ្ឋ សេវាកម្មសាធារណៈទន់ខ្សោយ ហើយបន្តិចម្តងៗ នឹងនាំទៅដល់ការបាត់បង់ជំនឿពីសំណាក់ប្រជាពលរដ្ឋលើស្ថាប័នរដ្ឋ ។

## សេចក្តីបញ្ចប់

ជាសង្ខេប គណនេយ្យភាពជាធាតុសំខាន់នៅក្នុងកិច្ចការអភិបាលកិច្ច និងអភិវឌ្ឍន៍ ប៉ុន្តែការយល់ដឹងអំពីពាក្យនេះនៅមានកំរិត និងខុសៗគ្នា ដែលអាចនាំមានការភាន់ច្រឡំនៅពេលធ្វើការតាក់តែង និងអនុវត្តន៍គោលនយោបាយ ។ ដោយសារពាក្យនេះអាចប្រើបាននៅក្នុងន័យច្រើន ចាំបាច់ត្រូវមានការបែងចែកឱ្យបានច្បាស់លាស់ថា តើពេលយើងនិយាយពីគណនេយ្យភាព យើងសំដៅដល់អ្វីពិតប្រាកដ ។ ដូច្នេះគួរមានការកំណត់រួមគ្នាមួយអំពីនិយមន័យ និងគោលគំនិតរបស់ពាក្យនេះ ហើយថា តើវាមានផលប៉ះពាល់យ៉ាងណាខ្លះដល់អភិបាលកិច្ចនៅកម្ពុជា ។ ជាការពិតហើយថា គោលគំនិតនៃគណនេយ្យភាពភាគច្រើនត្រូវបាននាំចូលពីបរទេស ។ ភារកិច្ចចំបងរបស់អ្នកអភិវឌ្ឍន៍ គឺត្រូវស្វែងយល់ថា ត្រូវទទួលយក និងកែប្រែគោលគំនិតត្រឹមកំរិតណា ដើម្បីអោយការអនុវត្តន៍មានភាពសមស្របទៅតាមបរិបទរបស់ប្រទេសយើង ។ ចំណុចសំខាន់មួយទៀតគឺ ការយល់ដឹងឱ្យបានច្បាស់ពីតំលៃសង្គម វប្បធម៌ ប្រវត្តិសាស្ត្រ និងនយោបាយរបស់ខ្មែរយើង និងថា តើតំលៃនេះជួយគាំទ្រ ឬរារាំងដល់ការសំរេចបាននូវគណនេយ្យភាព ។ ចុងក្រោយគឺថា ទោះជាយើងខិតខំពង្រឹងគណនេយ្យភាពតាមវិធីណាក៏ដោយ ក៏យើងត្រូវចងចាំឱ្យច្បាស់ក្នុងចិត្តថា គណនេយ្យភាពនោះគឺដើម្បីជួយលើកកំពស់ជីវភាពរបស់ប្រជាជនក្រីក្រ ។

# បញ្ជីឯកសារពិភាក្សារបស់ វបសអ

១. Kannan,K.P. ( វិច្ឆិកា១៩៩៥) *ការកសាងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សំរាប់ប្រទេសកម្ពុជាៈ ការពិនិត្យឡើងវិញលើការអនុវត្តន៍នាពេលបច្ចុប្បន្ន និងការលើកមតិកែលំអ* ( ឯកសារពិភាក្សាលេខ ១) ។

២. McAndrew, John P. ( មករា ១៩៩៦) *ជំនួយហូរចូលជំនួយស្រពិចស្រពិលៈ ជំនួយសង្គ្រោះ និងអភិវឌ្ឍន៍ទ្វេនិងពហុភាគី ១៩៩២-៩៥* ( ឯកសារពិភាក្សាលេខ ២) ។

៣. Kannan, K. P. ( មករា ១៩៩៧) *កំណែទំរង់សេដ្ឋកិច្ច កំណែតម្រូវរចនាសម្ព័ន្ធនិងការអភិវឌ្ឍន៍កម្ពុជា* ( ឯកសារពិភាក្សាលេខ ៣) ។

៤. ជីម-ចរិយា ស្រ៊ុន-ពិចូ សូ-សុវណ្ណារិទ្ធ ចន-ម៉ាកឃិនឌ្រូ ងួន-សុគន្ធា ប៊ុន-ដូរីណា និងរ៉ូប៊ីន-ប៊ីដឺលវី ( មិថុនា ១៩៩៨) *ការរៀនសូត្រពីកម្មវិធីអភិវឌ្ឍន៍ជនបទក្នុងប្រទេសកម្ពុជា* ( ឯកសារពិភាក្សាលេខ ៤) ជាខ្មែរថ្លៃ ៩.០០០រៀល ។

៥. Toshiyasu-Kato ច័ន្ទ-សុផល និងឡុង-វូ-ពិសិដ្ឋ ( កញ្ញា ១៩៩៨) *សមាហរណកម្មសេដ្ឋកិច្ចតំបន់សំរាប់ការអភិវឌ្ឍន៍ជានិរន្តរ៍ក្នុងប្រទេសកម្ពុជា* ( ឯកសារពិភាក្សាលេខ ៥) ជាភាសាខ្មែរ តំលៃ ៩.០០០រៀល ។

៦. Murshid,K.A.S. ( ធ្នូ១៩៩៨) *សន្តិសុខស្បៀងនៅក្នុងសេដ្ឋកិច្ចអន្តរៈអាស៊ីៈ បទពិសោធន៍កម្ពុជា*( ឯកសារពិភាក្សាលេខ ៦) ជាភាសាខ្មែរតំលៃ ៧.៥០០រៀល ។

៧. McAndrew, John P. ( ធ្នូ ១៩៩៨) *ការពឹងពាក់គ្នាទៅវិញទៅមកក្នុងយុទ្ធសាស្ត្រចិញ្ចឹមជីវិតគ្រួសារនៅក្នុងភូមិខ្មែរពីរ* ( ឯកសារពិភាក្សាលេខ ៧) ជាភាសាខ្មែរតំលៃ ៧.៥០០រៀល ។

៨. ច័ន្ទ-សុផល Martin-Godfrey, Toshiyasu-Kato ឡុង-វូ-ពិសិដ្ឋ Nina-Orlova, Per-Ronnås ទា-សាវ៉ា ( មករា ១៩៩៩) *ប្រទេសកម្ពុជាៈ បញ្ហាប្រឈមមុខនៃការបង្កើតការងារដែលមានផលិតភាព* ( ឯកសារពិភាក្សាលេខ ៨) ជាភាសាខ្មែរ តំលៃ ៦.០០០រៀល ។

៩. តេង-យូគី ប៊ុន-ដូរីណា សូ-សុវណ្ណារិទ្ធ និង ចន-ម៉ាកឃិនឌ្រូ ( មេសា ១៩៩៩) *បទពិសោធន៍របស់សកម្មភាពសហគមន៍ដើម្បីអភិវឌ្ឍន៍សង្គមនៃអង្គការយូនីសេហ្វ* ( ឯកសារពិភាក្សាលេខ ៩) ជាភាសាខ្មែរតំលៃ ៤.៥០០រៀល ។

១០. Gorman, Siobhan, ជាមួយ ប៊ុន-ដូរីណានិងសុខ-ខេង ( មិថុនា១៩៩៩) *បញ្ហាតួនាទីបុរស-ស្ត្រីនិងការអភិវឌ្ឍន៍នៅប្រទេសកម្ពុជាៈ ការពិនិត្យមើលជាទូទៅ* ( ឯកសារពិភាក្សាលេខ១០) ជាភាសាខ្មែរតំលៃ ៤.៥០០រៀល ។

១១. ច័ន្ទ-សុផល និង សូ-សុវណ្ណារិទ្ធ ( មិថុនា ១៩៩៩) *ចំណាកពលកម្មកម្ពុជាទៅប្រទេសថៃៈ ការប៉ាន់ស្មានជំហានដំបូង* ( ឯកសារពិគ្រោះលេខ ១១) ជាភាសាខ្មែរតំលៃ ៣.០០០រៀល ។

១២. ច័ន្ទ-សុផល Toshiyasu Kato ឡុង-វូពិសិដ្ឋ ទា-សាវ៉ា សូ-សុវណ្ណារិទ្ធ ហង់-ជួនណារ៉ុន កៅ-គឹមហួន និង ជា-វុធណា ( តុលា ១៩៩៩) *ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុអាស៊ីលើសេដ្ឋកិច្ចអន្តរកាលនៅបណ្តាប្រទេសអាស៊ីអគ្នេយ៍ៈ ទស្សនៈកម្ពុជា* ( ឯកសារពិគ្រោះលេខ ១២) ជាភាសាខ្មែរតំលៃ ៤.៥០០រៀល ។

១៣. អ៊ុង-ប៊ុនឡេង (សីហា ២000) *ការប្រែប្រួលតាមរដូវកាលនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ១៣) ជាភាសាខ្មែរតំលៃ ៣.000រៀល ។

១៤. Toshiyasu-Kato Jeffrey A. Kaplan, ច័ន្ទ-សុផល និង រៀល-សុភាព (សីហា ២000) *ប្រទេសកម្ពុជា: លើកកំពស់អភិបាលកិច្ចសំរាប់ការអភិវឌ្ឍន៍មាននិរន្តរភាព* (ឯកសារពិភាក្សាលេខ ១៤) ជាភាសាខ្មែរ តំលៃ ៣.000រៀល ។

១៥. Toshiyasu Kato, ច័ន្ទ-សុផល Jeffrey A. Kaplan, (សីហា ២000) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាពនៅក្នុងសេដ្ឋកិច្ចមួយដែលពឹងផ្អែកលើជំនួយ: បទពិសោធន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ១៥) ជាភាសាខ្មែរ តំលៃ ១0.000រៀល ។

១៦. ស៊ិក បូរ័ក្ស (ធ្នូ ២000) *កម្មសិទ្ធិ ការលក់ដូរ និងការប្រមូលផ្តុំដីធ្លីនៅកម្ពុជា: ការពិនិត្យវិភាគដោយត្រួសៗនូវទិន្នន័យទីពីរ និងទិន្នន័យដើម ដែលបានមកពីអង្កេតថ្មីៗចំនួនបួន* (ឯកសារពិភាក្សាលេខ ១៦) ជាភាសាខ្មែរថ្លៃ ៨.000រៀល ។

១៧. ច័ន្ទ-សុផល សូ-សុវណ្ណារិទ្ធ និងប៊ុន-ដូរីណា (មិថុនា ២00១) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាពនៅសាលាកសិកម្មព្រែកលៀប* (ឯកសារពិភាក្សាលេខ ១៧) ជាភាសាខ្មែរ តំលៃ ៧.000រៀល ។

១៨. Martin Godfrey, សូ-សុវណ្ណារិទ្ធ ទេព-សារ៉ាវី ប៊ុន-ដូរីណា Claude-Katz Sarthi-Acharya ស៊ីសុវត្ថិ-ឌួង-ចាន់តូ និង ហ៊ីង ថូរ៉ាក់ស៊ី (តុលា ២00១) *ការសិក្សាអំពីទីផ្សារពលកម្មនៅកម្ពុជា: ការកាត់បន្ថយភាពក្រីក្រ ការលូតលាស់ និងការកែតំរូវចំពោះវិបត្តិ* (ឯកសារពិភាក្សាលេខ ១៨) ជាភាសាខ្មែរ តំលៃ ៨.000រៀល ។

១៩. ច័ន្ទ-សុផល ទេព-សារ៉ាវី និង Sarthi Acharya (ធ្នូ ២00១) *ការកាន់កាប់ដីនៅកម្ពុជា: ការវិភាគលើទិន្នន័យចុងក្រោយ* (ឯកសារពិភាក្សាលេខ ១៩) ជាភាសាខ្មែរ តំលៃ ៨.000រៀល ។

២0. សូ-សុវណ្ណារិទ្ធ រៀល-សុភាព អ៊ុច-ឧទេយ្យ ស៊ី-រត្ន័មុនី, Brett Ballard និង Sarthi Acharya (មីនា ២00២) *ការវាយតំលៃសង្គមពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ២0) ជាភាសាខ្មែរ តំលៃ ៨.000រៀល ។

២១. Bhargavi Ramamurthy ស៊ិក-បូរ័ក្ស, Per Ronnås និង សុក-ហាច (មីនា ២00២) *ប្រទេសកម្ពុជាឆ្នាំ១៩៩៩-២000: ការផ្តោតលើបញ្ហាដីធ្លី កំលាំងពលកម្ម និងការចិញ្ចឹមជីវិតនៅជនបទ* (ឯកសារពិភាក្សាលេខ ២១) តំលៃ ៨.000រៀល ។

២២. ច័ន្ទ-សុផល និង Sarthi Acharya (កក្កដា ២00២) *ការលក់ដូរដីធ្លីនៅកម្ពុជា: ការវិភាគទិន្នន័យនៃការផ្ទេរ និងការលក់ដូរដីធ្លី* (ឯកសារពិភាក្សាលេខ ២២) ជាភាសាខ្មែរ តំលៃ ៨.000រៀល ។

២៣. Bruce McKenney និង ព្រុំ-តុលា (កញ្ញា ២00២) *ធនធានធម្មជាតិ និងជីវភាពនៅតាមជនបទក្នុងប្រទេសកម្ពុជា: ការវាយតំលៃជាមូលដ្ឋាន* (ឯកសារពិភាក្សាលេខ ២៣) ជាភាសាខ្មែរ តំលៃ ១0.000រៀល ជាអង់គ្លេស ១0ដុល្លារ ។

២៤. ច័ន្ទ-សុផល គីម-សេតារា និង Sarthi Acharya (ធ្នូ ២00២) *ដីធ្លី ជីវភាពជនបទ និងសន្តិសុខស្បៀងនៅកម្ពុជា: ទស្សនៈបានពីអង្កេតតាមមូលដ្ឋាន* (ឯកសារពិភាក្សាលេខ ២៤) ជាភាសាខ្មែរតំលៃ ៦.000រៀល ជាអង់គ្លេស តំលៃ ៧ដុល្លារ ។

២៥. ច័ន្ទ-សុផល និង Sarthi Acharya (ធ្នូ ២០០២) *បញ្ហាប្រឈមចំពោះការចិញ្ចឹមជីវិតនៅជនបទ: ការសិក្សាលើភូមិចំនួន ៩ នៅកម្ពុជា* (ឯកសារពិភាក្សា លេខ២៥) ជាខ្មែរតំលៃ ៨.០០០រៀល ជាអង់គ្លេស ១០ដុល្លារ ។

២៦. Sarthi Acharya គីម-សេតារា ចាប-សុថារិទ្ធ និង មាច-យ៉ាឌី (កញ្ញា ២០០៣) *ការងារក្រៅកសិដ្ឋាន និងការងារមិនមែនកសិកម្ម: ទស្សនៈស្តីពីការបង្កើតការងារនៅកម្ពុជា* (ឯកសារពិភាក្សាលេខ២៦) ជាខ្មែរ ៧.០០០រៀល អង់គ្លេស ៥ដុល្លារ ។

២៧. យឹម-ជា និង Bruce McKenney (ធ្នូ ២០០៣) *ការនាំចេញត្រីពីបឹងទន្លេសាបទៅប្រទេសថៃ: ការវិភាគលើការរាំងស្ទះពាណិជ្ជកម្ម អភិបាលកិច្ច និងបរិយាកាសសំរាប់ការលូតលាស់* (ឯកសារពិភាក្សាលេខ២៧) ជាខ្មែរតំលៃ ៧.០០០រៀល ជាអង់គ្លេស ១០ដុល្លារ ។

២៨. ព្រុំ-តុលា និង Bruce McKenney (ធ្នូ ២០០៣) *ការធ្វើពាណិជ្ជកម្មផលព្រៃឈើនៅកម្ពុជា: ការប្រឈមការគំរាមកំហែង និងឱកាសសំរាប់ពាណិជ្ជកម្មជ័រទឹក* (ឯកសារពិភាក្សាលេខ២៨) ជាខ្មែរ ៧.០០០រៀល ជាអង់គ្លេស ១០ដុល្លារ ។

២៩. យឹម-ជា និង Bruce McKenney (វិច្ឆិកា ២០០៣) *ពាណិជ្ជកម្មត្រីក្នុងស្រុក: ករណីសិក្សានៃម៉ាឃីទីងត្រីពីបឹងទន្លេសាបទៅក្រុងភ្នំពេញ* (ឯកសារពិភាក្សាលេខ២៩) ជាខ្មែរ ៥.០០០រៀល ជាអង់គ្លេស ៥ដុល្លារ ។

៣០. Caroline Hughes និង គីម សេតារា (មិថុនា ២០០៤) *ការវិវត្តន៍នៃដំណើរការប្រជាធិបតេយ្យ និងការគ្រប់គ្រងទំនាស់នៅកម្ពុជា: ការសិក្សាប្រៀបធៀបការបោះឆ្នោតបីលើកនៅកម្ពុជា* (ឯកសារពិភាក្សាលេខ៣០) ជាភាសាខ្មែរ ១០.០០០រៀល ជាភាសាអង់គ្លេស ១៣,៥០ដុល្លារ ។

៣១. Robert Oberndorf (កក្កដា ២០០៤) *សុខដុមនីយកម្មច្បាប់ទាក់ទងនឹងដំណើរការវិមជ្ឈការនៅកម្ពុជា* (ឯកសារពិភាក្សាលេខ៣១) ជាភាសាខ្មែរ ៥.០០០រៀល ជាភាសាអង់គ្លេស ៦,៥០ដុល្លារ ។

៣២. K.A.S. Murshid និង ទួត សុខផល្លី (ឧសភា ២០០៥) *សេដ្ឋកិច្ចឆ្លងកាត់ព្រំដែនរបស់ប្រទេសកម្ពុជា: ការសិក្សាជំហានដំបូង* (ឯកសារពិភាក្សាលេខ៣២) ជាភាសាខ្មែរ ៨.០០០រៀល ជាភាសាអង់គ្លេស ៥,០០ដុល្លារ ។

៣៣. Kasper K. Hansen និង តុប នេត (ធ្នូ ២០០៦) ***Natural Forest Benefits and Economic Analysis of Natural Forest Conversion in Cambodia*** (ឯកសារពិភាក្សាលេខ៣៣) ជាភាសាអង់គ្លេស ៨,០០ដុល្លារ ។

តំលៃ ៨.០០០ រៀល

9789995052164





វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ផ្ទះលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
ប្រអប់សំបុត្រ ៦២២ ភ្នំពេញ កម្ពុជា
(៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦
(៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdri@camnet.com.kh
website: http://www.cdri.org.kh